ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2012, 16:00
CMS/CFO: Sann Rada

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៨១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធួ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវឌ្ឍី

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអ៊័រ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

កញ្ញា សុង ឆរ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim NAKHJAVANI)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក ឡៃ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោក អូលីវីយ៉េ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារាវស្សី | ខ្មែរ |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អេនឌ្រូ អ៊ីអ៊ុនហ្វ៊ី | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក អូលីវីយេ បាហ៊្វូញ | បារាំង |
| លោក ដេវីដ ឆេនដ័ល័រ (TCE-11) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ដេវីដ ឆេនដ្លឺរ** (TCE-11)


សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖........................................................ទំព័រ ៦

សួរដោយលោក ហុង គីមសួន ផ្ដើមពី៖...................................................................ទំព័រ៣៨

សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្ដើមពី៖.......................................................ទំព័រ៦៥

សួរដោយលោក អូលីវីយេ បាហ៊ូញ ផ្ដើមពី៖...........................................................ទំព័រ៧៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ នៅព្រឹកនេះកិច្ចដំណើរការសវនាការពិភាក្សាដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដែលនឹងបន្តតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា ហើយនិងបន្ទាប់ទៀតគឺ ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

ហើយមុននឹងដំណើរការសូមលោកស្រី សេ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវបានអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនេះ។

[០៩:០៣:០៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែលោកមេធាវី កាណាវាស មេធាវីការពារឲ្យជនជាប់ចោទ អៀង សារី អវត្តមាន។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលមួយថ្ងៃពេញនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះនឹងសម្រេចអំពីសំណើសុំរបស់លោក អៀង សារី ជាមុនសិន។ អង្គជំនុំជម្រះបានទទួលសំណើសុំរបស់លោក អៀង សារី ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សូមលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ដោយគាត់សុំនៅបន្តតាមដានកិច្ចដំណើរការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។ ដោយមានបញ្ហាសុខភាពដែលមិនអាចអង្គុយតាមដានស្ដាប់កិច្ចដំណើរការ

សវនាការដោយផ្ទាល់បាន។

[០៩:០៤:២៧]

តាមអនុសាសន៍របស់លោកវេជ្ជបណ្ឌិត ឈៀង ឃោ ដែលជាគ្រូពេទ្យទទួលបន្ទុកពិនិត្យថែទាំសុខភាពព្យាបាលជនជាប់ចោទនៅមន្ទីរឃុំឃាំង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ បានផ្តល់យោបល់ថា “នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ ជនជាប់ចោទគប្បីត្រូវបានទទួលការអនុញ្ញាតឲ្យនៅតាមដានកិច្ចដំណើរសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍ ដោយមូលហេតុលោក អៀង សារី មានអាការៈវិលមុខខ្លាំង អស់កម្លាំង ហេវហត់ ហើយពិនិត្យទៅឃើញថា មានលក្ខណៈធ្ងន់ធ្ងរជាងកាលពីម្សិលមិញ។

អង្គជំនុំជម្រះយល់ឃើញនៅពេលនេះ ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមាននៅក្នុងបន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងជាមួយនឹងក្រុមមេធាវីរបស់គាត់បានដែរ។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់ចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឲ្យផ្នែកបុគ្គលិកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៦:០៧]

ជាកិច្ចបន្ត ដើម្បីងាយសម្រួលដល់កិច្ចពិភាក្សាទៅពេលមុខទៀត និងធ្វើឲ្យកាន់តែច្បាស់លាស់នូវកិច្ចដំណើរការនៃកិច្ចពិភាក្សានៅក្នុងដំណើរការស្តាប់សក្ខីកម្មអ្នកជំនាញរូបនេះ ក៏ដូចជាសក្ខីកម្មសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនៅពេលក្រោយទៀត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកស្រី ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយបំភ្លឺបញ្ជាក់បន្ថែមលើសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ដែលបានសាកសួរពីម្សិលមិញ អំពីបញ្ហាដាក់ឯកសារដេញដោលនៅក្នុងពេលសវនាការ ហើយនិងបញ្ជាក់បន្ថែមពាក់ព័ន្ធទៅនឹងខ្លឹមសារនៃលិខិតរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ គឺឯកសារ E172/24/4/4 ត្រង់កថាខណ្ឌទី៥។

សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:០៧:២៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចកាលពីម្សិលមិញ ទៅកាន់ក្រុមមេធាវីការពារក្តី នួន ជា ដែលផ្ទុះបញ្ចាំងទៅនឹង -- ដែលដូចទៅនឹងសេចក្តីសម្រេចធ្វើឡើងចំពោះពាក្យសុំរបស់ អៀង សារី ដែលក្នុងនោះ បានបញ្ជាក់ថា ឯកសារដែលចាត់ទុកថាជាឯកសារថ្មីអនុលោមតាមវិធាន៨៧(៤) ត្រូវតែបំពេញលក្ខខណ្ឌនៃវិធាននោះដដែល។ ដោយកំណត់សម្គាល់ឃើញថា ខ្លឹមសារនៃឯកសារទាំងអស់នោះ អាចយកមកប្រើប្រាស់នៅពេលបង្កើតសំណួរសួរទៅកាន់អ្នកជំនាញ។ ហេតុដូច្នេះ វាបង្ហាញយ៉ាងច្បាស់ថា ឯកសារជាច្រើនដែលបានដាក់បញ្ចូលមកក្នុង *អ៊ីនធឺហ្វេស* ប្រចាំថ្ងៃរបស់អង្គជំនុំជម្រះ ដែលវាជាឯកសារថតចម្លងដល់អង្គជំនុំជម្រះតាមលក្ខខណ្ឌនៃអង្គជំនុំជម្រះនោះ។ ឯកសារទាំងអស់នោះ គឺវាទំនងជាបំពេញទៅតាមសេចក្តីសម្រេចវិធាន៨៧(៤)។ ដូច្នេះ ហើយការប្រើប្រាស់ទាំងអស់នោះ វាមិនសូវមានប្រយោជន៍។

[០៩:០៨:៤២]

ដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថា បទប្បញ្ញត្តិវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវតែអនុវត្តដដែល។ គ្មានឯកសារណាមួយអាចយកមកប្រើប្រាស់ដោយអង្គជំនុំជម្រះនោះទេ លើកលែងតែឯកសារទាំងអស់នោះ ដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមបទប្បញ្ញត្តិទាំងឡាយនៃវិធាន៨៧(៤) រួមទាំងចំណុច៤ នៃវិធាន៨៧នេះផងដែរ ដែលក្នុងនោះ ចែងអំពីឯកសារថ្មីដែលទើបតែរកបាន។

អង្គជំនុំជម្រះសូមបញ្ជាក់ឲ្យភាគីយល់ថា គោលបំណងដែលតម្រូវឲ្យមានការជូនដំណឹងទៅដល់ភាគីតាមពេលវេលាជាមុននោះ ជាពិសេសទៅលើឯកសារដែលមិនបានគោរពតាមវិធាន៨៧(៤) គឺដើម្បីអនុញ្ញាតឲ្យភាគី និងអង្គជំនុំជម្រះស្វែងយល់អំពីលក្ខណៈនៃសំណួរទាំងឡាយដែលៗគ្រោងនឹងសួរទៅកាន់អ្នកជំនាញ។ ក្នុងការដាក់ឯកសារ១០០ -- ជាង១១០ នោះ គឺជាគុណប្រយោជន៍ -- គឺមិនមែនជាគុណប្រយោជន៍នៃការជូនដំណឹងទៅដល់អង្គជំនុំជម្រះនោះទេ។

[០៩:១០:០៣]

ហេតុដូច្នេះ អង្គជំនុំជម្រះសូមជូនដំណឹងទៅដល់ភាគីថា “ភាគីគួរតែដាក់ឯកសារឲ្យបានតិចជាងនេះបន្តិចឲ្យត្រឹមប្រាំ ឬដប់បានហើយ។ យ៉ាងហោចណាស់ឲ្យពីរអាទិត្យមុនពេលយកមកសួរដេញ

ដោលទៅកាន់សាក្សី ដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីពិនិត្យមើលឯកសារទាំងអស់នោះបាន"។ សេចក្តីសម្រេចកាលពីម្សិលមិញក៏បានចែងបំភ្លឺផងដែរថា ឯកសារទាំងអស់នោះគឺមិនអាចប្រើប្រាស់ថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ។ មានតែខ្លឹមសារនៃឯកសារទាំងអស់នោះប៉ុណ្ណោះដែលអាចយកមកប្រើប្រាស់សម្រាប់ដេញដោលទៅលើអ្នកជំនាញ។ ហេតុដូច្នេះ អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យយកការដកស្រង់សម្តីណាមួយពីឯកសារទាំងអស់នោះ ហើយក៏មិនអនុញ្ញាតឲ្យមានការបង្ហាញអត្តសញ្ញាណនៃឯកសារទាំងអស់នោះនៅក្នុងតុលាការផងដែរ។

[០៩:១១:០៦]

ចំណុចចុងក្រោយ ឯកសារបែបនោះ ប្រសិនបើយកមកប្រើប្រាស់ជាមូលដ្ឋាននៃការសួរដេញដោលសំណួរទៅកាន់អ្នកជំនាញនោះ ឯកសារទាំងអស់នោះត្រូវតែពាក់ព័ន្ធទៅនឹងឯកសារ -- ទៅនឹងការជំនុំជម្រះសំណុំរឿង០០២/០១។ លោកប្រធាននឹងមិនអនុញ្ញាតឲ្យសួរសំណួរទាំងឡាយណាដែលវាពាក់ព័ន្ធនិងជាន់គ្នាច្រំដែលនោះឡើយ។

នៅក្នុងសេចក្តីសម្រេចទីពីរ ដែលអង្គជំនុំជម្រះមានបំណងឲ្យខ្ញុំពន្យល់ក្នុងថ្ងៃនោះ នោះគឺថាសហមេធាវីនាំមុខគឺបានផ្តល់ -- ទទួលបាននូវពេលវេលាវគ្គទីពីរនៅព្រឹកនេះ និងពេលរសៀលដើម្បីដេញដោល។ សំណួរដែលគ្រោងនឹងសួរនោះ គឺត្រូវតែមានការពាក់ព័ន្ធនឹងមិនច្រំដែលគ្នានោះទេ។ ហើយខ្ញុំសង្ឃឹមថាសហមេធាវីនាំនឹងយល់អំពីសេចក្តីសម្រេចនេះ។ ហើយលោកប្រធាននឹងធ្វើការកាត់ -- នឹងកាត់បន្ថយពេលវេលាក្នុងករណីដែលមានសំណួរណាមួយជាន់គ្នា ឬក៏មិនពាក់ព័ន្ធនោះ។

សូមអរគុណលោកប្រធាន។ ខ្ញុំបានគ្របដណ្តប់និងបង្ហាញទៅលើសេចក្តីសម្រេចនេះរួចហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[០៩:១២:២៦]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីក្រុមប្រឹក្សាជំនុំជម្រះ លោក លោកស្រីជាភាគីទាំងអស់។ ខ្ញុំយល់អំពីសេចក្តីសម្រេចរបស់លោកស្រីចៅក្រម ខាតវ៉ាយថ៍ យ៉ាងល្អ ក៏ប៉ុន្តែដើម្បីជាការបំភ្លឺចៅក្រម ខាតវ៉ាយថ៍ គឺនិយាយអំពីឯកសារ១១០ ដែលបាន -- ឯកសារ ១.១០០ ដែលបានដាក់ចូលទៅក្នុងប្រព័ន្ធអ៊ីនធឺហ្វេស។ ខ្ញុំមិនដឹងថាអ្នកណាគេអាចធ្វើដូច្នោះនោះទេ ក៏ប៉ុន្តែប្រហែលជាក្រុមរបស់ខ្ញុំ

ហ្នឹងជាអ្នកដាក់បញ្ចូល។ មិនមែនថាដាក់បញ្ចូលដោយចេតនានោះទេ។ យើងខ្ញុំមិនមានបំណងឯកសារ -- មានបំណងដាក់ឯកសារច្រើនជាងអ្វី ដែលយើងត្រូវតែបំពេញតាមលក្ខខណ្ឌ៨៧(៤) ក៏ប៉ុន្តែ ប្រហែលជាមានកំហុសខ្លះទៅលើចំណុចនេះ។ យើងខ្ញុំមិនបានដឹងអំពីការដាក់ឯកសារ ១.១០០ នោះទេ។ យើងខ្ញុំមិនមានបំណងធ្វើដូច្នោះនោះទេ ខ្ញុំនឹងធ្វើការពិនិត្យឡើងវិញក្នុងពេលសម្រាកថា តើយើងខ្ញុំដាក់បញ្ចូលឯកសារទាំងអស់នេះ ឬក៏យ៉ាងម៉េច?

[០៩:១៣:៣១]

យើងខ្ញុំសូមបញ្ជាក់ ហើយសូមអធ្យាស្រ័យថាយើងខ្ញុំមិនមែនមានចេតនាដាក់ឯកសារ១.១០០ នោះឡើយ។ ប្រហែលជាភាគីដទៃទៀតអាចបញ្ជាក់បំភ្លឺបានទៅលើចំណុចនេះ។ ហើយប្រសិនបើពាក់ព័ន្ធទៅនឹងឯកសារ ១.១០០ នេះមែននោះ គឺខ្ញុំសូមអធ្យាស្រ័យដល់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ដោយហេតុថាពេលវេលាវាសំខាន់ ខ្ញុំសូមបញ្ជាក់បំភ្លឺបន្តិច តាមអ្វីដែលយើងបានសុំកាលពីម្សិលមិញថា យើងមានរយៈពេលមួយម៉ោងកន្លះ ក៏ប៉ុន្តែគឺយើងខ្ញុំសូមអនុញ្ញាត ១៥នាទីទៀតបន្ទាប់ពីការឈប់សម្រាក ដោយសារតែអម្បាញ់មិញនេះមានការបង្ហាញ និងការតវ៉ាពីភាគី។ ដូច្នេះតើអនុញ្ញាតដែរឬទេ គឺសុំ ១៥នាទីទៀតក្រោយពេលឈប់សម្រាកលោកប្រធាន?

[០៩:១៤:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងច្រើនលោកប្រធាន។ អរុណសួស្តីលោកសាស្ត្រាចារ្យ សូមអរគុណដែលលោកវិលត្រឡប់មកផ្តល់សក្ខីកម្មឡើងវិញ។ ដូចដែលលោកបានស្តាប់ជ្រាបមកហើយ គឺយើងនឹងធ្វើការដេញដោលលោក គឺ១ម៉ោងកន្លះបន្ថែមទៀត។ ហើយយើងខ្ញុំនឹងព្យាយាមដំណើរការឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** កាលពីម្សិលមិញយើងនិយាយអំពីការបង្កើត និងបេសកកម្មរបស់ស-២១ នៅក្នុងទិដ្ឋភាពខ្លះនៃប្រតិបត្តិការរបស់មន្ទីរនោះ រួមទាំងទម្រង់បែបបទនៃការសរសេរចម្លើយសារភាព និងឯកសារទាំងឡាយដែលលោកបានពិនិត្យពីបណ្ណសារស-២១។ យោងតាមការផ្តល់បរិបទទៅលើប្រធានបទតូចៗដែលខ្ញុំនឹងដេញដោលទៅលើលោក។ ខ្ញុំសូមសួរសំណួរដំបូងឲ្យលោកធ្វើការពន្យល់ទិដ្ឋភាពទូទៅខ្លីៗ ដែលលោកបាននិយាយអំពីការបោសសម្អាតទ្រង់ទ្រាយធំ កើតឡើងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៦ និងក្រោយឆ្នាំ៧៦។ ខ្ញុំនឹងអានដំណកស្រង់ខ្លីៗចេញពីសៀវភៅ ស-២១ ដើម្បីឲ្យបុគ្គលភាគីទាំងអស់យល់អំពីការវិភាគរបស់លោកទៅលើបញ្ហាបោសសម្អាតធំធេងនេះ។

[០៩:១៦:២៨]

ឯកសារ D108/50/1.4.6។ ខ្មែរERN គឺ 00191880, អង់គ្លេសគឺ 00192724 យើងខ្ញុំនឹងបញ្ជូនឯកសារជាក្រដាសជូនទៅលោកសាស្ត្រាចារ្យ បារាំងលេខ ERN គឺ 00357311 ខ្ញុំនឹងអានការដកស្រង់ខ្លីមួយចេញពីសៀវភៅរបស់លោកមួយនេះ។ ការដកស្រង់សម្តី ប្រសិនបើអាចបញ្ចាំងឯកសារជាភាសាខ្មែរនៅលើអេក្រង់បាននោះ គឺសូមធ្វើឡើងផង៖ "វិសុទ្ធកម្មការបោសសម្អាតធ្វើឡើងដោយមជ្ឈិមបក្ស និងអនុវត្តនៅមន្ទីរសន្តិសុខ ស-២១ អាចចែកចេញជាពីរជំហានធំៗ។ ជំហានទីមួយគឺចាប់ផ្តើមធ្វើឡើងពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែកញ្ញា ឆ្នាំ៧៦។ ជំហានទីពីរ គឺបន្តរហូតមកដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ មនុស្សដែលមុខសញ្ញាក្នុងការធ្វើវិសុទ្ធកម្មលើកទីមួយ គឺប្រជាជនស៊ីវិល និងយុទ្ធជនមានស័ក្តិធំៗរបស់របបលន់ នល់។ ជាលទ្ធផល ប្រជាជនរាប់ពាន់នាក់ត្រូវបានប្រមូលយកទៅសម្លាប់ចោល"។ បាទ ខ្ញុំរំលងមួយប្រយោគ ចុះមកក្រោមបន្តិច "អំពើមនុស្សឃាតក្នុងឆ្នាំ៧៥ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការអប់រំកសាងខ្លួននៅប្រទេសវៀតណាម គឺធ្វើឡើងតាមបញ្ជាពីថ្នាក់លើដាច់ខាត"។ តាមចម្លើយ ទៅខាងក្រោមបន្តិចទៀត ខ្ញុំសូមដកស្រង់សម្តី៖ "នៅក្នុងប្រទេសកម្ពុជា ការសម្លាប់គឺធ្វើឡើងនៅក្នុងឆ្នាំ៧៥ ដោយបក្ស។ ក្រោយមកយើងឃើញមានឯកសារជាច្រើនដែលបានលើកឡើងអំពីបញ្ហាខ្មាំង បានបញ្ជូនទៅសន្តិបាល គឺបានបង្ហាញឲ្យយើងឃើញ"។

[០៩:១៨:៤៣]

លោកសាស្ត្រាចារ្យ ប្រសិនបើខ្ញុំសូមឲ្យលោកធ្វើការបកស្រាយទៅលើការសន្និដ្ឋានរបស់លោក

ពាក់ព័ន្ធទៅនឹងការប្រមូលយកមកសម្លាប់ចំពោះបុគ្គលដែលពាក់ព័ន្ធទៅនឹងរបបលន់ នល់ នោះគឺកើតឡើងរហូតមកដល់ខែមិថុនា ឆ្នាំ៧៥ និងក្រោយមកទៀត។ ថាតើនីតិវិធីនេះបានកើតឡើង ដែរឬទេ? ហើយសូមលោកពន្យល់ ថាតើលោកសន្និដ្ឋានចំណុចនេះផ្អែកលើអ្វី? ហើយចំណុចសំខាន់នោះគឺវាបានឆ្លុះបញ្ចាំងទៅលើអ្វីខ្លះ នៅក្នុងពេលបោសសម្អាតនោះ?

**លោក ឆេវីង ឆេនដ៏ល័រ៖**

**ឆ៖** សូមអរគុណ។ អរុណសួស្តី។ ការបោសសម្អាតអតីតមន្ត្រីរដ្ឋាភិបាលលន់ នល់ និងទាហាននៅពេលនោះ គឺយើងបាន -- ទទួលបានព័ត៌មានតាមរបាយការណ៍អ្នកភៀសខ្លួន ឯកសារកម្ពុជាប្រជាធិបតេយ្យនោះមិនមានបង្ហាញទៅលើចំណុចនេះទេ នៅពេលដែលខ្ញុំសរសេរសៀវភៅនោះឡើង។ អ្នកដែលជនភៀសខ្លួនដែលខ្ញុំបានសម្ភាស គឺបានបង្ហាញនៅក្នុងទសវត្សរ៍ទី៨០ និងព័ត៌មានរបស់អ្នកសរសេរសៀវភៅផ្សេងទៀត គឺបានបង្ហាញអំពីការបោសសម្អាតដំណាក់កាលទាំងអស់នោះ។ ហើយគឺមានការកាប់សម្លាប់ដូចទៅនឹងសង្គ្រាមលោកលើកទី២ ហើយវាបានកើតឡើងគ្រប់ពេលទាំងអស់នៅក្នុងរបបនោះ។ គឺយើងឃើញថា ជីវិតជាច្រើនមានការស្លាប់នៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែយើងឃើញថា វាមានការកើនឡើងនៅក្នុងរបបនោះ។ នៅក្រោយមក នៅតាមគុកខេត្តនោះ ភស្តុតាងបានបង្ហាញថា ប្រសិនបើគេរកឃើញប្រជាជនថ្មីពាក់ព័ន្ធទៅនឹងរបប លន់ នល់ នោះ គេនឹងដកចេញពីកម្លាំងការងារ ហើយក្នុងករណីជាច្រើននោះ ត្រូវយកមកសម្លាប់ចោល។ ដូច្នេះហើយគឺមានករណីមួយចំនួននោះ បានបន្តនូវការបោសសម្អាតនេះ។

[០៩:២០:៤៩]

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ។ ខ្ញុំសូមចូលទៅដល់ចំណុច ដែលលោកបានពិភាក្សា និងការរៀបរាប់របស់លោក និយាយអំពីមនោគមន៍វិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ ដែលមនោគមន៍វិជ្ជានោះ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះខ្មាំង។ ចំណុចនេះ នៅក្នុងសៀវភៅ "សំឡេងពីស-២១" ខ្មែរ ERN គឺ 00191972, អង់គ្លេសគឺ 00192813, បារាំងគឺ 00357393។ ប្រសិនបើយើងមាន សូមបង្ហាញអត្ថបទជាភាសាខ្មែរនោះ នៅលើអេក្រង់ ខ្ញុំសូមដកស្រង់សម្តី៖ "មនោគមន៍វិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ ដូចដែលយើងបានឃើញ គឺធ្វើយ៉ាងណាបន្តការតស៊ូទៅលើវណ្ណៈ ហើយធ្វើការតស៊ូបដិវត្តន៍ប្រឆាំងទៅនឹងខ្មាំង ដែលខ្មាំងនេះ យើងត្រូវតែកម្ទេចបំផ្លាញ។ ខ្មាំងមួយចំនួននៅតាមព្រំដែនកម្ពុជា អ្នកមួយចំនួននោះនៅឆ្ងាយ។ យើងឃើញថា ខ្មាំងមួយចំនួន ជាខ្មាំងស៊ីរូងផ្ទៃក្នុង។ ខ្មាំងភាគច្រើន

បន្លំខ្លួនធ្វើជាមិត្ត ដើម្បីជីកពួកគេចេញ ចាំបាច់ត្រូវចាត់វិធានការឲ្យបានតឹងរ៉ឹង"។

[០៩:២២:២១]

ខ្ញុំសូមបង្ហាញការដកស្រង់ចេញពីទស្សនាវដ្ដីទង់បដិវត្ត ដែលលោកបានយកមកសរសេររៀបរាប់នៅក្នុងសៀវភៅ សោកនាដកម្មកម្ពុជា។ ទស្សនាវដ្ដីបដិវត្តនេះចុះថ្ងៃ ចុះខែសីហា ៧៥ ឯកសារ E3/5។ ខ្ញុំសូមអានការដកស្រង់សម្ដីមួយចំនួន ចេញពីទង់បដិវត្តនោះ ដើម្បីឲ្យបញ្ជាក់ថា តើវាពាក់ព័ន្ធទៅនឹងអ្វីដែលលោករៀបរាប់នៅក្នុងសៀវភៅនោះដែរឬទេ? ERN ជាភាសាខ្មែរ 00063341 ទៅដល់ 42, អង់គ្លេសគឺ 00401501 ទៅដល់ 02, បារាំង ERN គឺ 00538976 ទៅដល់ 77។ ឯកសារនេះគឺវែង ប៉ុន្តែខ្ញុំនឹងអានចំណុចដកស្រង់ខ្លីចំនួនបី។

ការដកស្រង់សម្ដី៖ "ដោយសារតែបញ្ហានេះ កងទ័ពរបស់យើងត្រូវបំពេញបេសកកម្មការពារប្រទេសឲ្យបានរឹងមាំ"។ ចំណុចមួយទៀតពីរប្រយោគខាងក្រោមគឺបានន័យថា "ចំពោះការការពារទីក្រុងភ្នំពេញ និងកម្ទេចពួកចក្រពត្តិអាមេរិក គឺយើងឃើញថា ពួកទាំងអស់នេះចង់បន្តបំផ្លាញបដិវត្តន៍របស់យើង។ យើងត្រូវតែធ្វើយ៉ាងណាកសាងកម្លាំងរួមគ្នា ដើម្បីការពារបដិវត្តន៍"។ នៅខាងក្រោមនេះបន្តិច បានន័យថា "ខ្មាំងខាងក្រៅ និងខ្មាំងនៅផ្ទៃក្នុងត្រូវ -- នៅតែមានដដែល។ ការតស៊ូវណ្ណៈ ការតស៊ូចំពោះប្រជាជននៅតែមានដដែល ដើម្បីកម្ទេចខ្មាំងទាំងអស់នោះ"។

[០៩:២៤:១៤]

ការដកស្រង់សម្ដីទាំងអស់នេះ គឺបានលើកឡើងអំពីការប្រយុទ្ធប្រឆាំងទៅនឹងវណ្ណៈ និងការប្រុងប្រយ័ត្នដែលត្រូវតែអនុវត្ត។ នៅក្នុងអត្ថបទនេះ គឺវាពាក់ព័ន្ធទៅនឹងអ្វីដែលលោករៀបរាប់អំពីការកម្ទេចខ្មាំង ដែលត្រូវធ្វើឡើង និងការរក្សាប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ដូចអ្វីដែលលោកបានសរសេរ។ សូមលោកបញ្ជាក់លើចំណុចនេះ។

**ឆ៖** ជាការពិត ខ្ញុំបានដកស្រង់ចំណុចនេះ នៅក្នុងសៀវភៅ ហើយយើងឃើញថា នេះវាជាគោលបំណងរបស់របបនោះ ហើយវាជាចំណុចមួយចាប់អារម្មណ៍ ជាពិសេសនៅក្នុងរយៈពេលប៉ុន្មានឆ្នាំនោះ។ ខ្មាំងក្នុង និងផ្ទៃក្នុង និងខ្មាំងខាងក្រៅ គឺឃើញមាននៅក្នុងឆ្នាំ៧៥ ហើយនិងក្រោយមកទៀត។ ហើយគេបានប្រើប្រាស់ឧបករណ៍យុទ្ធសាស្ត្រ ដើម្បីធ្វើការបោសសម្អាតចំពោះក្រុមទាំងអស់នោះ។ នៅក្នុងអត្ថបទនេះ គឺវាបានជំរុញឲ្យអ្នកដែលបានតាមដានស្ដាប់នោះ គឺត្រូវតែមានការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ប្រឆាំងនឹងខ្មាំង។ ចំណុចសំខាន់មួយទៀត គឺវាមិនបានកំណត់ច្បាស់លាស់នៅត្រង់ចំណុច

នេះ។ នៅពេលដែលខ្ញុំនៅទីនេះ គឺៗយើង -- វាហាក់ដូចជាខ្ញុំកំពុងតែមានខ្លាំងសំខាន់ៗជាច្រើន ហើយគ្មាននរណាមួយនៅក្នុងបន្ទប់នេះអាចឲ្យយើងទុកចិត្តនោះឡើយ។ ដូច្នេះ វាអាចប្រៀបធៀបទៅនឹងករណីនេះបាន ហើយវាជាបរិយាកាសដែលកើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ខ្មាំងខាងក្នុងនោះ គឺត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ដើម្បីធ្វើការបោសសម្អាត ហើយគេព្យាយាមធ្វើយ៉ាងណាការពារបដិវត្តន៍ ហើយធ្វើយ៉ាងណាដឹងអំពីសមាសភាពទាំងអស់នោះ ដើម្បីឲ្យដឹង។ វាជាចំណុចមួយដែលគេធ្វើយ៉ាងណាឲ្យមានតុល្យភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។

[០៩:២៦:១៥]

**ស៖** ដើម្បីឲ្យយើងយល់ច្បាស់ទាំងអស់គ្នានៅទីនេះ ផ្អែកតាមការស្រាវជ្រាវរបស់លោក ថាតើទង់បដិវត្តនេះ គឺអត្ថបទដែលបានដកស្រង់តំណាងអ្វីដែរ?

**ឆ៖** វាជាទង់បដិវត្តដែលគេចែកផ្សាយជូនទៅដល់សមាជិកបក្ស។ អត្ថបទនេះគឺសរសេរឡើងដោយសមាជិកជាន់ខ្ពស់ ឬក៏អត្ថបទនេះគឺវាឆ្លុះបញ្ចាំងអំពីសុន្ទរកថាដែលធ្វើឡើងដោយកម្មាភិបាលថ្នាក់ខ្ពស់ ក៏ប៉ុន្តែឈ្មោះដែលអ្នកសរសេរនោះ គឺមិនបានសរសេរបញ្ជាក់ថាជានរណានោះទេ។

**ស៖** សូមអរគុណ។ លោកបានរៀបរាប់ និងពិភាក្សាជាមួយនឹងចៅក្រម ខាតវ៉ាយថ៍ កាលពីថ្ងៃពុធ អំពីចំណុចសំខាន់នៃសេចក្ដីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ សេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការកម្ទេចនៅក្នុងឯកសារនោះ។ ខ្ញុំមិនចង់លើកឡើងសាជាថ្មីនោះទេ ក៏ប៉ុន្តែសេចក្ដីសម្រេចនោះគឺជាចំណុចយោងមួយដែលវាពាក់ព័ន្ធទៅនឹងឆ្នាំ៧៦។ ខ្ញុំមានបំណងបង្ហាញឯកសារមួយទៀត គឺឯកសារទង់បដិវត្ត ហើយឲ្យលោកពិចារណា និងពន្យល់យើងខ្ញុំ ថាតើខ្លឹមសារនៅក្នុងនោះ គឺវាចង្អុលបង្ហាញយ៉ាងម៉េចទៅលើគោលនយោបាយ? ឯកសារ E3/4 ទង់បដិវត្ត ចុះខែកក្កដា ឆ្នាំ៧៦។ ខ្មែរ ERN គឺ 00062922, អង់គ្លេសគឺ 00268927, បារាំង 00349980។ ប្រសិនបើអនុញ្ញាតនោះ គឺខ្ញុំនឹងផ្ដល់ឯកសារនេះជាក្រដាសទៅដល់អ្នកជំនាញដើម្បីអាចងាយមើល។

[០៩:២៨:៤២]

លោកសាស្ត្រាចារ្យ ប្រសិនបើលោកពិនិត្យមើលទៅលើលេខ ERN ត្រង់ចំណុចដែលខ្ញុំបានអានអម្បាញ់មិញនោះ ឬក៏ត្រង់ទំព័រលេខ ERN 927 នោះ សូមលោកមើល ការពិភាគទៅលើចំណុចផ្សេងទាំងបញ្ហាអត្តនោម័តិ និងសត្យានុម័តិនោះ។ ជាសត្យានុម័តិ មារសត្រូវយើងឃើញមាន ពីរប្រយោគខាងក្រោម។ "ទិដ្ឋភាពយាយី វានៅតែជាប្រចាំ បំផ្លាញយើងតាមគ្រប់វិធីបែបយ៉ាង។ បំផ្លាញពីក្រៅ

បំផ្លាញពីក្នុង តែពីខាងក្រៅវាយយើងមិនបានទេ ទាល់តែវាយពីក្នុង។ ដើម្បីវាយពីក្នុងបាន ទាល់តែវាយមាគ៌ា ធ្វើឲ្យមាគ៌ាច្របូកច្របល់នៅក្នុងផ្ទៃក្នុងបក្ស នៅក្នុងយោធា។ នៅក្នុងចំណោមប្រជាជនដើម្បីគេងាយបំបែក"។

អត្ថបទបន្ទាប់ទៀត មុនពេលដែលខ្ញុំសួរសំណួរចេញពីឯកសារនេះនោះគឺ ខ្មែរ ERN គឺ 0062935 ERN ជាភាសាអង់គ្លេសគឺ 00268938, បារាំងគឺ 00349989។ ការដកស្រង់សម្ដី៖ "កាលពីមុន ការឧទ្ទេសនាមមួយចំនួន គឺមានច្រើន ក៏ប៉ុន្តែឧទ្ទេសនាមមួយចំនួននោះ គឺវាធ្វើឡើងក្នុងឆ្នាំ៧០-៧១ ដូច្នេះសមាសភាពឱកាសនិយម វាចូលបានច្រើន។ តែបក្សបិទទ្វារសម្រិតសម្រាំងបានជាអតិបរិមា"។ រំលងមួយប្រយោគ ប្រយោគខាងក្រោមសរសេរថា "នៅក្នុងនេះ តាមបទពិសោធន៍ត្រូវក្ដាប់ប្រវត្តិរូបឲ្យបាន។ បើប្រវត្តិរូបមិនច្បាស់ ទោះជាល្អក៏ដោយ ក៏កុំអាលបញ្ចូល ប្រយ័ត្នពួក សេ.អ៊ី.អា វាជ្រៀតចូល។ សេ.អ៊ី.អា វាវាយបដិវត្តន៍ ដោយបញ្ចូលថ្នាំតាមសរសៃឈាមរបស់បដិវត្តន៍"។ តើចំណុចនេះ វាបង្ហាញអ្វីខ្លះពាក់ព័ន្ធទៅនឹងការ -- ពាក់ព័ន្ធទៅនឹងខ្មាំងនាពេលនោះ?

[០៩:៣១:២៥]

**ឆ៖** នេះជាចំណុចមួយ អត្ថបទមួយដែលគេចង្អុលបញ្ជាក់ទៅលើការកំណត់ខ្មាំង ជាពិសេសបុគ្គលដែលត្រូវបានគេបញ្ចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា។ យើងមិនមានចំនួនតួលេខអ្នកដែលចូលបក្សនោះទេ យើងឃើញថាមានចំនួនណាស់ រាប់ពាន់នាក់ឯណោះ រាប់ម៉ឺននាក់ឯណោះ ដែលបានចូលរួមនៅក្នុងសង្គ្រាមស៊ីវិល។ នៅពេលដែលសង្គ្រាមកាន់តែក្លាយជាបដិវត្តន៍ -- ប្រតិបត្តិការរបស់ខ្មែរក្រហមនោះ ប្រតិបត្តិនេះកាន់តែមាន កាន់តែច្រើន។ នៅក្នុងរបបលន់ នល់ យើងដឹងថា ខ្មែរក្រហម គឺគេត្រូវធ្វើយ៉ាងណាបង្កើត បញ្ចូលកម្មាភិបាលឲ្យបានច្រើនដែលពួកគេទុកចិត្ត ហើយបញ្ចូលចូលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនោះ យើងឃើញមានមន្ត្រីយោធា អ្នកដឹកនាំ អ្នកដែលជាអ្នកធ្វើការនៅក្នុងបក្សរបស់គេ។ ខ្ញុំមិនបានឃើញមើលឯកសារណាមួយ ដែលពាក់ព័ន្ធទៅនឹងការបញ្ចូលបក្សនោះទេ។ ក៏ប៉ុន្តែវាជាអត្ថបទមួយដែលត្រឹមត្រូវ ហើយយើងឃើញថានៅក្នុងនោះ គឺគេត្រូវការពិនិត្យមើលប្រវត្តិរូបឲ្យបានហ្មត់ចត់។

ចំណុចនេះ គឺឲ្យយើងយល់បាននៅក្នុងសម័យសង្គ្រាម ហើយអ្នកខ្លះនោះ គឺយើងអាចគិតទៅថាអ្នកខ្លះនោះ គេបង្ហាញថាគេជាកសិករក្រីក្រ ហើយគេមិនជាប់ពាក់ព័ន្ធទៅនឹងសម័យ លន់ នល់ នោះទេ។ ដូច្នេះករណីទាំងអស់នេះ វាត្រូវតែធ្វើការសម្រិតសម្រាំងទៅលើប្រវត្តិរូប។ បញ្ហាប្រវត្តិរូបនេះ

គឺវាផ្ទុះបញ្ចាំងនូវអ្វីដែលយើងបានពិភាក្សាកាលពីលើកមុន ដែលគេថាធ្វើយ៉ាងណា គេធ្វើការកំណត់ទៅលើខ្មាំងដកចេញពីក្នុងនោះ ជាពិសេសគឺខ្មាំងដែលពាក់ព័ន្ធទៅនឹងរបប លន់ នល់ ដែលនៅសល់។

[០៩:៣៣:២០]

**ស៖** លោកបានពិភាក្សា ម្សិលមិញលោកបានពិនិត្យមើលប្រវត្តិរូបរបស់អ្នកឃាម ស-២១។ ផ្នែកមួយដែលយើងបាននេះ គឺបង្ហាញអំពីទាក់ទងទៅនឹងត្រូវពិនិត្យលើប្រវត្តិរូប ដើម្បីឲ្យចូលទៅក្នុងបក្ស។ តើអ្វីលោកយល់ដូចម្តេច គឺថាដើម្បីឲ្យរបបនោះធ្វើការបាន ហេតុអីក៏គេប្រើប្រវត្តិរូបដើម្បីធ្វើការងារនេះ?

**ឆ៖** ប្រវត្តិរូបគេប្រើជាទូទៅនៅក្នុងរបបនេះ។ នេះហើយគឺ ជាគំនិតថ្មីនៅក្នុងប្រទេសកម្ពុជា គឺថាម្នាក់ៗនៅក្នុងបក្សត្រូវតែធ្វើប្រវត្តិរូប ដើម្បីប្រើនៅក្នុងការសិក្សា វគ្គសិក្សា ហើយជាពិសេស គឺមេដឹកនាំបក្ស។ នៅក្នុងចម្លើយសារភាពមួយនោះ ក៏គេមានសេចក្តីលម្អិត គឺថាដកស្រង់ចេញមកពីឯកសារ គឺជាពិសេស គឺថាជាព័ត៌មានដែលត្រឹមត្រូវ មិនត្រឹមត្រូវដែលគេត្រូវពិចារណានោះ។ នេះគឺជាចំណុចសំខាន់ គឺថាចំណុចផ្សេងៗនៅក្នុងជីវិតអតីតកាលនោះ គឺថាជាចង្អុលបង្ហាញថា តើខ្លួននៅក្នុងវណ្ណៈអ្វី បើសិនជាកសិករកណ្តាល ឬកសិករក្រគឺអាចជាគេទុកចិត្ត។ បើសិនជាពាក់ព័ន្ធទៅនឹងរបប លន់ នល់ ឬក៏ជាព្រះសង្ឃអីហ្នឹង គឺជាវណ្ណៈមួយដែលគេសង្ស័យមិនសូវបរិសុទ្ធ។ នេះហើយគឺគេពិនិត្យមើលប្រវត្តិរូបដើម្បីកំណត់ពីវណ្ណៈ។

[០៩:៣៥:០៣]

ហើយបើសិនជាគេចោទថា ជាប្រព្រឹត្តបទខុសអីក៏គេពិនិត្យមើលប្រវត្តិរូបថា តើមានការប្តូរទេប្រវត្តិរូប ឬក៏មានការលុបចោល។ នេះ ហើយជាឯកសារដ៏សំខាន់របស់របបនេះ។ នេះជាឧបករណ៍មួយរបស់របប ដើម្បីការត្រួតត្រា ដើម្បីរកថាតើអ្នកណាជាអ្នកណា ដើម្បីប្រើជាឯកសារកំណត់សមាជិកភាព ឬភាពស្មោះត្រង់នឹងបក្ស។ ហ្នឹងគឺសារៈសំខាន់នៃប្រវត្តិរូប។

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងចូលទៅដល់ផ្នែកមួយទៀតដែលលោកបានសរសេរយ៉ាងលម្អិតគួរសមនៅក្នុងសៀវភៅ ស-២១ "សំឡេងពីស-២១" គឺហេតុការណ៍ៗ ដើមឆ្នាំ១៩៧៦។ ជាពិសេសហេតុការណ៍នៅក្នុងខេត្តសៀមរាប ហើយនិងៗហេតុការណ៍នៅភ្នំពេញផងដែរ ការទម្លាក់គ្រប់បែក ការផ្ទុះគ្រាប់បែកបាទ។ សូមលោកពន្យល់បន្ថែមបានដែរឬទេ អំពីហេតុការណ៍ ឬក៏ចង់ឲ្យខ្ញុំអានសេចក្តីនៅក្នុងសម្រង់នេះជូនលោកស្តាប់ជាមុន? ឬក៏លោកអាចឆ្លើយមុនបាន?

[០៩:៣៦:២៧]

**ឆ៖** ហើយខ្ញុំមិនបាននិយាយច្រើន គឺថាខ្ញុំបានពិនិត្យការផ្ទុះគ្រាប់បែកនៅសៀមរាប ខ្ញុំមិនអាចពន្យល់បានទេ។ បញ្ញវន្តដែលធ្វើការងាររឿងនេះ គឺថាអាចនឹង -- គឺអាចនឹងមានការផ្ទុះដោយថៃដន្យ អាចជាការវាយប្រហារផ្លូវអាកាសពីថៃ ហើយជាបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយអ្នកក្នុងមូលដ្ឋានក៏មិនដឹង ហើយប៉ុន្តែការនេះធ្វើឲ្យរបបនោះមានការភ័យខ្លាច។ រីឯនៅភ្នំពេញវិញ ជាថ្មីម្តងទៀតនោះមានការគប់បែក បោកគ្រាប់បែកនៅជិតវាំង។ ដូចដែលលោកបានឮពីខាងដើមហើយ កន្លែងមួយចំនួនដែលមេដឹកនាំរស់នៅនោះ នៅក្បែរវាំងនោះឯង។

ហើយគឺមានគ្រាប់បែកផ្ទុះនៅនេះ ហើយនេះជា -- បញ្ហាទាំងអស់នេះគេត្រួតត្រាច្បាស់លាស់ណាស់ គេពិនិត្យមើល ហើយគេចាត់ទុកថាជាវាយប្រហារទៅលើរបប។ អង្គភាពយោធាដែលកាន់ការនៅភ្នំពេញ -- សៀវភៅខ្ញុំបានបញ្ជាក់ពីចំនួនគឺមានក្រុមដែលកងទ័ព ដែលយកមកពីភូមិភាគបូព៌ាដែលបញ្ជាដោយអតីតកម្មាភិបាលមកពីនោះ ហើយគេគិតថា យោធាទាំងអស់នេះគឺជាអ្នកដាក់គ្រាប់បែកឲ្យផ្ទុះ ហើយគ្រាប់បែកហ្នឹងត្រូវបានបញ្ជាដោយកម្មាភិបាលមកពីបូព៌ានេះ។ ហើយជាៗការស៊ើបអង្កេតរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់ថាពួកដែលមកពីជាប់ព្រំប្រទល់ពីវៀតណាម ហ្នឹងគឺជាជនសង្ស័យ។ នេះហើយជាចំណុចចាប់ផ្តើមរបស់គេនោះ ដែលថា ស-២១ ដែលបង្កើតនៅវិទ្យាល័យ -- អតីតវិទ្យាល័យនោះបានបង្កើតបន្ទាប់ពីហ្នឹងភ្លាម ពីហេតុការណ៍ហ្នឹងភ្លាម។

[០៩:៣៨:២៩]

**ស៖** សូមអរគុណដែលលោកបានផ្តល់សេចក្តីពន្យល់នេះ។ លោកបានពិភាក្សាបន្ថែមទៀតអំពីបញ្ហា ឬក៏កម្មាភិបាលភូមិភាគបូព៌ា នៅក្នុងសៀវភៅរបស់លោក។ តើមានបញ្ហាអ្វីពាក់ព័ន្ធ -- សូមទោស ខ្ញុំសូមកែសម្រួលឃ្លានេះឡើងវិញ។ កាលណាពិនិត្យមើលការចាប់ខ្លួនកម្មាភិបាលឈ្មោះ កុយ ធួន ដែលលោកបានសរសេរក្នុងសៀវភៅរបស់លោកដែរ។ ថាតើមានហេតុការណ៍អ្វីសំខាន់ដែលថាមានការចាប់ខ្លួន ហើយបន្ទាប់ពីការចាប់ខ្លួនមានហេតុការណ៍អ្វីទៀត?

**ឆ៖** គឺថានេះ គឺជាការបោសសម្អាតលើកទីបី ប្រហែលមួយឆ្នាំក្រោយមក គឺមិនទាក់ទងផ្ទាល់នឹងហេតុការណ៍មុនទេតាមខ្ញុំចាំ។ នេះជាការចាប់ផ្តើមនៃការបោសសម្អាតនូវពួកបញ្ញវន្តនៅក្នុងបក្សមនុស្សដែលមានជាប់ខ្សែជាមួយ កុយ ធួន នៅលីសេស៊ីសុវត្ថិ ហើយមានអ្នកផ្សេងទៀតដែលខ្ញុំមិនបានចាំ។

[០៩:៣៩:៤០]

ការបោសសម្អាតប្រឆាំងនឹងពួកកម្មាភិបាលយោធាពីភូមិភាគបូព៌ាហ្នឹងដល់ឆ្នាំ១៩៧៦-៧៧ គឺជាការប្តូរការបោសសម្អាតទៅលើកម្មាភិបាលនៅក្នុងតំបន់ផ្សេងៗនៅក្នុងប្រទេស ដែលថា គេចាត់ទុកថាជាសមាសភាពអាក្រក់ដែលគណៈមជ្ឈិមមិនបានដឹងច្បាស់ថា អាក្រក់ប៉ុនណាទេ ដែលមុននឹងចាប់ផ្តើមបោសសម្អាតនោះ។ ភូមិភាគឧត្តរជាភូមិភាគដែលមានការលំបាក កុយ ធួន ធ្លាប់បានទទួលបន្ទុកនៅកន្លែងនោះ ហើយនេះអាចជាចំណុចដែលមិនសូវច្បាស់ ដែលថាមិន -- ដោយសារតែចាប់ខ្លួនគាត់។ ប៉ុន្តែគឺគេការចាប់ផ្តើមនៃវាយប្រហារទៅលើការផលិត បង្កបង្កើតផល កន្លែងណាខ្សោយ អាហ្នឹងគេចាត់ទុកជាទិសដៅ រហូតដល់មកដល់ឆ្នាំ១៩៧៧។ ហើយអ្នកដែលជាប់ខ្សែ កុយ ធួន ចាប់ផ្តើមទទួលរងនូវការចាប់ខ្លួន ហើយក៏គេសង្ស័យ ដោយសារគេចាប់ខ្លួន កុយ ធួន។ ហើយថ្នាក់លើរបស់បក្សហ្នឹង គឺទាំងខាងស៊ីវិល ខាងយោធា ក៏ត្រូវបានគេសង្ស័យ និងតាមដានចាប់ខ្លួនបន្ទាប់ពី កុយ ធួន នោះដែរ។ អ៊ីចឹង ការនាំឲ្យមានការបោសសម្អាត កុយ ធួន នេះ គឺចំណុចសំខាន់ គឺថាចម្លើយសារភាពរបស់គាត់ គឺ៨០០ទំព័រ ឯណោះ។ ហើយប្រសិនបើយើងដឹងអ្វីច្បាស់តាម ឌុច នោះ គឺថា ឌុច ទទួលការណែនាំពីថ្នាក់លើ ថាកុំឲ្យធ្វើទារុណកម្មគាត់ ឲ្យសួរចម្លើយគាត់តាមធម្មតា។ នេះជាចំណុចដែលយើងដឹងនោះ។

[០៩:៤១:២៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ លោកបានយោងទៅរកការចាប់ខ្លួនមនុស្សដែលជាប់ខ្សែ កុយ ធួន។ ខ្ញុំចង់យោងទៅរកសេចក្តីដកស្រង់ពីរនៅក្នុងសៀវភៅ "សំឡេងចេញពី ស-២១" ដែលទាក់ទងទៅនឹងមនុស្សម្នាក់ក្នុងចំណោមនោះ ដើម្បីកត់ត្រា គឺឯកសារ D108/50/1.1.6។ ខ្មែរ ERN 00191900, អង់គ្លេស ERN 00192742 រហូតដល់ 43, បារាំង ERN 00357321 រហូតដល់ 22។ លោកសាស្ត្រាចារ្យ ខ្ញុំគិតថា លោកអាចរកចំណុចនេះបាន។ សេចក្តីដកស្រង់ពីរដែលពាក់ព័ន្ធទៅនឹងគំនិតនេះដែលយើងបានពិភាក្សានេះ។ សូមដកស្រង់៖ "ពីរសប្តាហ៍ក្រោយពីចាប់ខ្លួន កុយ ធួយ គេបាននាំ ឌឿន មក ស-២១។ ឌឿន បានធ្វើការជិតស្និទ្ធជាមួយ ឌឿន(ស៊ីក) នៅក្នុងសម័យសង្គ្រាមស៊ីវិល ហើយបានជំនួស កុយ ធួយ ជាលេខាពាណិជ្ជកម្ម។ នៅក្នុងឆ្នាំ១៩៧៥ គាត់ក្លាយជាកម្មាភិបាលរដ្ឋខាងរដ្ឋបាលមន្ត្រី៨៧០ របស់បក្សកុម្មុយនីស្តកម្ពុជា"។ នៅក្នុងផ្នែកបន្ទាប់ទៀត ដែលទាក់ទងទៅនឹង -- សូមដកស្រង់៖ "អ្នកទោសដែលចាប់ខ្លួនរហូតមកដល់ពេលនេះ មានការលើកលែង ដែលថា ណៃ សារ៉ាន់។

ឌឿន គឺជាមនុស្សដែលនៅកៀកនឹងមជ្ឈិម។ តំណែងរបស់គាត់សំខាន់នៅក្នុងមន្ទីរ៨៧០ គឺបញ្ជាក់ដោយអង្គហេតុថា ខៀវ សំផន ជាអ្នកមកជំនួសគាត់។ គឺជាប្រធាន គណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ដែលថា ខៀវ សំផន បានដើរតួសំខាន់ នៅពេលដែល ឌឿន ធ្លាក់ -- ឌឿន ត្រូវបានគេចាប់ខ្លួន”។

[០៩:៤៣:៥១]

ពិនិត្យមើលសេចក្ដីដកស្រង់នេះ។ ខ្ញុំមិនចង់ឲ្យលោកធ្វើការសន្និដ្ឋាន ឬក៏លោកយោងទៅរកភស្ដុតាងដ៏សំខាន់ទាក់ទង ខៀវ សំផន ទេ។ ប៉ុន្តែថាតើលោកយល់ថា ឌឿន មានឋានៈខ្ពស់ដូចម្ដេច? ថាតើលោកអាចពន្យល់ដោយសង្ខេបទាក់ទងទៅនឹងហេតុការណ៍នេះ អំពីខ្លឹមសារដកស្រង់ ដែលថាសារៈសំខាន់របស់ ឌឿន នៅក្នុងមន្ទីរ៨៧០ហ្នឹង គឺថា គឺបញ្ជាក់ថា អ្នកមកជំនួសគាត់គឺជាមនុស្សសំខាន់ដែរ ដូចជា ខៀវ សំផង នេះ តើលោកអាចដឹងដោយរបៀបណាចំណុចនេះនោះ?

**ឆ៖** បើសិនជាខ្ញុំចង់អាចសរសេរនេះឡើងវិញ ខ្ញុំនឹងកែ។ សារៈសំខាន់មន្ទីរ៨៧០ ហ្នឹង គឺថាសំខាន់ដោយសារតែគេដក ឌឿន ចេញទៅ គេដាក់មនុស្សសំខាន់ទៅជំនួស។ ដូច្នេះ គឺថា -- នោះគឺជាមន្ទីរដ៏ -- មូលដ្ឋានដ៏សំខាន់ ប៉ុន្តែវាមានចំណុច គឺថាអាចធ្វើឲ្យច្រឡំជាមួយនឹងតួនាទីឈ្មោះលេខកូដរបស់ ប៉ុល ពត ដែរ។ ពេលខ្លះមន្ទីរហ្នឹងគេយោងទៅរក ប៉ុល ពត។ គឺថានេះគឺសំដៅទៅរកមន្ទីរដែលមនុស្សកំពូលៗនៅក្នុងបក្សធ្វើការនៅកន្លែងនេះ។ សំណួរនេះគប្បីតែរៀបរាប់ឡើងវិញគឺថា មុនពេលដែលថាមន្ទីរនេះគឺថា -- ហើយគេកំណត់នៅក្នុងមន្ទីរនេះ ហើយគេចាត់តាំងចេញបញ្ជា ហើយគឺជា -- ដូចជាប្រមុខរដ្ឋនៅកន្លែងហ្នឹងគឺថា កាន់អំណាចនៅកន្លែងហ្នឹង ហើយបញ្ជាទៅតំបន់ផ្សេងៗ។ ហើយខ្ញុំមិនបានត្រៀមខ្លួនដើម្បីនិយាយអំពីអ្វីដែលខ្ញុំត្រូវស្រាវជ្រាវនោះទេ។ ហើយខ្ញុំឃើញថាលទ្ធភាពដែលនឹង -- ខ្ញុំមិនអាចនិយាយបានច្បាស់ឲ្យកត់ត្រាតុលាការថ្ងៃនេះទេ ដូច្នេះមន្ទីរ៨៧០ គឺជាៗមន្ទីរសរសៃឈាមដ៏សំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា។ ក៏វាអាចធ្វើឲ្យច្រឡំមន្ទីរមជ្ឈិម អចិន្ត្រៃយ៍ក-១ អង្គការលើនោះគឺថានេះគឺជាពាក្យ ៗដែលគេយោងទៅរកក្រុមមនុស្សមួយចំនួនតូចនៅថ្នាក់លើនោះឯង។

[០៩:៤៦:២៣]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ ពិនិត្យមើលការចាប់ខ្លួនមួយទៀតដែលលោកបានពិភាក្សាលម្អិតដែរនៅក្នុងសៀវភៅនិយាយពី “សំឡេងពីស-២១” នោះ។ លោកបានពិនិត្យមើលការប្រព្រឹត្តទៅលើ ហ៊ូ នឹម ហៅ ភ័ស ដែលជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការរបស់កម្ពុជាប្រជាធិបតេយ្យ។

នេះជាចំណុចដែលលោកបានលើកឡើងនៅក្នុងអត្ថបទខ្មែរ ERN 00191900, អង់គ្លេស ERN 00192743 ហើយបារាំង ERN 00357332។ ដកស្រង់ "ចម្លើយសារភាពរបស់ កុយ ធួន ក៏បញ្ជាក់ឈ្មោះ កុយ នឹម (ស៊ីក) ហៅ ភ័ស ដែរ។ គឺជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ហើយជាអ្នករួមការងារជាមួយ ខៀវ សំផន ដែលត្រូវបានគេចាប់ខ្លួន ហ៊ូ នឹម នោះហើយ។ ហើយនៅក្នុងកំពង់ចាម ហ៊ូ នឹម គឺមានតំណែងដូចគ្នាជាមួយ ខៀវ សំផន ជាមួយ សាឡុត ស ហើយនៅសាលាមួយនៅក្នុងខេត្តកំពង់ចាម។

ជាបឋម តើលោកអាចរៀបរាប់ប្រាប់តុលាការដែលថាតួនាទីដែលថា ហ៊ូ នឹម ដើរតួអ្វីដែលថាជាន់គ្នា ខៀវ សំផន នោះៗនៅក្នុងបក្ស? ថាតើមានសារៈសំខាន់អ្វីដែលថាអាចឲ្យមានការចាប់ខ្លួនអ្នកផ្សេងទៀតដែលជាប់ខ្សែគាត់ក្រោយពីគេចាប់ខ្លួនគាត់ហើយនោះ?

[០៩:៤៨:១២]

**ឆ៖** ដើម្បីរំឭកឡើងវិញ ហ៊ូ នឹម គឺៗជាមនុស្សបីនាក់ក្នុងចំណោមដែលគេហៅថា "ខ្មោចបីនាក់" នោះ ដែលថាជាអ្នកដឹកនាំរណសិរ្សរបស់សម្តេច សីហនុ នោះ។ ដែល ហ៊ូ យន់ ក៏គេចាត់ -- ក៏គេថាបានស្លាប់ហើយ ហើយមួយទៀត ខៀវ សំផន។ ខ្មោចទាំងបីនេះគឺថា នៅក្នុងរឿងអតីតកាលមិនទាក់ទងទៅរឿងចាប់ខ្លួននោះទេ។ ហើយចម្លើយសារភាពបានសរសេរក្នុងជីវិតរបស់គាត់ គាត់មិនបានបន្ទោសទៅលើអ្នកផ្សេងនោះទេ។ ដោយជាក់ស្តែងគឺថា វាមានការពាក់ព័ន្ធទៅនឹងអ្នកមួយចំនួនដែលគេចាប់យកមកស-២១ ដោយមានការឆ្លើយដាក់ គេបន្ទោសគាត់អំពីស្ថានភាពនៅក្នុងភូមិភាគពាយ័ព្យដែលថា -- ហើយនិងកម្មាភិបាលដែលមិនស្ថិតនៅក្នុងតំបន់នោះ ដែលជាពិសេសពួកប្រជាជនថ្មីនៅក្នុងតំបន់នោះ។ គឺថាដោយសារស្ថានភាពមិនបានល្អទេនៅក្នុងភូមិភាគពាយ័ព្យនោះ។ ដូច្នេះ នេះគឺជាបញ្ញវន្តដែលថា ខ្ពស់ជាង កុយ ធួន ដែលថា ហ៊ូ នឹម នេះគឺថាជាមនុស្សនៅក្នុងបក្សដែលគេក្លាយទៅជាទិសដៅរបស់បក្សកុម្មុយនីស្តកម្ពុជានោះ។

[០៩:៤៩:៤៥]

ហើយនៅក្នុងឆ្នាំ១៩៦០ ហ្នឹង ពាក់ព័ន្ធនឹងចលនាម៉ៅនិយម ហើយគាត់បានគេចខ្លួនទៅជនបទជាមួយ ខៀវ សំផន នៅក្នុងឆ្នាំ១៩៦៧ ហើយសម្តេច សីហនុ បានតាមដានគាត់ ហើយចាត់ទុកថាជាខ្មាំង។ នេះហើយគឺជាប្រវត្តិទាក់ទងទៅនឹងពួកគាត់ ជាមូលហេតុដែលថាចម្លើយសារភាពរបស់គាត់នោះ ចន្ទ ប៊ូ, ប៉ែន យៀវនិន បានរកឃើញមុនដែលយើងសរសេរសៀវភៅ ហើយយើងបានដឹងពីគាត់ -

- រឿងរ៉ាវពីគាត់ពីមុន ដែលថាជាតួអង្គសំខាន់ក្នុងខ្មែរក្រហម ដែលគេហៅថា "រឿងរបស់ខ្មោចទាំងបី" ដែលគេចោទគាត់។ នៅក្នុងភាសាអង់គ្លេស គឺថាយើងមានចម្លើយសារភាពមួយចំនួន មានបោះពុម្ពផ្សាយជាភាសាអង់គ្លេសផងដែរ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ។ ពិនិត្យមើលក្រុមមនុស្សមួយក្រុមទៀត ដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក គឺជាក្រុមជនរងគ្រោះ។ នេះគឺនៅក្នុងសៀវភៅ "សំឡេងពី ស-២១" ខ្មែរ ERN 00191897 ដល់ 8, អង់គ្លេស ERN 00192739 រហូតដល់ 40, បារាំង ERN 00357328។ ផ្នែកពិសេសនេះ គឺថានិយាយអំពីការបោសសម្អាតបញ្ញវន្ត ហើយនិងអ្នកការទូត។ ខ្ញុំនឹងផ្តោះសេចក្តីដកស្រង់មួយចំនួនខ្លះ ហើយនិងទៅយកតែពិនិត្យមើល ដែលលោកនិយាយអំពីការប្រារព្ធពិធីផែនការបួនឆ្នាំ ហើយនិងការវាយប្រហារជាមួយវៀតណាមឆ្នាំ១៩៧៧ ផ្នែកដែលខ្ញុំចង់អានជូនលោក ហើយនិងសួរលោកនោះគឺដូចខាងក្រោមនេះ។

[០៩:៥២:០១]

"ក្នុងពេលដែលកម្ពុជាប្រជាធិបតេយ្យត្រៀមខ្លួន ដើម្បីធ្វើសង្គ្រាមបក្សកុម្មុយនីស្តកម្ពុជាក៏បានកម្ទេចអ្នកការទូតរបស់ខ្លួន ហើយនិងបញ្ញវន្តដែលអ្នកកាន់ជើងខាងវៀតណាម និងវៀតណាមផងដែរ។ ជនរងគ្រោះសំខាន់ៗដូចជា ឯកអគ្គរដ្ឋទូតប្រចាំប្រទេសវៀតណាម ដូចជា ហាក់សៀង ឡាយនី គឺអតីតមន្ត្រីការបរទេស ដែលត្រូវបានចោទប្រកាន់ថា បានបង្កើតបក្សកុម្មុយនីស្តទៀតនៅក្នុងឆ្នាំ១៩៦០។ អ្នកការទូតផ្សេងៗទៀត ក៏ត្រូវបានប្រមូលមកចាប់ខ្លួន -- ប្រមូលផ្តុំ។ នេះជាវិធានការផ្ទុះបញ្ចាំងពីការមិនទុកចិត្តបក្សចំពោះអ្នកដែលមានការហ្វឹកហាត់ រហូតដល់អ្នកដែលមានការបណ្តុះបណ្តាល ហើយនិងអ្នកដែលរស់នៅឯបរទេស ដែលមិនមែនជាខ្មែរនោះ។" តើលោកអាចពន្យល់ជូនតុលាការបន្ថែមទេ អំពីផលវិបាកនៃការបោសសម្អាតអ្នកដែលគាំទ្រវៀតណាម គាំទ្រសូវៀត ដោយសារទាក់ទងទៅនឹងគណៈខាងការទូត ហើយនិងអ្នកដែលធ្វើការនៅក្រសួងការបរទេសនោះ?

**ឆ៖** របបនេះមិនបានទុកចិត្តនរណាម្នាក់គ្រប់ៗគ្នាទេ ហើយគេតាមដានសកម្មភាព ជាពិសេសអ្នកដែលរស់នៅបរទេសភាគច្រើននោះ គេជ្រើសរើសឲ្យធ្វើការទូតនោះ គឺតាមនិយមន័យ គឺនៅបរទេស ហើយមានបទពិសោធន៍នៅកន្លែងផ្សេងៗទៀតដែរអ្នកទាំងនោះ។ ហើយខ្ញុំមិនច្បាស់ថា ការបោសសម្អាតនេះ -- ដោយសារថា គណៈការទូតនោះវាតូចនោះទេ។ ប៉ុន្តែនៅភូមិភាគពាយ័ព្យ ឬក៏នៅភូមិភាគបូព៌ា នៅសម័យកាលនោះក៏មានការបោសសម្អាត។ ខ្មែរក្រហមចង់ឲ្យច្បាស់ខ្លួនឯងថា នៅក្នុង

ឆ្នាំ១៩៧៧, ៧៨ ដែលមានការផ្ទុះអាវុធជាមួយវៀតណាមនោះ គឺថាអ្នកណា -- មនុស្សមួយចំនួនដែលនៅប្រទេសបរទេសក្រៅ នៅកូរ៉េខាងជើង វៀតណាម ឡាវ ជាដើមហ្នឹង គឺគេៗដកទូតចេញមកវៀតណាម ហើយក៏បញ្ជូនមកស-២១។

[០៩:៥៤:២៥]

មនុស្សដែលនៅប្រទេសឡាវ គឺថា ដក -- នៅនៅឡើយ ហើយអ្នកទូតមកពីចិន ក៏មិនទាន់បានដកមកវិញទេ។ អនុញ្ញាតឲ្យធ្វើការនៅក្នុងប-១ ដោយសារគេមានបទពិសោធន៍ ដោយសារថាមានការសង្ស័យក៏ដោយ ប៉ុន្តែគេឲ្យទុកនៅប-១ សិន។

**ស៖** ហើយទាក់ទងទៅនឹងប-១ ទាក់ទងទៅនឹងក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ តើលោកអាចផ្តល់យោបល់អំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាថា តើគេមានអំណាចអ្វីខ្លះ ទៅលើស្ថាប័នណាមួយដែលមានអំណាច ដែលចេញនូវសេចក្តីសម្រេចឲ្យមានការចាប់ខ្លួនបែបនោះ?

[០៩:៥៥:១៥]

**ឆ៖** មិនមានៗភស្តុតាងច្បាស់លាស់នៅកម្ពុជា អំពីបញ្ហានេះទេ។ អ្នកការទូតត្រូវបានគេចាប់ខ្លួន គឺយកមកពីបេសកកម្មការទូត ហើយពេលខ្លះគេបញ្ជូនមកប-១ ហើយក៏មានការយល់ព្រម ហើយលោក អៀង សារី ក៏បានដឹងពីរឿងហ្នឹង ដោយសារគាត់ជារដ្ឋមន្ត្រី។ ហើយគឺថា មានអ្នកចាប់ខ្លួនមកចាប់ខ្លួននៅក្នុងក្រសួងរបស់គាត់ ហើយៗអ្នកទាំងនោះគឺក្រសួងទុកចិត្ត ហើយលោក -- មន្ត្រី រដ្ឋមន្ត្រីហ្នឹងគាត់ធ្វើការកន្លែងហ្នឹង គាត់ដឹងគឺថា គឺក្រោយពេលមុនពេលចាប់ខ្លួនគេបញ្ជូនព័ត៌មានទៅគាត់ ហើយចាប់ខ្លួន ហើយក៏មានកិច្ចការអីគេចម្លងជូន។ ដូច្នេះការដឹងរបស់គាត់នោះ គឺថាគាត់មិនអាចបដិសេធថា គាត់មិនដឹងទេ។ អ៊ីចឹងហើយ យើងនិយាយគឺថា មនុស្សនៅថ្នាក់លើ មនុស្សកំពូលនោះមានតែគាត់ គឺថាហើយសេចក្តីសម្រេចសមូហភាពហ្នឹង គឺមានគ្រប់ពេលទាំងអស់ ហើយយើងមិនអាចបញ្ជាក់ថា អ្នកណាជាឯកភាពដល់ការចាប់ខ្លួននោះទេ ប៉ុន្តែយើងអាចនិយាយបានថា លោក អៀង សារី គាត់បានដឹងពីការចាប់ខ្លួននេះ។ ហើយយើងមិនអាចនិយាយបានថា កុំចាប់អ្នកហ្នឹងទេ កុំធ្វើអ៊ីចឹង គឺមិន -- បាទនេះជាអ្វីដែលខ្ញុំអាចជម្រាបបានគឺប៉ុណ្ណឹង។

**ស៖** យើងត្រឡប់ទៅ--

**ប្រធានអង្គជំនុំ៖**

សូមៗលោកអ្នកជំនាញ សូមនិយាយឲ្យបានយឺតជាងនេះបន្តិច លឿនពេកៗអ្នកបកប្រែបកអត់

ទាន់ទេបាទ។ សូមអញ្ជើញបន្ត លោកសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

[០៩:៥៧:២៦]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកទៅរកសេចក្តីសម្រេចសម្ងហភាព ទំនាក់ទំនងរវាងប្រធានមន្ទីរក្រសួងផ្សេងៗនៅក្នុងសម័យកាលនោះ។ ផ្អែកតាមការសិក្សារបស់លោក ស្រាវជ្រាវរបស់លោកនោះ ថាតើៗមានប្រព័ន្ធអ្វីជាគំរូ ដែលថាធ្វើសេចក្តីសម្រេចទាក់ទងទៅនឹងការចាប់ខ្លួន ជាពិសេសដើម្បីចាប់ខ្លួនអ្នកណាម្នាក់ចេញពីក្រសួងណាមួយ គេមានសេចក្តីសម្រេច ហើយរូបមន្តគំរូរបស់គេហ្នឹងបែបណា? តើលោករកឃើញបែបណាដែរ?

**លោក ផេរីង ផេនន៍ល័រ៖**

**ឆ៖** បញ្ហានេះ យើងមិនមានព័ត៌មានណាមួយទេ។

**ស៖** សូមអរគុណលោកដែលលោកបានឆ្លើយខ្លី។ ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត និយាយដោយសង្ខេបទេ ហើយខ្ញុំមិនយោងទៅរកខ្លឹមសារដកស្រង់ច្រើនពេកទេ ចំណុចនេះ។ យើងបាននិយាយយោងពីខាងដើមទៅរកការពិភាក្សា អំពីៗការវាយរបស់កម្ពុជាប្រជាធិបតេយ្យទៅក្នុងប្រទេសវៀតណាម ខាងផ្លូវយោធាការវាយលុកលុយ។ នៅក្នុងសៀវភៅ "សំឡេងពីស-២១" នោះក៏លោកបាននិយាយការផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសនោះដែរ នៅក្នុងខែមករា ឆ្នាំ ១៩៧៨។ ថាតើការស្ថានភាពដែលដុនដាបនេះគឺថា វាមានផលប៉ះពាល់ ទៅនឹងនយោបាយទាក់ទងទៅនឹងខ្មាំងរបស់បក្សដែរឬទេ? សៀវភៅនិយាយពី "សំឡេងចេញពីស-២១" ហ្នឹង ខ្មែរ ERN 00191910, អង់គ្លេស ERN 00192751, បារាំង ERN 00357341។

[០៩:៥៩:៥៧]

នេះជាចំណុច ដែលលោកបាននិយាយនៅក្នុងសៀវភៅនោះ "នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខ្មាំងដែលជាទិសដៅរបស់បក្សនោះគឺជាពួកអ្នកដែលមានក្បាលយួនខ្លួនខ្មែរ។ ហើយនៅក្នុង ស-២១ ជាពិសេស គឺមានអ្នកទោសជាច្រើន គឺត្រូវគេបង្ខំឲ្យគោរពថ្វាយបង្គំរូបក្បាលឆ្កែ ឬក៏ដែលមានក្បាលហូជីមិញ រូបឆ្កែនោះ។ ថាតើលោកអាចដកការសន្និដ្ឋាន ឬក៏សេចក្តីវិភាគដូចម្តេចដែលថាគេហៅខ្មាំង

ថាមនុស្សដែលមានក្បាលយួន ខ្លួនខ្មែរ ហើយគេឲ្យថ្វាយបង្គំរូបគំនូរដែលមានក្បាលហូជីមិញនោះ?

**ឆ៖** នៅពាក់កណ្ដាលឆ្នាំ១៩៧៨ កម្ពុជាបានដឹងពីការវាយលុកលុយ ហើយទាក់ទងទៅនឹងសង្គ្រាមវៀតណាម គឺថាការវាយលុកលុយដែលប្រទេសផ្សេងទៀតគេទទួលស្គាល់នូវខែវិច្ឆិកា -- ធ្នូ ឆ្នាំ១៩៧៧ ហើយគេមើលឃើញចំណុចពីរ។ មួយគឺចេតនា គេចង់ប្ដូរទៅកម្រិតមួយដើម្បីបោសសម្អាតបក្សនៅក្នុងភូមិភាគបស្ចិម នៅក្នុងការបោសសម្អាតពីមុន។ ប៉ុន្តែគេបានប្ដូរការយកចិត្តទុកដាក់ទៅលើអ្នកដែលជាជនជាតិវៀតណាម ជនជាតិភាគតិចវៀតណាម ដែលថា គឺថាគេទទួលការបរាជ័យដោយសំខាន់ ដែលថាគេវ៉ៃដេញទៅដេញមកព្រំដែន ពេលមួយនោះគឺខ្មែរក្រហមត្រូវបានវៀតណាមវាយបណ្ដេញចូលមកប្រទេសវិញ។ ហើយក៏គេចាត់ទុកថា ខ្ញុំមិនបញ្ជាក់ -- គេមិនបាននិយាយសាធារណៈទេ គឺថាគេបានវាយឆ្លងព្រំដែនទៅវៀតណាម ឆ្នាំ១៩៧៧ ហើយដែលអាចជាកាយវិការបង្កហេតុឲ្យមានសង្គ្រាមនោះ។ ហើយការវាយប្រហារនោះ គឺថារបបនោះបានចាប់ផ្ដើមនៅឆ្នាំ១៩៧៨ គឺថាវាមានការច្បាំងរុញគ្នាទៅវិញទៅមកនៅតាមព្រំដែន។ ហើយនេះគឺជាការបើកចំហ ហើយនិងការវាយបំបែកនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារមានសង្គ្រាមហ្នឹង។ សង្គ្រាមជាមួយវៀតណាម ដែលធ្វើឲ្យរបបនេះធ្លាក់ចុះ។ ហើយជាការបង្កហេតុឲ្យមានការភ័យខ្លាច និងការយកចិត្តទុកដាក់ឲ្យមានការបោសសម្អាតកាន់តែខ្លាំងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

[១០:០២:៥២]

**ស៖** សូមអរគុណ។ មុនពេលដែលយើងចូលទៅលើបញ្ហាបោសសម្អាតនេះ និងបង្ហាញដែលលោកបានលើកពីខាងដើម ជាពិសេសការប៉ះពាល់ទៅដល់ភូមិភាគបូព៌ានោះ ខ្ញុំសូមឲ្យលោក -- ខ្ញុំចង់ពិចារណាបន្តិចបន្តួចថាតើសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់របបនោះ នៅក្នុងឆ្នាំ អំឡុងឆ្នាំ៧៧ នោះ មានពាក់ព័ន្ធទៅនឹងគោលបំណងនៃការរៀបរាប់ និងពិភាក្សាទៅលើបញ្ហាខ្លាំងដែរឬទេ? ឯកសារដែលខ្ញុំមានបំណងចង់បង្ហាញជូនលោកគឺ ឯកសារលេខ E3/201 គឺជាសុន្ទរកថារំឭកខួបធ្វើឡើងដោយលោក ខៀវ សំផន នៅថ្ងៃទី១៥ ខែមេសា ៧៧។ ERN ជាភាសាខ្មែរពាក់ព័ន្ធគឺ 00292805, អង់គ្លេស ERN គឺ 00419513។ យើងខ្ញុំនឹងបញ្ជូនឯកសារនេះជាក្រដាសជូនលោកសាស្ត្រាចារ្យ។ បារាំងមានលេខ ERN 00612116 -- 166 សូមកែតម្រូវ។ ការដកស្រង់សម្ដីចេញពីសុន្ទរកថានេះមានដូចតទៅ សូមដកស្រង់សម្ដី៖ “ទោះបីយ៉ាងណាក៏ដោយ” ខ្ញុំសូមឲ្យដាក់ភាសាខ្មែរលើអេក្រង់ផង មុនពេលដែលខ្ញុំអាន។ “ក៏ប៉ុន្តែយើងត្រូវតែបន្តភារកិច្ចការពារកម្ពុជាប្រជាធិបតេយ្យរបស់យើង។ ការពាររដ្ឋបាល

កម្មករ កសិកររបស់យើង រក្សាការពារសមិទ្ធផលបដិវត្តន៍កម្ពុជារបស់យើង តាមរយៈការទប់ស្កាត់ជាដាច់ខាតនូវសត្រូវទាំងអស់។ រារាំងពួកវាពីការឈ្លានពាន ពីការជ្រៀតជ្រែក ឬការធ្វើវិទ្ធង្សនាប្រឆាំងនឹងយើង។ យើងត្រូវបោសសម្អាតសត្រូវក្នុង។ សមត្ថភាពយើងជាម្ចាស់ការលើស្ថានភាព ដើរតាមមាគ៌ានយោបាយក្នុងស្រុក គោលនយោបាយបរទេស និងគោលនយោបាយយោធារបស់អង្គការបដិវត្តន៍របស់យើង។ ត្រូវធ្វើអ្វីៗគ្រប់យ៉ាងឲ្យបានល្អប្រណិត និងគ្រប់ជ្រុងជ្រោយ។ យើងមិនត្រូវមានចិត្តរាយមាយ ធ្វេសប្រហែស ឬភ្លេចភ្លាំងដោយសារជោគជ័យអតីតកាលទេ"។ ខ្ញុំឈប់ត្រឹមនេះ។ ហេតុផលដែលខ្ញុំលើកអត្ថបទនេះឡើង ដោយសារតែវាជាសេចក្តីថ្លែងការណ៍ជាសាធារណៈ។ ខ្ញុំមានបំណងស្នើសុំឲ្យលោកផ្តល់យោបល់ជំនាញថា តើខ្លឹមសារទាំងអស់នេះនៅក្នុងចំណុចដែលខ្ញុំដកស្រង់នេះ វាបានឆ្លុះបញ្ចាំងបង្ហាញអំពីគោលនយោបាយរបស់បក្ស ដែលយើងបានពិភាក្សាពីមុនៗដែរឬទេ?

**ឆ៖** ខ្ញុំគិតថាអត្ថបទនេះ គឺវាបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវទៅលើគោលនយោបាយរបស់បក្សដែលវារៀបរាប់ឡើងវិញតាមឃ្លោងឃ្លានោះ ហើយដែលយើងឃ្លោងឃ្លាទាំងអស់នោះ ដូចយើងបានស្តាប់សក្ខីកម្មរបស់យើងរយៈពេលបីថ្ងៃចុងក្រោយនេះរួចមកហើយ។

[១០:០៦:១៤]

**ស៖** ខ្ញុំសូមអរគុណ ដែលលោកបានឆ្លើយខ្លីៗដូច្នេះ។ លោកបាននិយាយអំពីការបោសសម្អាតនៅខាងឧត្តរ និងខាងពាយ័ព្យ ក៏ប៉ុន្តែយើងក៏មិនមានពេលគ្រប់គ្រាន់សួរលម្អិតទៅលើចំណុចនេះនោះទេ។ អ្វីដែលខ្ញុំចង់ចោទសួរលោកនោះគឺ អ្វីដែលលោកបានរៀបរាប់នៅខាងភូមិភាគបូព៌ា។ លោកបាននិយាយទៅលើបញ្ហាការបោសសម្អាតនៅភូមិភាគបូព៌ាបន្តិចរួចមកហើយ។ ក៏ប៉ុន្តែចំណុចមួយដែលខ្ញុំចង់ឲ្យលោកធ្វើការពន្យល់បន្ថែម ជាពិសេសគឺត្រង់ចំណុចដែលលោកនិយាយអំពីចំណុចសំខាន់នៃការបោសសម្អាតនៅខាងភូមិភាគបូព៌ានោះ។ ខ្ញុំនឹងអានអត្ថបទមួយចេញពី "សំឡេងពីមន្ទីរស-២១" ហើយឲ្យលោកពន្យល់បន្ថែមថា តើការបោសសម្អាតនោះ វាមានន័យយ៉ាងម៉េច? ខ្មែរ ERN ជាភាសាខ្មែរ គឺ 00191910 ទៅដល់ 00191913, អង់គ្លេសគឺ 00192752 ទៅដល់ 53, បារាំង ERN គឺ 00357341 ទៅដល់ 42។ វាជាផ្នែកអត្ថបទមួយវែង ក៏ប៉ុន្តែខ្ញុំដកស្រង់ចំណុចដែលសំខាន់តែប៉ុណ្ណោះចេញពីសៀវភៅចំណងជើង "សំឡេងមន្ទីរស-២១"នេះ។

[១០:០៧:៤៧]

ដំបូងលោកបានសរសេរអំពីការចាប់ខ្លួន ជូ ជេត នៅភូមិភាគបស្ចិម ហើយបន្ទាប់មក ហើយ

ការចាប់ខ្លួន សោ ភឹម។ អត្ថបទបន្ទាប់ពីចំណុចនេះនោះគឺមានដូចតទៅ៖ “មជ្ឈិមធ្វើការបោសសម្អាតភូមិភាគ -- កម្មាភិបាលភូមិភាគបូព៌ានៅក្នុងខែមេសា ឆ្នាំ៧៨ មានបុគ្គលមួយចំនួនត្រូវបានដឹកតាមឡានមកចូលស-២១។ អ្នកទោសទាំងអស់នោះ គឺត្រូវបានគេយកមកសម្លាប់ចោល ហើយដោយមិនមានការសួរចម្លើយ។ ការបោសសម្អាតធ្វើឡើងដោយមន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាដឹកនាំដោយ សុន សេន និងអ្នកកម្មាភិបាលគាំទ្រមកពីខាងនិរតី”។

លោកសាស្ត្រាចារ្យ លោកបាននិយាយរួចមកហើយ ពាក់ព័ន្ធនឹងការសង្ស័យទៅលើកម្មាភិបាលក្នុងបក្សនៅក្នុងឆ្នាំ១៩៧៦ ជាពិសេសកម្មាភិបាលនៅភូមិភាគបូព៌ា។ ដូច្នេះតើលោកអាចពន្យល់បន្ថែមទៅលើការសន្និដ្ឋានរបស់លោកដែរឬទេ ថាហេតុអ្វីបានជានាំទៅដល់មានការបោសសម្អាតដូច្នេះ?

[១០:០៩:០២]

**ឆ៖** ខ្ញុំគិតថាអ្វីដែល--

**ប្រធានអង្គជំនុំ៖**

សូមសាក្សី -- អ្នកជំនាញកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម សួស្តីសហភាតា ព្រះរាជ-អាជ្ញា អស់លោកទាំងអស់គ្នា។ ហើយសូមអភ័យទោស ហើយអធ្យាស្រ័យផងដោយសារឡើងមករំខាន។ ខ្ញុំមិនចង់ទេ ប៉ុន្តែគេចមិនបាន។

ហើយមានចំណុចពីរ។ ទីមួយ ឃើញព្រះរាជអាជ្ញាលើកយកចម្លើយសារភាពនៅស-២១ ច្រើនណាស់មកឲ្យលោកសាស្ត្រាចារ្យវិភាគ។ ខ្ញុំថា -- ខ្ញុំគិតថាចម្លើយទាំងអស់នេះ យើងដឹងហើយថាគឺសុទ្ធតែចម្លើយបានមកពីការបង្ខិតបង្ខំជាចម្លើយដែលមិនពិតប្រាកដ។ ហេតុអីឲ្យលោកសាស្ត្រាចារ្យវិភាគច្រើន។ ហើយទីពីរ ចំណុចទីពីរ ខ្ញុំឃើញថា កន្លងមកនេះលោកសាស្ត្រាចារ្យបានចាប់ផ្តើមនៅកណ្តាលទី ឬនៅចុងច្រើនណាស់ ដែលលោកចាប់ផ្តើមពាក្យថា “*អាយស៊ីង*” អង់គ្លេសនិយាយអ៊ីចឹង។ បានន័យថា ពាក្យថា “ខ្ញុំគិត”។ អានេះពាក្យថា -- យើងបានជជែកគ្នាកាលពីម្សិលមិញរួចហើយ។ អ៊ីចឹងខ្ញុំសូមតុលាការមេត្តា -- ហើយណែនាំ ឬបង្គាប់ថា បើសិនជាសាក្សីភ្ជាប់ពាក្យថា “ខ្ញុំគិត” នេះមកវាអាចដោយនឹងពាក្យស្មានមកជាមួយទៅហើយ ឬពាក្យសន្និដ្ឋាន សន្មត។ អ៊ីចឹងតើការចាប់ផ្តើមថ្លែងដោយ

ពាក្យថា "ខ្ញុំគិត" នេះតើលោកសាក្សីគួរតែបញ្ចប់ ឬមិនបាច់ឆ្លើយតែម្តងទៅ ពីព្រោះថាជាចម្លើយដែលគាត់គិតស្មានដោយខ្លួនឯង។ សូមអរគុណលោកប្រធាន។

[១០:១០:៥១]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមិនយល់អំពីមូលដ្ឋាននៃការជំទាស់របស់ខាងមេធាវីការពារក្តីនេះ។ ខ្ញុំបានសួរទៅលើអ្នកជំនាញ ទៅលើខ្លឹមសារនៃឯកសារ ហើយអ្នកជំនាញក៏បានទទួលការណែនាំពីចៅក្រមខាតវ៉ាយធ៍ ពីថ្ងៃពុធ ផងដែរ ដែលថាយើងមិនអាចយោងទៅលើចម្លើយសារភាពនោះទេ។ យើងក៏បានត្រៀមទៅលើចំណុចនេះផងដែរ នៅពេលដែលយើងកោះហៅអ្នកជំនាញនេះ គឺយើងឲ្យគាត់ផ្តល់មតិយោបល់ជំនាញរបស់គាត់។ នៅពេលដែលផ្តល់មតិជំនាញនេះ គឺគាត់គិតពិចារណា។ នេះគឺជាអ្វីដែលគាត់បានឆ្លើយ និងធ្វើដូច្នេះ។ ហើយវាមិនមែនជាការសមរម្យទេនៅពេលដែលយើងថា កុំឲ្យគាត់ប្រើពាក្យថា "ខ្ញុំគិត" តាមការងារស្រាវជ្រាវរបស់គាត់ដែលគាត់បានធ្វើកន្លងមកនោះ។

[១០:១១:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីជាតិការពារក្តីឲ្យលោក អៀង សារី គ្មានប្រសិទ្ធភាព។ ការតាំងសំណួររបស់តំណាងសហព្រះរាជអាជ្ញា គឺប្រព្រឹត្តទៅត្រឹមត្រូវហើយ។ ហើយចំណែកឯពាក្យពេចន៍ដែលលោកសាស្ត្រាចារ្យ ដេវីដ ឆេនឌ័ល័រ បានបង្ហាញនេះ គឺគាត់មានសិទ្ធិបង្ហាញពីការយល់ឃើញរបស់គាត់ក្នុងនាមគាត់ជាអ្នកជំនាញ។ អង្គជំនុំជម្រះបានធ្វើការកាត់មិនឲ្យមានការបង្ហាញនូវអត្តនោម័តិរបស់ខ្លួនចំពោះសាក្សី។ សាក្សីមិនអាចធ្វើដូចជាអ្នកជំនាញទេ អ៊ីចឹងហើយបានជានៅក្នុងផ្លូវច្បាប់គេបែងចែកសញ្ញាណពីរហ្នឹងដាច់ពីគ្នា។ ការចូលរួមក្នុងមានសាក្សី និងការចូលរួមក្នុងអ្នកជំនាញ។ ទំនាក់ទំនងផ្លូវច្បាប់ខុសគ្នា។

សូមអញ្ជើញបន្តលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនឌ័ល័រ នៅពេលដែលយើងចូលទៅដល់ចំណុចចុងក្រោយនៃការ

ពិភាក្សារបស់យើងពាក់ព័ន្ធទៅនឹងមន្ទីរស-២១ និងការអនុវត្តគោលនយោបាយទៅលើខ្មាំងនោះ លោកបាននឹកឃើញហើយថា តាមរយៈសាក្សី និងអ្នកជំនាញ តាមរយៈអង្គភាពអ្នកជំនាញ និង -- គាំពារអ្នកជំនាញ និងសាក្សីនោះ គឺបានឲ្យលោកពិនិត្យមើលឯកសារពី ស-២១ មួយចំនួន ដែលជាពិសេសគឺវាដកចេញមកពីចម្លើយសារភាព និងការធ្វើចំណារ។ ការ -- ចំណារទាំងអស់នោះ គឺវាផ្អែកទៅលើការវិភាគ ហើយបានបញ្ជូនឲ្យលោកពិនិត្យមើល។ ខ្ញុំអនុញ្ញាតចូលទៅលើ -- ពិនិត្យទៅមើលឯកសារទាំងអស់នេះ ជាពិសេសចម្លើយសារភាពបីដំបូង។ ប្រសិនបើយើងអាចចែកជូនលោកសាស្ត្រាចារ្យនោះ ERN -- ឯកសារទាំងបីនេះ គឺ IS5.16 គឺចេញពីចម្លើយរបស់ ឈុត នី។ ឯកសារ D288/6.5/2.47 ឯកសារនេះ គឺពាក់ព័ន្ធទៅនឹង ចាប ម៉ុត។

[១០:១៥:១៧]

ឯកសារមួយទៀត គឺ IS5.41 ដែលមានលេខ E3/1565 ផងដែរ។ ពាក់ព័ន្ធទៅនឹង គន់ គៀន (ស៊ីក) ហៅ ឃុង ប៊ែត(ស៊ីក)។ ដូច្នេះបើសិនជាអនុញ្ញាតនោះ សូមឲ្យយើងយកឯកសារក្រដាសនេះជាភាសា -- ជាឯកសារក្រដាសទៅដល់លោកសាស្ត្រាចារ្យ។

**អ្នកបកប្រែ៖**

លោកប្រធាន សូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ឈ្មោះជាភាសាខ្មែរឡើងវិញដោយសារតែយើងខ្ញុំស្ដាប់មិនបានច្បាប់។

**លោក អាប់ឌុលឡាក់ ថាវីក៖**

យើងខ្ញុំមានឯកសារនេះជាភាសាអង់គ្លេស។ ដូច្នេះហើយយើងខ្ញុំនឹងផ្ដល់ឯកសារជាភាសាអង់គ្លេសទៅដល់លោក។

[១០:១៥:០២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែសូមឲ្យតំណាងសហព្រះរាជអាជ្ញាជាតិបញ្ជាក់ឈ្មោះៗ អ្នកដែលពាក់ព័ន្ធនៅក្នុងឯកសារទាំងបីជាភាសាខ្មែរច្បាស់។ ពីព្រោះការបកប្រែហ្នឹង ស្ដាប់ឈ្មោះខ្មែរហ្នឹងមិនច្បាស់ទេ។ មន្ត្រីរដ្ឋបាលតុលាការ អាចផ្ដល់ឯកសារអំមិញនេះ ឲ្យគាត់ពិនិត្យមើលដើម្បីបញ្ជាក់ពីឈ្មោះបុគ្គលដែលទទួលរងនូវការស្ដាប់ចម្លើយណ៎ា។

**លោក ច័ន្ទ តារាស្មី៖**

បាទ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនឈ្មោះជាខ្មែរបាទ។ ទីមួយ គឺយោងទៅលើសេចក្ដីកំណត់ហេតុអំពីប្រវត្តិរបស់លោក -- គាត់ឈ្មោះ ជួក ញ៉េ។ បាទ ជួក ញ៉េ។ ទីពីរ ខ្ញុំសូមអនុញ្ញាតជម្រាបជូនអំពីចម្លើយរបស់ឈ្មោះ ចាប មុិត។ បាទ។ មុិត សរសេរ។ “ម”-“ិ”-បុកជើង និង “ត” ។ ចាប មុិត បាទ ជាលេខាស្រុកខ្សាច់កណ្ដាល តំបន់២២ បូព៌ា បាទ។ បាទ ទីបី ខ្ញុំសូមអានអំពីឈ្មោះប្រវត្តិសកម្មភាពរបស់ឈ្មោះ គង់ គៀន។ បាទ។ គង់ សរសេរអក្សរ “គ” និង “ង” បន្តក់ ហើយ គៀនសរសេរអក្សរ “គ” ស្រះ “ៀ” ធំ និង “ន” បាទ គង់ គៀន ហៅ អឹង វ៉េត។។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណបាទ។

[១០:១៧:២២]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកសហព្រះរាជអាជ្ញាជាតិ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ តាមឈ្មោះដែលលំដាប់ដោយ ដែលខាងសហព្រះរាជ-អាជ្ញាជាតិបានអានអម្បាញ់មិញនេះ ខ្ញុំសូមឲ្យជំនួយការ -- អង់គ្លេសភាសា ERN គឺ 00185061, ហើយខ្មែរគឺ 0005403 យើងខ្ញុំសូមអនុញ្ញាតដាក់ជាភាសាខ្មែរនៅលើអេក្រង់។ លោកសាស្ត្រាចារ្យសូមឲ្យខាងសោតទស្សន៍ជួយបញ្ចាំងនៅលើអេក្រង់។ យើងដាក់តែមួយទំព័រខាងមុខទេ។ សូមអរគុណច្រើនខាងសោតទស្សន៍។

[១០:១៨:១៤]

អ្វីដែលយើងចាប់អារម្មណ៍នៅទីនេះ គឺចំណារ ដែលលោកបានឃើញនៅទីនេះ និងកាលបរិច្ឆេទថ្ងៃ១១ ខែវិច្ឆិកា ៧៧។

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** បាទ ខ្ញុំសូមមើលឯកសារនេះ បន្តិចសិន។ “ជូនបង នួន មួយច្បាប់”។

**ស៖** សូមអរគុណ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ឡើងវិញ ដែលថាឲ្យខ្ញុំមើលចំណារទាំងអស់នេះ ហើយកាលពីម្សិលមិញ

ហើយព្រឹកនេះ ក៏ខ្ញុំមើលចំណារនេះច្រើន នៅក្នុងសៀវភៅច្រើនផងដែរ ហើយខ្ញុំបានឃើញចំណារទាំងអស់នេះផង។ សូមអរគុណ។

[១០:១៩:១៣]

**ស៖** សូមអរគុណ។ លោក ដែលយើងខ្ញុំទាមទារច្រើនពីលោក ដែលលោកបានឲ្យមើលឯកសារយ៉ាងច្រើន។ នៅពេលដែលយើងមើលចម្លើយសារភាពទីពីរ ជាចម្លើយសារភាពមួយជាងនេះបន្តិច គឺចម្លើយរបស់ ចាប មុិត។ ខ្មែរ ERN 00226401, អង់គ្លេស ERN គឺ 00284069។ សូមឲ្យលោកអាន ប្រសិនបើលោកអាច យើងមានឯកសារជាភាសាអង់គ្លេស ហើយវាងាយសម្រាប់លោកអានជាភាសាអង់គ្លេស។ ខ្ញុំសូមអរគុណ ប្រសិនបើខាងសោតទស្សន៍បញ្ចាំងលើអេក្រង់ ERN ជាភាសាខ្មែរ 00226401 សូមអរគុណ។ សូមឲ្យលោកសាស្ត្រាចារ្យអានផងត្រង់អត្ថបទនេះ វាងាយស្រួលបើលោកមើលអត្ថបទជាភាសាក្រដាស -- នៅក្នុងក្រដាស ហើយអានវាតែម្តង។ តើលោកសាស្ត្រាចារ្យអាចអានបានដែរឬទេ? បាទ គឺខ្ញុំកំពុងតែរង់ចាំមើលមីក្រូហ្វូននោះ បើកភ្លើងជាមុនសិនទើបលោកអានតាមក្រោយ។

**ឆ៖** ខ្ញុំក៏ -- ខ្ញុំគិតថាខ្ញុំក៏អាចអានជាភាសាខ្មែរដែរ ខ្ញុំអំមិញហ្នឹងផ្ទៀងផ្ទាត់ជាភាសាខ្មែរ -- ជាមួយនឹងភាសាខ្មែរផងដែរ។ ចំណុចមួយនោះគឺថា ផន គឺជាមន្ត្រីនៅស-២១ ផងដែរ វាជាចំណារសរសេរដៃដោយ ឌុច ដែលយើងដឹងហើយថាបានបញ្ជាក់យ៉ាងច្បាស់។ ចំណុចសំខាន់គឺនៅក្នុងកថាខណ្ឌទី២ គឺមានលេខរ៉ូម៉ាំង ទៅដល់បងលេខ២។ បងលេខ២ នេះគឺជាឈ្មោះដែលគេកំណត់សម្រាប់ នួន ជា។ អ្វីដែលសរសេរនៅក្នុងនេះ គឺការណែនាំនេះគឺចេញពី នួន ជា ទៅ សុន សេន បន្ទាប់មកបញ្ជូនទៅ ឌុច ហើយ ឌុច នេះបញ្ជូនទៅថ្នាក់ក្រោមទៀត ដូច្នេះ វាជាខ្សែសង្វាក់នៃការណែនាំ។ ហើយអ្វីដែលគេបានសរសេរលម្អិតនោះ គឺគេមិនបានពន្យល់នោះទេ។

[១០:២២:០៣]

**ស៖** ពាក់ព័ន្ធទៅនឹងឯកសារទីបីម្តង។ គឺឯកសារនេះ ខ្ញុំមានតែជាភាសាខ្មែរតែប៉ុណ្ណោះ។ ហើយវា -- ការបកប្រែនោះក៏ទាន់ផ្លូវការនោះដែរ ក៏ប៉ុន្តែលោកអាចធ្វើការសង្ខេបខ្លឹមសាររបស់ឯកសារនេះជូនយើងខ្ញុំបាន។ គឺឯកសារ IS5.41 ឬក៏ E3/1565 គឺជាចម្លើយសារភាពទីបី ដែលសហព្រះរាជអាជ្ញាជាតិទើបតែអានឈ្មោះអម្បាញ់មិញ គឺចម្លើយសារភាពរបស់ គង់ គៀន ហៅ អុឹង វ៉េត។ លោកសាស្ត្រាចារ្យ ប្រសិនបើខ្ញុំសូមឲ្យលោកជួយអានបន្តិចនោះ គឺសូមឲ្យសោតទស្សន៍បញ្ចាំងទៅលើ

អក្រេង់ផងដែរ ដើម្បីឲ្យយើងមើលឃើញ។ ERN ជាភាសាខ្មែរ 0017305, អង់គ្លេសគឺ 00182773។ យើងឃើញមានចំណារច្រើនណាស់នៅលើឯកសារនេះ ក៏ប៉ុន្តែសូមឲ្យលោកចាប់ផ្តើមអានចំណារដែលមានគូសរង្វង់ពណ៌ខៀវជុំវិញ។ សូមឲ្យលោកមើលពីឯកសារក្រដាសរបស់លោក ដោយសារវាមានភាពងាយស្រួលជាង។

[១០:២៣:១៩]

**ឆ៖** សរសេរ -- ចំណារសរសេរដែនេះ គឺមិនច្បាស់ទេ គេសរសេរថាជូន បងនួន មួយច្បាប់។ ខ្ញុំអានជាភាសាខ្មែរដោយសារតែក្នុងនេះសរសេរថាជូន បងនួន មួយច្បាប់តែខ្ញុំមិនស្គាល់ចំណារនេះសរសេរដោយអ្នកណានោះទេ។

**ស៖** សូមឲ្យអានចំណារនៅខាងស្តាំដែលសរសេរលេខ១ លេខ២ នោះផងដែរ។ សូមឲ្យលោកជួយអាន។

**ឆ៖** លេខ១ ឯកសារនេះៗ ច្បាស់ណាស់ មនុស្សភាគច្រើនៗ ហើយបន្ទាប់មកវាអត់ សរសេរអត់ច្បាស់ទេ ខ្ញុំអានអត់រួច។ ចំណុចចុងក្រោយសរសេរថា មួយចំនួនខាង៣៣ និង៣៥ ហើយខ្ញុំអត់អានអក្សរ “ទ”ៗ នោះទេ។ ប្រហែលជាអង្គភាព១០៩ ខ្ញុំអត់បានយកវចនានុក្រមជាភាសាខ្មែរមក ដូច្នេះខ្ញុំអានអត់ដាច់ អានអត់យល់ អត់ច្បាស់ចំពោះខ្ញុំ។

[១០:២៤:៥៥]

**ស៖** សូមអរគុណច្រើនលោកសាស្ត្រាចារ្យ។ សូមអរគុណដែលលោកព្យាយាមអានឯកសារនេះ -- ខ្លឹមសារឯកសារនេះជូនយើងខ្ញុំ។ ដើម្បីចៀសវាងកុំឲ្យយើងសង្ស័យទាំងអស់គ្នា ឯកសារទាំងបីនេះ ឯកសារពីរមានសរសេរ -- ឯកសារនោះក៏មានចំណារជូនទៅបងនួន ផងដែរ ហើយមួយទៀតសរសេរថា បងទី២។ ដូច្នេះតើវាបានឆ្លុះបញ្ចាំងអ្វី ហើយវាពាក់ព័ន្ធទៅនឹងអ្វីខ្លះឯកសារចម្លើយសារភាពនេះ?

**ឆ៖** បងនួន បងទី២ គឺជាពាក្យពីរដោយឡែកពីគ្នា ដែលប្រើប្រាស់ដោយកម្មាភិបាលនៅពេលដែលគេផ្ញើឯកសារនេះទៅកាន់ នួន ជា។ ហើយថាតើតួនាទីអ្វីមាននៅក្នុងចម្លើយសារភាពនេះ គឺថាយើងមិនដឹងថា ចម្លើយសារភាពនេះមានបំណងធ្វើអ្វីនោះទេ។ ក៏ប៉ុន្តែចំណារនេះក្នុងករណីមួយចំនួន គឺគេមិនបានបង្ហាញនៅក្នុងឯកសារភស្តុងតាងមួយណាថា គាត់ជាអ្នកសរសេរនោះទេ។ ក៏ប៉ុន្តែមានឯកសារមួយច្បាប់ដែលគេថតចម្លងជូនគាត់ ហើយគេឃើញ -- ភាគច្រើនយើងឃើញនៅឯកសារមួយ

ចំនួន គេដាក់ថា ជូនមួយច្បាប់ទៅកាន់គាត់។ ហើយឯកសារនោះគេបញ្ជូនទៅកាន់គាត់ ហើយចំណារមួយចំនួនសរសេរដោយ ឌុច។ បងទី២ នេះគឺបង -- គឺ នួន ជា ដែលផ្តល់ការណែនាំ ក្រោយពីគាត់បានពិនិត្យមើលចម្លើយសារភាពនេះ។ នៅពេលដែលគេបញ្ជូនឯកសារនេះទៅកាន់បងទី២នេះគឺ បានន័យថាគាត់បានដឹងអំពីប្រតិបត្តិការនៅមន្ទីរស-២១ គាត់ធ្វើការជិតស្និទ្ធជាមួយនឹង សុន សេន ក្នុងរបបនោះ។ នេះគឺជាអ្វីដែលខ្ញុំអាចនិយាយថា គាត់ប្រាកដជាដឹងមែនទៅលើបញ្ហាដំណើរការស-២១នេះ។

[១០:២៦:៥៥]

**ស៖** សូមអរគុណច្រើនដែលលោកបានបញ្ជាក់ចំណុចនេះ។ ប្រសិនបើខ្ញុំចូលទៅដល់ឯកសារមួយទៀតគឺ D288/6.5.2.32 គឺចេញពីចម្លើយ សូ គឹមអាន ហៅ ម៉េត (ស៊ីក) ខ្មែរ ERN ពាក់ព័ន្ធគឺ 00227819, អង់គ្លេស ERN គឺ 00284045។ ចម្លើយជាក្រដាសនេះជូនលោក បារាំង ERN គឺ 00800646 គឺចម្លើយរបស់ ម៉ី ហៅ សូ គឹមអាន លេខ ERN ភាសាបារាំងទៅ 59។ ដើម្បីជាប្រតិចារឹកនោះ គឺសូមឲ្យលោកអានឈ្មោះនេះជាភាសាខ្មែរទៅ ដោយសារតែខ្ញុំអានភាសាខ្មែរនេះការប្រកបរបស់ខ្ញុំអត់ត្រឹមត្រូវទេ។ សូមឲ្យលោកជួយអាន។

**ឆ៖** ឈ្មោះនោះគឺ អាចារ្យមី (ស៊ីក) គឺជាឈ្មោះបដិវត្តន៍ ឈ្មោះដើមនោះគឺ សូ គឹមអាន។

**ស៖** សូមអរគុណ។

**ឆ៖** ខ្ញុំមើលជាភាសាខ្មែរ វាដូចជា សូ តឹមអាន មិនមែន គឹម ទេចំពោះខ្ញុំ ក៏ប៉ុន្តែខ្ញុំគិតថា វាជាអក្សរ “ត” មិនមែន “គ” ទេ គឺ សូ តឹមអាន ចំពោះខ្ញុំ។ គឺខ្ញុំព្យាយាមមើលហើយ ប៉ុន្តែខ្ញុំដូចជាមិនច្បាស់នៅខាងលើយោបល់ ឌុច នោះ ដែលគេសរសេរនោះ មិនដឹងថា អក្សរនេះ “ត” ឬ “គ” នោះទេ។

[១០:២៨:១០]

**លោក ច័ន្ទ តារាស្មី៖**

សូមជម្រាបឯកឧត្តម អ៎! លោកប្រធាន។ សូមជម្រាបអង្គសវនាការ តាមការអានរបស់ខ្ញុំទៅលើអត្ថបទនេះគឺ ខ្ញុំសូមអានថា “អំពីករណីអាចារ្យម៉ី ក្នុងវង់ក្រចក គឺ សូ តឹមអាន”។ ព្រោះក្នុងអក្សរនេះ គឺតាមមើលការពិនិត្យអក្សរនេះគឺអក្សរ “ត” បាទ មិនមែនអក្សរ “គ” ទេ ទៅតាមការយល់ឃើញរបស់ខ្ញុំបាទ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមឲ្យខាងសោតទស្សន៍ ដាក់ភាសាខ្មែរនៅលើអេក្រង់ ERN ជាភាសាខ្មែរគឺ 00231321។

ខ្មែរគឺ 00227819 ទេ ខ្ញុំសូមកែតម្រូវ អំមិញ ខ្ញុំអានលេខ ERN ខុស។ ការបកប្រែជាភាសាអង់គ្លេស គឺ 00284045, បារាំងគឺ ត្រង់ទំព័រ 00800646។ ត្រង់ទំព័រដំបូង គឺខ្ញុំសូម -- ទំព័រដំបូង សូមបញ្ចាំងលើអេក្រង់ ហើយសូមឱ្យលោកសាស្ត្រាចារ្យមើលជាភាសាខ្មែរ។ តើលោកអាចសង្ខេបទេ ខ្លឹមសារនៅក្នុងអត្ថបទនេះ គឺយ៉ាងម៉េចដែរ? យើងខ្ញុំមិនចង់ឱ្យលោកពន្យល់ទាំងអស់ទេ គឺបន្ទាប់មក គេអាន ការអានសង្ខេបនោះ គឺយើងចូលទៅដល់អត្ថបទមួយទៀត។

**ឆ៖** វាពិបាកណាស់នៅពេលដែលឱ្យខ្ញុំសង្ខេប ក៏ប៉ុន្តែវាបង្ហាញថាឯកសារនេះបង្ហាញព័ត៌មានលម្អិត គឺថាករណីនេះ គឺគេបានបញ្ជូនទៅបញ្ជូនមក ដើម្បីឱ្យមានការផ្ទៀងផ្ទាត់ចម្លើយសារភាព។ ចម្លើយសារភាពនេះ គឺៗគេ គឺគេចង់ដឹងថាតើបុគ្គលនេះបុគ្គលនេះមកពីណា? មានតួនាទីអ្វី? ដូច្នេះនេះ គឺជាចម្លើយសារភាពដែលគេធ្វើការស៊ើបអង្កេតទៅលើបុគ្គលរូបហ្នឹង។

[១០:៣១:២៧]

**ស៖** មើលនៅទំព័រចុងក្រោយនៃសេចក្តីដកស្រង់ចេញពីឯកសារជាភាសាខ្មែរ។ នេះជាទំព័រទីពីរក្នុងភាសាអង់គ្លេស ហើយខ្ញុំចង់ឱ្យលោកពិនិត្យមើលចំណុចទីបីដែលចាប់ផ្តើមថា "ស្នើយោបល់"។ សូមលោកអានជាភាសាអស់គ្លេសជូនតុលាការបាទ។

**ឆ៖** នេះជាករណីដែលកម្រ។ ជាញឹកញាប់ ប៉ុន្តែវាជាករណី ឌុច គឺថាបញ្ជាបញ្ជូនឯកសារទៅថ្នាក់ សូមអង្គការពិនិត្យមើលរឿងករណីនេះ។ ឌុច គឺថា ដូចដែលយើងដឹងពីរឿងក្តីមុន គឺគាត់មិននិយាយផ្ទាល់ទៅទេ ប៉ុន្តែគាត់សរសេរឯកសារទៅប្រាប់ទៅ សុន សេន ដែលជាមនុស្សទំនាក់ទំនងរបស់គាត់ ហើយគាត់បញ្ជូនទៅបងផ្សេងៗ។ ហើយគាត់បញ្ជូនទៅអ្នកមួយផ្សេងនៅថ្នាក់កំពូល។ នេះហើយជាវិធីដែលគេធ្វើការងារនោះ។ ហើយគាត់ត្រូវការការពិនិត្យបន្ថែមទៀតពីលើគាត់នោះ។

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកអ្នកជំនាញ។ បាទឥឡូវនេះដល់ម៉ោងពេលវេលាសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យដល់អ្នកជំនាញនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញនៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងកំណត់ខាងលើ

អម្បាញ់មិញនេះ។

សូមអញ្ជើញលោកមេធាវី!

[១០:៣៣:១៦]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមនិយាយដោយសង្ខេប ហើយខ្ញុំមិនចង់រំខានពេលសម្រាកទេ ខ្ញុំចង់ត្រឡប់មកចំណុចមួយដែលចៅក្រម ខាតវ៉ាយថ៍ លើកឡើងព្រឹកមិញនេះ ដែលនិយាយអំពីឯកសារ១.១០០ ដែលដាក់ចូលក្នុង*អ៊ីនធីហ្វេស*នោះ ខ្ញុំបានឮថា យើងអាចនឹងទទួលខុសត្រូវពីរឿងនេះ ហើយចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់ថា នេះគឺជា -- ឥឡូវនេះខ្ញុំបានមើលឃើញថាចៅក្រម ខាតវ៉ាយថ៍ គ្រវីក្បាល នេះមិនមែនជាការបង្ហាញថាដើម្បីកត់ត្រាបានត្រឹមត្រូវ គឺឯកសារ១.១០០ នេះដែលបានដាក់ចូលនោះ គឺមិនៗមែនមេធាវីការពារ នួន ជា ជាអ្នកដាក់នោះទេ តែម្នាក់ឯងទេ។ យើងដាក់តែ១៥០ប៉ុណ្ណោះ។ ដាក់រាប់បញ្ចូលទាំងការបកប្រែផង គឺថាឯកសារ៦៨ច្បាប់ដើមទេ។ ហើយខ្ញុំមិនធ្វើឱ្យរំខានដល់សហព្រះរាជអាជ្ញាទេ សហព្រះរាជអាជ្ញាក៏បានដាក់ចូលច្រើនជាង ៧០០ឯកសារឯណោះ។ នេះជាបញ្ហាទាក់ទងនឹងមិនបានជូនដំណឹងមុនដែរ។ គឺមិនត្រូវស្តីបន្ទោសតែមេធាវី នួន ជា ទេ។ ហើយយើងមិនបានទទួលព័ត៌មានត្រឹមត្រូវ។ ហើយថ្ងៃនេះ យើងមិនមែនជាភាគីដែលត្រូវទទួលការស្តីបន្ទោសពីការដាក់ឯកសារថ្មីមិនបានដឹងមុន។

[១០:៣៤:៣៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំនិយាយដោយសង្ខេប គឺថាតើចំនួននេះមានដូចម្តេច? គឺថាចំនួន៧០០នេះ គឺគប្បីបែងចែកជាបីពីព្រោះថា វាមានការបកប្រែផងដែរ។ យើងដាក់ឯកសារតែជាង ២០០រយទេ ដែលថាចំនួននោះ វាច្រើន គឺថាយើងដាក់ចម្លើយសារភាពមួយចំនួនដែលយើងបានបញ្ជូនលោកសាស្ត្រាចារ្យ ដើម្បីឱ្យភាគីបានដឹងដើម្បីឱ្យបានត្រៀម។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ប៉ុន្តែសូមមេធាវីពិនិត្យលើសេចក្តីសម្រេចព្រឹកមិញឡើងវិញ តាមខ្ញុំនៅចាំឃើញថាការរំឭកភាគីទាំងអស់ ដែលពាក់ព័ន្ធក្នុងការប្រើប្រាស់ដាក់ឯកសារ គឺឱ្យគិតគូរទាំងអស់គ្នា ហើយឱ្យអនុវត្តទាំងអស់គ្នា មិនមែនតែក្រុមមេធាវីរបស់ នួន ជា មួយភាគីនោះទេ គឺភាគីនៃរឿងក្តី

ទាំងអស់។

បាទ សូមសម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៥នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវី មានបញ្ហាអីទៀតហើយ?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ខ្ញុំប្រើពេលតែពីរមីនុតទេ ហើយនិងជូនវេទិកាទៅសហព្រះរាជអាជ្ញា។

ខ្ញុំដោយសង្ខេប យើងខ្ញុំ -- បើសិនជាអង្គជំនុំជម្រះអាច ឬក៏បុគ្គលណាម្នាក់អាចសម្រួល អាចនឹងបញ្ចេញប្រតិចារឹកជូនដល់យើងខ្ញុំសម្រាប់សប្តាហ៍នេះ ដើម្បីនឹងជួយដល់យើងបានសិក្សាបានល្អ ដើម្បីយើងអាចនឹងមើលក្នុងអ៊ីម៉ែល ហើយខ្ញុំ យើងអាចនឹងទាញសេចក្តីដកស្រង់ទៅលោក ឆេនដ័ល័រនូវអ្វីដែលគាត់បានលើកឡើងនៅក្នុងពេលកន្លងមកនេះ។ បាទ យើងខ្ញុំចង់បានប្រតិចារឹកមុននឹងចប់សប្តាហ៍នេះបាទ។

[១០:៥៤:៤៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន អង្គសវនាការទាំងមូល។ សូមអធ្យាស្រ័យម្តងទៀត ដោយសារមករំខានពេលវេលាខ្លះ។ ហើយមុនគាត់សម្រាកនេះ តុលាការបានសម្រេចលើសំណើសុំរបស់តំណាង

សហព្រះរាជអាជ្ញាទៅលើការពន្យារពេលបន្ថែមមួយម៉ោង។ ខ្ញុំចង់ដឹងថា ពេលវេលាដែលបន្ថែមនេះ តើប៉ះពាល់ដល់ពេលវេលាដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីឬក៏អត់? ឬមួយក៏ -- ព្រោះពេលវេលានេះ ជាពេលវេលារបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬមួយក៏ដើមបណ្តឹងរដ្ឋប្បវេណីមិននឹងត្រូវការបន្ថែមទៀត សម្រាប់ថ្ងៃខាងថ្ងៃចន្ទតទៀត។ ខ្ញុំបាទគ្រាន់តែចង់ដឹងទេ។ ហើយការអនុវត្តបែបនេះ បាទ ព្រោះព្រះរាជអាជ្ញាគាត់អាងថា មានការជំទាស់ និងរំខានច្រើន។ ខ្ញុំគិតថា អាការអនុវត្តបែបនេះគួរតែអនុវត្តគ្រប់ភាគីទាំងអស់ ក្នុងករណីដែលភាគីមួយកំពុងតែសួរ ហើយមានការរំខានច្រើន អ៊ីចឹងពេលវេលាត្រូវបន្តពន្យារទៅតាមនោះ។ សូមអរគុណ។

[១០:៥៥:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតរួចហើយ។ ការចាត់ចែង និងគ្រប់គ្រងពេលវេលា គឺជាសិទ្ធិ -- ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះនឹងថ្លឹងថ្លែងអំពីបញ្ហានេះឲ្យបានសមស្របបំផុត ក្នុងករណីចាំបាច់អាចពន្យារពេលនៃកិច្ចការដេញដោលពេលរសៀលរហូតដល់ម៉ោងបួនកន្លះ។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាមាននាទី១៥នាទី បាទ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សាស្ត្រាចារ្យ ឆេនដ័ល័រ នៅក្នុងពេល១០នាទីដែលនៅសល់នេះ យើងអាចព្យាយាមនិយាយដោយសង្ខេប។ សូមលោកឆ្លើយដោយសង្ខេបដែរក្នុងពេលតែ១៥នាទីនេះ។ ហើយយើងមិនមានពេលគ្រប់គ្រាន់ដើម្បីពិនិត្យមើលចម្លើយសារភាពដែលមានចំណារទាំងអស់ដែលលោកបានបំភ្លឺព្រឹកមិញនេះមួយចំនួននោះទេ។ ហើយលោកបានបញ្ជាក់ថា លោកបានមើល។ តើនៅក្នុងសេចក្តីសន្និដ្ឋានរបស់លោក តើលោកផ្អែកលើសេចក្តីសារភាពទាំងអស់នោះ តើលោកអាចនិយាយដូចម្តេចអំពីទំនាក់ទំនងពីស-២១ ទៅថ្នាក់ដឹកនាំ ជាពិសេសគឺថ្នាក់លើរបស់កម្ពុជាប្រជាធិបតេយ្យនាសម័យកាលនោះ?

[១០:៥៧:១៣]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** យើងដឹងថា ចម្លើយសារភាពមួយចំនួនត្រូវបានបញ្ជូនទៅ សុន សេន ហើយយើងដឹងអំពី

បណ្ណសារថា ដែលថាជាឯកសារផ្ទាល់ខ្លួនរបស់ សុន សេន នៅក្រសួងការពារប្រទេសកម្ពុជាប្រជាធិបតេយ្យនោះ ហើយៗគាត់បញ្ជូនចម្លើយសារភាពទៅថ្នាក់លើបន្ថែមទៀត។ ហើយគាត់ក៏ជាសមាជិកនៃគណៈមជ្ឈិម នេះគឺជាកន្លែងដែលយើងឃើញថាចម្លើយសារភាពរបស់ សុន សេន។ ពេលខ្លះ គឺមិនមែនជាចំណាររបស់ ឌុច របស់ សុន សេន ទេគឺបញ្ជូនមួយច្បាប់ទៅនឹងមនុស្សមួយចំនួនតូចជាថ្នាក់ដឹកនាំ។ ពេលខ្លះក៏បញ្ជូនទៅ បងវ៉ាន់ ពេលខ្លះក៏ជូនទៅ បងប៉ុល។ នេះហើយជាលោក ប៉ុល ពត។ ខ្ញុំមិនប្រាកដថាច្បាស់ជាអ៊ីចឹងនោះទេ។ ប៉ុន្តែយើងនៅពេលដែលគេបានបញ្ជូនទៅៗ មិនដឹងថាអ្នកហ្នឹងបានអានបានទទួលបែបណា យើងមិនអាចមានភស្តុតាង។ ប៉ុន្តែមិនឃើញមានបញ្ជាក់ថាបានទទួលបាទ។

[១០:៥៨:២១]

**ស៖** សូមអរគុណ។ តើលោកអាចទាញសេចក្តីសន្និដ្ឋានអ្វីបានខ្លះអំពីៗទំហំនៃការទាក់ទងរវាងមជ្ឈិមបក្ស ទាក់ទងទៅនឹងចំណារទាំងអស់នេះដែលជាចំណារសុំមតិ ឬក៏អ្វីផ្សេងនោះ?

**ឆ៖** សុន សេន គឺជាសមាជិករបស់មជ្ឈិមបក្ស គាត់ពាក់ព័ន្ធក្នុងការងារដ៏សំខាន់ ហើយ ឌុច មិនរំខានគាត់គ្រប់ទាំងអស់នោះទេ។ ប៉ុន្តែទិដ្ឋភាពសំខាន់ៗដែល ឌុច *រឹផត* រាយការណ៍ទៅ គាត់ក៏បានឆ្លើយតបមកវិញជាមួយ ឌុច នោះដែរ។

**ស៖** សូមអរគុណ។ ហើយយើងមើលឯកសារមួយទៀត ដែលចេញពី ស-២១ គឺជាឯកសារចុងក្រោយដែលយើងពិនិត្យមើលពេលនេះ គឺឯកសារ IS15.30 ហើយមានជាភាសាទាំងបីនោះឯង។ ខ្មែរ ERN 00008923, អង់គ្លេស ERN 00249844 រហូតដល់ 45, បារាំង ERN 00766902។ នៅក្នុងសំណុំឯកសារដែលខ្ញុំបានជូនទៅលោក នេះគឺជាឯកសារបញ្ជូនបុគ្គលម្នាក់ដែលយើងពិភាក្សាពីមុន គឺលោក ហ៊ូ នឹម ដែលគាត់បានបញ្ជូនទៅភាគីផ្សេង។ ឥឡូវនេះ គឺឯកសារនៅលើអេក្រង់ជាភាសាខ្មែរហើយ ឲ្យសាធារណជន ហើយភាគីដែលអានភាសាខ្មែរអាចឃើញថា នេះជាលិខិតដែលគាត់បញ្ជូនទៅបុគ្គលម្នាក់ទៀតហ្នឹង។ ដោយសារពេលខ្លី ខ្ញុំនឹងអាន ហើយនិងសូមសួរលោកទៅតាម ក្រោយបាទ។

[១១:០០:២៤]

ចាប់ផ្តើមលេខមួយ “គោរពបក្សកុម្មុយនីស្តកម្ពុជា លើសពីជីវិតខ្ញុំ។ គោរព បងប៉ុល, បងនួន, បងវ៉ាន់, បងវន, សមមិត្ត ខៀវ, សមមិត្ត ហែម ជាទីគោរពស្នេហា!”។ កថាខណ្ឌបន្ទាប់នោះ មានខ្លឹមសារដូចតទៅនេះ៖ “ថ្ងៃនេះ ១០ មេសា ឆ្នាំ១៩៧៧ ពេលដែលខ្ញុំកំពុងរៀបចំ មមាញឹករៀបចំកម្មវិធីផ្សាយវិទ្យុ ទទួលអំណរបុណ្យខួបទីពីរនៃមហាជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ តាមទូរស័ព្ទសមមិត្ត

ប៉ង់ បានហៅខ្ញុំមកធ្វើការជាមួយអង្គការ។ ពេលមិត្តយុទ្ធជនចាប់ខ្ញុំ ខ្ញុំភ្ញាក់ក្រញាង ខ្ញុំមិនស្មានយ៉ាងនេះសោះ”។ នៅខាងក្រោមមានឃ្លាមួយចំនួនដែលគាត់បាននិយាយថា៖

“ខ្ញុំព្យាយាមបញ្ជាក់ពីភាពស្មោះត្រង់របស់ខ្ញុំជូនអង្គការ ដើម្បីឲ្យអង្គការវិនិច្ឆ័យខ្ញុំ។ ខ្ញុំធានាចំពោះអង្គការថា ខ្ញុំមិនដែលក្បត់អង្គការទេ ខ្ញុំមិនពាក់ព័ន្ធជាមួយ សេ.អ៊ី.អា នោះទេ ឬក៏ពាក់ព័ន្ធជាមួយនឹងភ្នាក់ងារ សឹង ង៉ុកថាញ់ នោះទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ សាថ្មី ហើយសូមអធ្យាស្រ័យសាថ្មីដែរ។ ខ្ញុំឃើញព្រះរាជអាជ្ញាអំមិញគាត់មកអានចម្លើយសារភាព ដកស្រង់ចម្លើយសារភាព ដែលខុសពីអ្វីដែលព្រះរាជអាជ្ញាបានអាននៅ -- ហើយការកំណត់លើទំព័រ គឺ *អាណូថេសិន* នៅលើចម្លើយសារភាព។ ខ្ញុំថាអានចម្លើយសារភាពរបស់ជនរងគ្រោះ ខ្ញុំហៅជនរងគ្រោះរបស់ -- នៅមន្ទីរស-២១ យកមកឲ្យសាក្សីវិភាគ ហើយឆ្លើយបែបនេះ ខ្ញុំថាជាការមិនត្រឹមត្រូវទេ។ ព្រះរាជអាជ្ញាអាចសួរតែទៅលើការ ចំណារទៅលើឯកសារចម្លើយសារភាពតែប៉ុណ្ណោះ។ សូមអរគុណ។

[១១:០២:៣៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

អនុសញ្ញាប្រឆាំងនឹងទារុណកម្ម គឺអនុវត្តតែចំពោះឯកសារទាំងឡាយណាដែលវាកើតចេញពីការធ្វើទារុណកម្ម។ នេះមិនមែនជាចម្លើយសារភាពទេ ជាលិខិតរបស់បុគ្គលមួយរូបដែលត្រូវបានគេចាប់ខ្លួនមុនពេលសួរចម្លើយនិងធ្វើទារុណកម្ម ផ្ញើទៅកាន់បុគ្គលដែលមានឈ្មោះនៅក្នុងនេះ។ ក្នុងលិខិតនេះគឺបានបញ្ជាក់ថា ថ្ងៃទី១០ មេសា ៧៧ គឺគេត្រូវបាន -- គាត់ត្រូវបានចាប់ខ្លួន។ ដូច្នេះ ហើយលិខិតនេះគឺជាការសារភាព ការអះអាង និងការឆ្លើយឆ្លងតែប៉ុណ្ណោះ។ វាមិនមែនជាចម្លើយសារភាព ហើយវាមិនមែនជាឯកសារចម្លើយសារភាពនៅស-២១ ដែលបុគ្គលិកនៅទីនេះរៀបចំនៅទីនេះនោះទេ។ ដូច្នេះហើយអនុញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនអាចមកអនុវត្តចំពោះឯកសារនេះទេ។ សូមអរគុណ។

[១១:០៣:៣២]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់របស់មេធាវីជាតិការពារក្ដីលោក អៀង សារី គ្មានប្រសិទ្ធភាព។ គាត់មានការភ័ន្តច្រឡំលើខ្លឹមសារនៃឯកសារដែលកំពុងដាក់ដេញដោលនេះ។

តំណាងសហព្រះរាជអាជ្ញាបន្តការសួរដេញដោលចំពោះអ្នកជំនាញ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យ នៅពេលដែលយើងមើលលិខិតនេះ លោកក៏បានពិចារណាទៅលើលិខិតនេះផងដែរ តើវាមានសារៈសំខាន់អ្វីនៅក្នុងលិខិតនេះ ជាពិសេសចំពោះជម្រើសដែល ហ៊ូ នឹម នេះបានបញ្ជូនលិខិតនេះទៅកាន់អ្នកទាំងអស់នោះ?

[១១:០៥:២២]

**លោក ដេវីដ ឆេនឌ័ល័រ៖**

**ឆ៖** ទាំងអស់នេះគឺជាឈ្មោះបដិវត្តន៍របស់សមាជិកគណៈមជ្ឈិមដែលមានចាប់ផ្ដើមពី ប៉ុល ពត បន្ទាប់មកទៅដល់សមាជិកត្រៀម សុន សេន និង ខៀវ សំផន។ ហ៊ូ នឹម គឺជាអ្នកដែលខ្ពស់ដែរនៅក្នុងគណៈមជ្ឈិម ហើយគាត់ដឹងអំពីការងាររបស់បក្ស។ ចំណុចសំខាន់នៅក្នុងឯកសារនេះ គឺដូចទៅនឹងឯកសារសុំអភ័យទោសដទៃទៀត ដែលពាក់ព័ន្ធនឹងស-២១ គឺបានសរសេរឆ្លើយតបទៅកាន់ថ្នាក់ដឹកនាំខាងលើ ហើយមិនដែលបានបញ្ជូនទៅថ្នាក់លើនោះទេ គឺគ្រាន់តែយកទៅទុកនូវសំណុំឯកសាររបស់ស-២១ តែប៉ុណ្ណោះ។ ដូច្នេះហើយនេះជាឯកសារដើម ដែលលេចចេញមកពីបណ្ណសាររបស់ស-២១ នៅពេលដែលប្រគល់ចូលស-២១ បុគ្គលនោះគឺគ្មានជម្រើសអាចផ្ញើលិខិតនេះទៅកាន់ថ្នាក់លើបាននោះទេ។

**ស៖** សូមអរគុណ។ ឯកសារចុងក្រោយដែលខ្ញុំបង្ហាញជូនលោកសាស្ត្រាចារ្យ គឺកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ៧៦ ឯកសារ E3/232។ សុំឲ្យសោតទស្សន៍បញ្ចាំងឯកសារជាភាសាខ្មែរនៅលើអេក្រង់ទំព័រដំបូង។ ក្នុងពេលដែលយើងរង់ចាំ ទំព័រដែលនឹងបញ្ចាំងទៅលើអេក្រង់នោះ ត្រង់ទំព័រដំបូងនោះលោកសាស្ត្រាចារ្យ សូមឲ្យលោក សូមអានពន្យល់ តើមានបុគ្គលណាខ្លះចូលរួមក្នុងការប្រជុំ? ដូច្នេះសូមឲ្យលោកអានចំណុចដំបូង។ យើងខ្ញុំសូមឲ្យលោករង់ចាំមីក្រូហ្វូនចេញភ្លើងសញ្ញាជាមុនសិន ទើបលោកអាចឆ្លើយបាន។

[១១:០៦:១៦]

**ឆ៖** ឈ្មោះប្អូនដំបូង គឺសមមិត្តលេខា ប៉ុល ពត, សមមិត្តអនុលេខា នួន ជា, សមមិត្ត ហែម ខៀវ សំផន, សមមិត្ត ឌឿន, សមមិត្ត ស្រេង, សមមិត្ត ហង់, សមមិត្ត សុត និងសមមិត្ត ឌុច -- ទូច សមមិត្ត ទូច។

**ស៖** អ្វីដែលខ្ញុំចង់សួរនោះ គឺថាចូលទៅដល់ចំណុចរបៀបវារៈនៃកិច្ចប្រជុំ ដែលក្នុងនោះគឺតាម របាយការណ៍របស់បុគ្គលពីរនាក់ ដែលលោកបានលើកឡើងអម្បាញ់មិញ។ ខ្មែរ ERN ជាភាសា 0017118, អង់គ្លេស 00323933។ បាទ សូមអធ្យាស្រ័យ ERN ជាភាសាអង់គ្លេសគឺ 00182630 បារាំងគឺ 00323933។

សូមឱ្យសោតទស្សន៍ជួយបញ្ចាំងឯកសារជាភាសាខ្មែរនៅលើអេក្រង់។

ERN ជាភាសាអង់គ្លេស -- ជាខ្មែរនោះគឺ 00171188(ស៊ីក)។ នៅពេលដែលលោកសាស្ត្រាចារ្យ មើលទៅលើខ្លឹមសារនៃឯកសារនេះ នៅចំណុចលេខ២ និយាយអំពីសភាពការណ៍នៅមូលដ្ឋាន៖

“១) សមភាពការណ៍នៅ៣០៣ សមមិត្ត ស្រេង រាយការណ៍ជូនអង្គការអំពីសកម្មភាពរបស់៖ ចំណុច១) ពួក អាលឿន និងគ្នាវា ៣៤នាក់ ដែលកងទ័ពភាគចាប់ខ្លួនអស់ហើយ។ ពួកអា អ៊ុក ម៉ឺន ហៅ អ៊ុក ហុង ដែលប៉ុនប៉ងរត់ទៅវៀតណាមខាងត្បូង និងគ្នាវា៤-៥នាក់ទៀត ហើយស្នើមតិណែនាំរបស់ អង្គការ”។

[១១:០៨:១០]

ហើយពាក់ព័ន្ធទៅនឹងសភាពការណ៍នៅ១០៦៖

ចំណុច២) គឺសមមិត្ត សុត រាយការណ៍ជូនអង្គការអំពីសកម្មភាព។ ចំណុច ក គាត់លើកឡើង ថា សមមិត្ត សុត រាយការណ៍បញ្ហាមួយចំនួន។ បញ្ហាអ្នកជំងឺនៅការដ្ឋាន ហើយបាត់បង់កម្លាំងពលកម្ម បួនភាគរយ (ស៊ីក)”។

ការសរសេរនៅក្នុងនេះបន្ទាប់ទៀត គឺនិយាយអំពីយោបល់របស់អង្គការ ត្រង់លេខ III។ សូម ឱ្យខាងសោតទស្សន៍ជួយបញ្ចាំងនៅលើអេក្រង់ផង។ “ពាក់ព័ន្ធទៅនឹងបញ្ហាបី នៅ៣០៣ ត្រូវតែកោះ ហៅបុគ្គលដែលមានឈ្មោះទាំងអស់នោះមកសួរ ថាតើទទួលខុសត្រូវអ្វី? យើងមិនទាន់ដកពួកគេចេញពី តំបន់នោះនៅឡើយនោះទេ។ កោះហៅពួកគេមកសួរចម្លើយ ហើយចង់មើលប្រតិកម្មរបស់ពួកវាយ៉ាង ម៉េច? ដូច្នេះមានវិធានការពីរ។ ទីមួយ ទុកនៅការដ្ឋាន ហើយរាយការណ៍ទៅថ្នាក់លើ រួមជាមួយនឹង ឯកសាររបស់ពួកវា”។

[១១:០៩:៣០]

ដូច្នេះលោកសាស្ត្រាចារ្យ សមមិត្ត ស្រេង ដែលរាយការណ៍អំពី៣០៣ និងបានទទួលមតិណែនាំពីអង្គការ ថាតើចាត់ការទៅលើបុគ្គលមួយចំនួនទាំងអស់នោះដោយរបៀបណា? ដូច្នេះ តើចំណុចនេះមានចំណុចសំខាន់អ្វីខ្លះ ពាក់ព័ន្ធទៅនឹងការចូលរួមរបស់បក្ស -- គណៈមជ្ឈិមទៅលើការងារនៅក្នុងតំបន់?

**ផ៖** ចំណុចនេះបានបង្ហាញឲ្យឃើញថា វាមានការគ្រប់គ្រងទៅលើសកម្មភាពមួយចំនួនដែលសំខាន់ ហើយបញ្ជូនពួកទាំងអស់នៅធ្វើការពិនិត្យមើល។ ដូច្នេះ បុគ្គលមួយចំនួនមានការពាក់ព័ន្ធនៅក្នុងហ្នឹង។ ក្រុម៣៤ នោះ គឺបានរត់គេចខ្លួន គ្រោងរត់គេចខ្លួន។ ដូច្នេះហើយ គេចង់ឲ្យមានការសួរចម្លើយទៅលើបុគ្គលទាំងអស់នេះ យកពួកគេមកដាក់ចូលនៅមន្ទីរនៅក្នុងស្រុក ហើយមិនចាំបាច់ដកពួកគេចេញពីតួនាទីនោះទេ។ ដូច្នេះហើយ ការគ្រប់គ្រងបុគ្គលទាំងអស់មួយចំនួននេះ គឺដើម្បីគេចង់តាមដានឲ្យបានដិតដល់។

[១១:១០:៤៨]

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ។ សំណួររបស់ខ្ញុំសម្រាប់ថ្ងៃនេះ នោះគឺនៅពេលដែលយើងពិនិត្យការពិភាក្សារវាងយើងទាំងពីរនាក់ កាលពីពីរថ្ងៃ អំឡុងពេលពីរថ្ងៃមុននេះ គឺយើងឃើញថាមានភស្តុតាងបង្ហាញអំពីការទទួលខុសត្រូវជាសមូហភាពនៅថ្នាក់លើ។ ខ្ញុំចង់ឲ្យយើងបញ្ជាក់យល់ទាំងអស់គ្នា ទៅលើយោបល់ដែលលោកបានឆ្លើយ។ ហើយកុំឲ្យយើងសង្ស័យពាក់ព័ន្ធទៅនឹងអ្វីដែលលោកបានលើកឡើងទៅលើការងារសមូហភាពនេះ។ ខ្ញុំនឹងអនុញ្ញាតឲ្យលោកផ្តល់ជាយោបល់ទៅលើចំណុចនេះ។

ខ្ញុំសូមចូលទៅដល់សៀវភៅ "សោកនាដកម្មប្រទេសកម្ពុជា" ខ្ញុំមិនបង្ហាញឯកសារនេះទេ ក៏ប៉ុន្តែគឺលេខ ERN ពាក់ព័ន្ធ គឺ 00193302។ គឺមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ នៅក្នុងសៀវភៅត្រង់ទំព័រនេះ គឺលោកនិយាយអំពីការបន្តការប្រតិបត្តិរបបកម្ពុជាប្រជាធិបតេយ្យ។ លោកបានលើកឡើងនៅក្នុងអត្ថបទនោះថា "ពាក់ព័ន្ធនៅនឹងការអនុវត្ត។ ការនិរន្តភាពនៃកម្ពុជាប្រជាធិបតេយ្យគឺត្រូវតែ -- របបកម្ពុជាប្រជាធិបតេយ្យត្រូវតែផ្តល់អំណាចមួយចំនួនទៅដល់បុគ្គលមួយចំនួន។ សម្តេចឪ និង លេខានោះ គឺប៉ុល ពត គឺគាត់ទទួលខុសត្រូវទៅលើការងារនេះ។ បក្សកុម្មុយនីស្តកម្ពុជា គឺលាក់ខ្លួនទៅលើកម្មាភិបាលរបស់ខ្លួនមួយចំនួន។ ពាក់ព័ន្ធប្រតិបត្តិរបស់ពួកគេ គឺបានបង្ហាញឲ្យឃើញការគ្រប់គ្រងទៅ

លើព័ត៌មាន ហើយនិងទៅលើការដឹកនាំបញ្ហា។ នៅត្រឹមឆ្នាំ១៩៧៧ បងទីមួយ ប៉ុល ពត, បងទីពីរ នួន ជា មានការលាក់បាំងនៅក្នុងអង្គការ”។

[១១:១៣:០២]

ការបន្តមួយទៀត ពាក់ព័ន្ធទៅនឹងការដឹកនាំរបស់ លន់ នល់ និង សីហនុ គឺនារីនិងបុរស នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺយើងឃើញមានការគ្រប់គ្រងនៅក្នុងរបបនេះ។

ខ្ញុំចង់សួរថា វាជាចំណុចដកស្រង់ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរបស់បុគ្គលមួយរូប ហើយយើងឃើញថា វាមានការកសាងអំណាចនៅក្នុងចំណោមកម្មាភិបាល។ ដូច្នេះ នៅទីនេះគឺខ្ញុំសូមឲ្យធ្វើការពន្យល់ ប្រសិនបើអាច។ តើលោកមានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកប្រើពាក្យថា “បុគ្គលមួយរូបជាអ្នកគ្រប់គ្រងទាក់ទងនឹងអំណាចនៅក្នុងប្រទេស”?

[១១:១៣:៥៨]

**ឆ៖** នេះគឺជាអត្ថបទក្រោយរយៈពេល២២ឆ្នាំ ខ្ញុំអាចផ្តល់ជាយោបល់បាន។ ខ្ញុំជឿថា មានឯកសារជាច្រើនដែលខ្ញុំផ្អែកទៅលើចំណុចនេះ។ យើងដឹងហើយថា ការដឹកនាំកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈសមូហភាព ហើយសេចក្តីសម្រេចដែលចេញមកពី ប៉ុល ពត គឺជាសេចក្តីសម្រេចចុងក្រោយ។ ដូច្នេះហើយគាត់គឺជាថ្នាក់ដឹកនាំនៅក្នុងអង្គការប្រតិបត្តិក្នុងប្រទេសកម្ពុជា។ ហើយយើងអាចហៅសម័យនោះថា ជាសម័យរបស់ ប៉ុល ពត។ យើងដឹងហើយថា ខ្ញុំនឹងទៅមើលអត្ថបទនេះឡើងវិញ ខ្ញុំសូមបញ្ជាក់ថា ការដឹកនាំនៅទីនោះ គឺយ៉ាងណាក៏ដោយ មានលក្ខណៈជាសមូហភាព។ ខ្ញុំបានសរសេរសៀវភៅនេះ មុនពេលដែលខ្ញុំមកដល់ប្រទេសកម្ពុជានេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើនលោកសាស្ត្រាចារ្យ។ ហើយខ្ញុំសូមអរគុណ អង្គជំនុំជម្រះដែលបានផ្តល់ពេលវេលាមួយចំនួននេះ មកដល់យើងខ្ញុំ។ សូមអរគុណ។

[១១:១៥:០០]

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល មេធាវីនាំមុខបានស្នើសុំផ្ទេរសិទ្ធិផ្តល់ជូនលោកមេធាវី ហុង គីមសួន។ លោកស្រីមេធាវី គ្រីស្ទីន ម៉ាទីណូ និងលោកមេធាវី អូលីវីយេ បាហូញ ដើម្បីធ្វើអន្តរាគមន៍ពាក់ព័ន្ធនឹងការសួរអ្នកជំនាញដេវីដ ឆេនដ័ល័រ នេះ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក ហុង គីមសួន៖**

សូមគោរពលោកប្រធាន លោកចៅក្រម លោកស្រីចៅក្រម ព្រមទាំងអង្គសវនាការជាទីគោរព ខ្ញុំបាទ ហុង គីមសួន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមជម្រាបសួរលោក ដេវីដ ឆេនដ័ល័រ។ ខ្ញុំនឹងមានសំណួរខ្លះៗបន្តពីលោកព្រះរាជអាជ្ញា។ ហើយខ្ញុំព្យាយាមមិនឲ្យមានជាន់សំណួរគ្នា ក៏ប៉ុន្តែប្រហែលជាចៀសមិនរួចខ្លះៗសូមអនុញ្ញាតឲ្យជាដំបូន្មានដែលខ្ញុំបាទវិញ នៅពេលណាលោកមានប្រសាសន៍ជូនអង្គសវនាការរួចហើយបាទ។ ជាដំបូង ខ្ញុំសូមអនុញ្ញាតសួរលោកទាក់ទងជាមួយប្រវត្តិសាស្ត្រនៃចលនាតស៊ូរបស់ឥស្សរៈដែលបានទាក់ទងគ្នារហូតមកដល់របបកម្ពុជាប្រជាធិបតេយ្យ។ មានន័យថា មុននឹងមានកកើតជាបក្សកុម្មុយនីស្តកម្ពុជា គឺនៅក្នុងសៀវភៅរបស់លោកស្តីអំពីប្រវត្តិសាស្ត្រខ្មែរនោះ មាននិយាយអំពីក្រុមបក្សប្រជាជនបដិវត្តន៍ខ្មែរ និងក្រុមឥស្សរៈជាដើម។

សំណួររបស់ខ្ញុំចង់សួរលោកថា តើបក្សប្រជាជនបដិវត្តន៍ខ្មែរវាមានទំនាក់ទំនងអីខ្លះជាមួយនឹងក្រុមឥស្សរៈកាលពីការកកើតឡើងនៅក្នុងចន្លោះឆ្នាំ១៩៤៧ និង ១៩៤៨ បាទ?

[១១:១៧:៥៧]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** គឺជាអំឡុងពេលមួយដែលយើងបានពិភាក្សាពីខាងដើម ការទំនាក់ទំនងរវាងគណបក្សប្រជាជនបដិវត្តន៍ខ្មែរ និងរណសិរ្ស គឺយើងឃើញថាទំនាក់ទំនងរវាងឥស្សរៈនោះគឺយើងឃើញថា

មានការជំរុញដោយប្រទេសថៃ ហើយគឺការជំរុញពីមូលដ្ឋាន។ ហើយទំនាក់ទំនងមួយចំនួននោះគឺជំរុញដោយវៀតណាម រវាងគណបក្សប្រជាជនបដិវត្តន៍ខ្មែរនិងឥស្សរៈ។ គណបក្សប្រជាជនបដិវត្តន៍ខ្មែរកើតនៅក្នុងឆ្នាំ៥១ ដែលមានក្រុមមួយចំនួនចងសម្ព័ន្ធជាមួយនឹងមូលដ្ឋាន ហើយគណបក្សនេះគឺមិនទទួលយកឥស្សរជន ឥស្សរៈមកចូលរួមជាមួយនោះទេ។ គោលបំណងរបស់បក្សនេះ គឺដើម្បីធ្វើការទាមទារឯករាជ្យពីប្រទេសបារាំង ហើយមិនមានកម្មវិធីសង្គមណាមួយដែលបានបង្កើតឡើងដោយបក្សនេះឡើយ។ បក្សប្រជាជនបដិវត្តន៍ខ្មែរនេះបានបង្កើតឡើងដោយវៀតណាម និងការជំរុញដោយវៀតណាម។ ដោយបន្ទាប់មកមានការប្រែទៅជាប្រជាជនបក្សខ្មែរ។ ក្នុងរយៈពេលជាច្រើនឆ្នាំមកបក្សនេះគឺ បម្រើការរួមជាមួយនឹងបក្សឥណ្ឌូចិន ដែលក្នុងនោះគឺចូលរួមនៅក្នុងសង្គ្រាមឥណ្ឌូចិនជាមួយនឹងវៀតណាម ជាមួយនឹងឡាវ ដើម្បីវៃប្រឆាំងនឹងបារាំង។ ទំនាក់ទំនងរវាងបក្សនេះជាមួយនឹងជនដែលមិនមែនជាកុម្មុយនីស្តគឺឥស្សរៈ គឺជំរុញរកចូលទៅដល់ចលនាកុម្មុយនីស្ត ហើយយើងឃើញថា វាមានបង្ហាញច្បាស់នៅក្នុងឆ្នាំ៤៥ រហូតដល់ឯករាជ្យកម្ពុជា ប្រទេសកម្ពុជា។ ហើយគេបានបង្កើតកម្ម វិធីបរទេសមួយចំនួនដើម្បីចូលរួមសកម្មភាពជាមួយនឹងវៀតណាម ឡាវ ជាពិសេសនៅក្នុង ការតស៊ូនៅក្នុងឥណ្ឌូចិនប្រឆាំងនឹងបារាំង។

[១១:២០:៤០]

យើងឃើញថា បក្សនេះគឺមិនពេញចិត្តទៅនឹងកម្មវិធីរបស់ខ្លួននោះឡើយ ហើយជាពិសេសគឺទៅលើចលនារបស់គេ ដែលវាមានការរារាំងដោយរដ្ឋាភិបាលនៅពេលនោះ។ ដូច្នេះហើយយើងឃើញថាក្រុមនេះគឺវាមានទំនាក់ទំនងខ្លះដែរជាមួយនឹងឥស្សរៈ។

**សៈ** សូមអរគុណ។ អម្បាញ់មិញលោកបានមានប្រសាសន៍ជម្រាបជូនទៅដល់អង្គសវនាការទាក់ទងជាមួយនឹងចលនាតស៊ូឥស្សរៈហ្នឹង វាបានជំរុញចូលមកដល់រឿងបក្សកុម្មុយនីស្តកម្ពុជា។ សំណួររបស់ខ្ញុំសួរថា តើឥស្សរជនដែលនៅក្នុងជំនាន់សម័យតស៊ូឥស្សរៈហ្នឹង មានក្លាយខ្លួនមកជាមន្ត្រីជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាក្រោយបានឯករាជ្យមកហើយដែរឬទេ?

**ឆៈ** ខ្ញុំមិនគិតថា បុគ្គលដែលមានសកម្មភាពនៅក្នុងប្រទេសកម្ពុជា ឬក៏ប្រទេសថៃ គាំទ្រទៅលើចលនាឥស្សរៈនោះទេ។ វាកាន់តែមានសារៈសំខាន់ឡើងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ទូ សាមុត និង សឺង ង៉ុកមិញ គឺបុគ្គលដែលមកពីវៀតណាមខាងត្បូង ក្នុងចំណោមជនជាតិភាគតិចខ្មែរនៅទីនោះ គឺជាអ្នកដែលគាំទ្រដោយវៀតណាម នៅក្នុងការជួយជ្រោមជ្រែងនេះ។ ហើយពួកគេបានចូលទៅដល់

កាន់តួនាទីមួយចំនួននៅក្នុងបក្ស។ ទូ សាមុត បានក្លាយទៅជាលេខា ហើយក្រោយមកបាត់ខ្លួន ហើយដែលគេសន្មតថា ត្រូវបានគេសម្លាប់ចោលនៅឆ្នាំ៦២។ សឹង ង៉ុកមិញ គឺជាឥស្សរជនមួយរូបដែលនៅវៀតណាមខាងជើង ហើយគាត់នៅតែមានវត្តមានពីឆ្នាំ៥៥ ទៅដល់ទសវត្សរ៍៦០ ហើយចូលរួមនៅក្នុងខាងគណៈមជ្ឈិម។

[១១:២៣:០២]

**ស៖** បាទ សូមអរគុណ។ សំណួរបន្តទៅទៀតចង់សួរលោកថា មនុស្សដែលជាសមាជិករបស់ខ្មែរឥស្សរៈ នៅក្នុងឯកសារ "សោកនាដកម្មនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា" D108/50/175 ជាភាសាខ្មែរ ERN 00701668 នៅទំព័រទី១--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យលោក ហុង គីមសួន អានលេខឯកសារម្ដងទៀតលោកប្រធាន។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** បាទ ឯកសារលេខ D108/50/1.75។ លេខ ERN ភាសាខ្មែរ 00701668, ERN ជាភាសាអង់គ្លេស 00193116 នៅក្នុងទំព័រទី១ និយាយអំពីខ្មែរឥស្សរៈចំនួនពីររូបដែលជិតស្និទ្ធជាមួយនឹងវៀតមិញខ្លាំងជាង ដាប ឈួន គឺលោក ស៊ីវ ហេង និងលោក ឡុង ប៊ុនរួត ដែលក្រោយមកមានឈ្មោះថា នួន ជា។ សំណួរខ្ញុំចង់សួរថាតើលោកទាំងពីរនាក់នេះ ក្លាយខ្លួនពីខ្មែរឥស្សរៈមកជាសកម្មជនឬក៏មន្ត្រីនៃបក្សកុម្មុយនីស្តកម្ពុជាមែនឬទេ?

[១១:២៥:០២]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ជាការពិត ដាប ឈួន គាត់គឺជាសមាជិករបស់ឥស្សរៈ ក្រោយមកចូលជាមួយនឹង សីហនុ នៅពេលដែលគាត់បះបោរប្រឆាំងនឹង សីហនុ នៅក្នុងឆ្នាំ១៩៦៩។ ដូច្នេះហើយការចលនាប្រឆាំងនឹងកុម្មុយនីស្តគឺក៏ពាក់ព័ន្ធមេដឹកនាំខាងនៅសៀមរាប ឡុង ប៊ុនរួត នោះគឺឈ្មោះបុគ្គលមួយរូប នួន ជា បានវិលត្រឡប់មកពីប្រទេសថៃ ហើយធ្វើការងារនៅក្នុង -- ខ្ញុំមិននិយាយកាលបរិច្ឆេទឲ្យបានច្បាស់លាស់នោះទេគឺ ត្រឡប់មកវិញធ្វើការងារនៅក្នុង ប្រហែលជានៅក្នុងឆ្នាំ៤៩-៥០ ហើយជួយនៅក្នុងការជ្រោមជ្រែងនេះ។ គាត់គឺជាសមាជិកមួយរូបនៅក្នុងកុម្មុយនីស្តថៃ។ អ្វីដែលខ្ញុំអាចជម្រាបបាននោះគឺថា គឺគាត់ធ្វើការងារជាមួយនឹងខាងពាយ័ព្យ ដែលកន្លែងគាត់មកពីទីនោះ។ ដូច្នេះកន្លែងនោះហើយ ដែលយើង

ឃើញមានការដាក់ពិន័យដោយវៀតណាម ឯកសារជាច្រើននៅក្នុងអំឡុងពេលនោះ គឺបាននិយាយអំពីបដិវត្តន៍របស់កម្ពុជា។ ខ្ញុំគិតថា បុគ្គលមួយរូបដែលនៅក្នុងនោះគឺមានទទួលការគាំទ្រពីថៃ ចាប់ពីសង្គ្រាមលោកទី២ ដែលសង្គ្រាមលោកលើកទី២ នេះក៏បង្កជាបញ្ហានៅក្នុងប្រទេសកម្ពុជា ហើយនិងដល់ប្រទេសបារាំង។

[១១:២៦:៤៦]

បុគ្គលរូបនេះគឺជា នួន -- បុគ្គលរូបនេះគឺជាបុគ្គលមួយរូបដែលជាជនស្នេហាជាតិ ហើយរស់នៅក្នុងប្រទេសថៃ។ ហើយគឺនៅពេលនោះ យើងឃើញមានការតវ៉ាប្រឆាំងទៅនឹងអាណានិគមបារាំង ហើយចលនាតស៊ូនេះ គឺបានទទួលរងការទប់ស្កាត់ដោយចលនានាពេលនោះដែរ។ សកម្មភាពជាច្រើនគឺបានបង្ហាញអំពីចំណុចនេះ ក៏ប៉ុន្តែគឺខ្ញុំសូមមិនបញ្ជាក់ច្បាស់ ទៅលើចំណុចនេះទេ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកបានមានប្រសាសន៍ច្រើនហើយ ទាក់ទងជាមួយនឹងសកម្មជន ឬក៏ឥស្សរជន ដែលចេញពីចលនាតស៊ូឥស្សរៈ។ ខ្ញុំសួរលោកមក ទាក់ទងមកដល់ក្រោយខ្មែរបានឯករាជ្យពីបារាំង ពីក្រោយឆ្នាំ១៩៥៤ ឈានមកដល់ឆ្នាំ១៩៦០ឡើងមក គឺលោកមានប្រសាសន៍ទាក់ទងជាមួយនឹងឈ្មោះ ទូ សាមុត ដែលជាលេខាបក្សជំនាន់នោះ ដែលត្រូវបានបាត់ខ្លួន។ តើលោកអាចជម្រាបអង្គសវនាការបានទេថា ការបាត់ខ្លួន ទូ សាមុត នៅក្នុងឆ្នាំ១៩៦២ ហ្នឹង វាទាក់ទងជាមួយនឹងហេតុការណ៍អ្វីខ្លះ ឬក៏មានរឿងយ៉ាងម៉េចខ្លះដែរទេបាទ?

**ឆ៖** នេះជាសំណួរល្អដែលធ្វើឱ្យមានបញ្ហាសម្រាប់ខ្ញុំ។ អ្វីដែលគេដឹងហ្នឹងគឺថា ទូ សាមុត នោះជាលេខាបក្សកុម្មុយនីស្តកម្ពុជា ជាបក្សពលករកម្ពុជានៅក្នុងឆ្នាំ៦២ គេហៅអ៊ីចឹង គឺថាបានបាត់ខ្លួននៅក្នុងឆ្នាំ៦២។ គេសន្និតជាទូទៅថា គេយល់ថា គេសម្លាប់គាត់ ដោយក្រុមនគរបាលសម្តេច សីហនុ ដោយសារថា គាត់ជាជនកុម្មុយនីស្ត ហើយអ៊ីចឹងហើយគឺជាការយោងដែលថា មុខតំណែងគាត់ជាលេខាបក្សពលករកម្ពុជា។ គេមិនបានប្រកាសទៅដល់អាជ្ញាធរសាធារណៈទេកាលនោះ។ ហើយតំណែងរបស់គាត់គេបានដឹង គឺដូចជា សាឡុត ស ហើយនិង នួន ជា ពេលក្រោយលោក -- លើកលែងតែពេលក្រោយមកបានគេដឹង។

[១១:២៨:០៥]

ប៉ុន្តែអ្នកដែលបានស្គាល់ ទូ សាមុត តែងតែនិយាយអំពីការស្នេហាជាតិ ភាពស្មោះត្រង់ ហើយគាត់ពលិកម្មចំពោះចលនាកុម្មុយនីស្ត ហើយគាត់បាននាំសមាជិកមួយចំនួន ហើយដែលក្លាយទៅជា

មេដឹកនាំកុម្មុយនីស្តកម្ពុជា ហើយបន្ទាប់មក ប៉ុល ពត មកពីប្រទេសបារាំង ក្លាយទៅជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន។ ហើយបន្ទាប់ពីនោះមក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទិដ្ឋភាពនៃជីវិតរបស់គាត់ហ្នឹង គឺត្រូវបានគេលុបបំបាត់ ហើយយើងពិនិត្យឃើញថា នៅក្នុងដំណាក់កាលចលនាកុម្មុយនីស្តកម្ពុជា គឺលេខា គឺមិនមែនជាមនុស្សណាដែលជាប់ទំនាក់ទំនងជាមួយវៀតណាមទេ។ ហើយមានអ្នកខ្លះគេគិតថាការពិភាក្សាក្នុងទសវត្សរ៍ឆ្នាំ៨០ អំពីបញ្ហាវន្តដែលដឹងរឿងខ្មែរក្រហមនោះ គឺថា ប៉ុល ពត ពាក់ព័ន្ធនៅក្នុងការសម្លាប់ ឬក៏ការបាត់ខ្លួនរបស់ ទូ សាមុត។ ខ្ញុំមិនយល់ថា បែបនោះទេ។ ហើយមិនមានបញ្ញវន្តណាដែលទាញសេចក្តីសន្និដ្ឋានថា ប៉ុល ពត ពាក់ព័ន្ធនឹងការសម្លាប់ ទូ សាមុត នោះទេ។

**ស៖** ជាបន្តខ្ញុំ សូមសួរលោក ដោយសាររឿងនេះទាក់ទងគ្នាជាមួយនឹងការបាត់ខ្លួន ទូ សាមុត ដែរ ហើយនៅក្នុងកាលៈទេសៈនោះ គឺមាន ប៉ុល ពត មានលោក នួន ជា ដែលសមាជិកក្នុងបក្សដែរ។ សំណួរខ្ញុំចង់សួរថា ដោយសារលោក នួន ជា ពេលនោះស្និទ្ធជាមួយនឹង ទូ សាមុត។ តើលោកអាចជម្រាបអង្គសវនាការបានទេថា ហេតុអ្វីបាន នួន ជា មិនឡើងជាលេខាបក្ស បែរជា ប៉ុល ពត ឡើងជំនួសវិញបាទ?

[១១:៣១:០៧]

**ឆ៖** នេះជា នៅជាអាថ៌កំបាំងនៅឡើយ។ ខ្ញុំយល់ថាវាមានបញ្ហាមួយចំនួនកើតឡើងដែលថា នួន ជា ផ្អែកទៅលើប្រវត្តិរូបរបស់គាត់ គឺថាវាមានបញ្ហាមួយចំនួន។ ដូច្នេះហើយប្រវត្តិរូបនេះហើយដែលធ្វើឲ្យគាត់មិនអាចក្លាយទៅជាៗមុខតំណែងលេខាបក្សបានទេ ពីព្រោះសមាជិកគេមិនព្រមជាមួយគាត់។ ហើយគាត់ថាមិន គាត់មិនបានបង្ហាញពីភាពដាច់ខាត ដែលថាសំខាន់ត្រូវតែៗធ្វើលេខាបក្សនោះ។ ឆន្ទៈហើយនិងសមត្ថភាពរបស់គាត់ក្នុងការបម្រើតំណែងជាអ្នកទីពីរ គឺថាវារយៈពេលយូរមកហើយក្នុងលំដាប់ទីពីរ ដោយគាត់មានភាពស្មោះត្រង់ទៅនឹងបក្សកុម្មុយនីស្តអន្តរជាតិ ហើយនិងបក្សកុម្មុយនីស្តកម្ពុជាផងដែរ។ អ៊ីចឹងគាត់ស័ក្តិសមនៅក្នុងតំណែងទីពីរ។ ហើយតំណែងទីមួយនោះគឺថាត្រូវតែអ្នកផ្សេង ហើយលទ្ធភាពនោះគាត់ -- ហើយគាត់មិនមានអំណាចបញ្ជាដោយផ្ទាល់ ជាអ្នកទីមួយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

**ស៖** បាទ សូមអរគុណ។ ជាបន្តទៀត ខ្ញុំសូមសួរលោកថា នៅក្នុងចន្លោះឆ្នាំ១៩៦០ មកដល់ឆ្នាំ១៩៧០ គឺវាមានព្រឹត្តិការណ៍ ឬក៏ព្រឹត្តិហេតុផ្សេងៗ ដែលនាំឲ្យមានការរត់ចូលព្រៃនៃមេដឹកនាំ ឬក៏មេធំៗនៃបក្សកុម្មុយនីស្តកម្ពុជា។ ជាសំណួររបស់ខ្ញុំចង់សួរលោកថា នៅក្នុងចន្លោះឆ្នាំ១៩៦០ មកទល់

នឹង១៩៧០ នេះ គឺជាពេលវេលាដែលរបបសង្គមរាស្ត្រនិយម ឬក៏យើងចង់និយាយថាជារបបដឹកនាំដោយសម្តេច នរោត្តម សីហនុ។ អ៊ីចឹងជាសំណួរខ្ញុំសួរថាតើការនាំឲ្យមេធំៗនៃបក្សកុម្មុយនីស្តកម្ពុជារត់ចូលព្រៃហ្នឹង មានហេតុភេទយ៉ាងម៉េចខ្លះ ដែលត្រូវបានគាត់រត់ចូលព្រៃបាទ?

[១១:៣៣:៣២]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ ចាំស្តាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់ខាងមេធាវីការពារក្តី។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំបាទយល់ឃើញថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចមានមានការយល់ច្រឡំចំពោះ ដូចថាមេដឹកនាំកុម្មុយនីស្តរត់ចូលព្រៃ។ ចំណុចនេះ សូមឲ្យបញ្ជាក់ឲ្យច្បាស់ថាជានរណាផងបាទ ដើម្បីឲ្យអង្គជំនុំជម្រះអាចធ្វើការវិនិច្ឆ័យបាន។ សូមអរគុណ។

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណ។ ខ្ញុំសូមកែតម្រូវនូវពាក្យរបស់ខ្ញុំបាទអម្បាញ់មិញឡើងវិញ ដោយសារក្នុងនោះវាមានមនុស្សច្រើន ដែលជាសកម្មជនក្នុងបក្សកុម្មុយនីស្តកម្ពុជា។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងខ្ញុំសូមកែតម្រូវថា តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា មនុស្សដែលចាត់ទុកថាជាអ្នកជាន់ខ្ពស់ ឬសកម្មជនខ្ពង់ខ្ពស់នៅបក្សកុម្មុយនីស្តកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៦០ ដល់ ១៩៧០ ដែលរត់គេចខ្លួនចូលក្នុងព្រៃនោះ តើលោកមានចាំថាមានឈ្មោះណាខ្លះទេ?

[១១:៣៤:៥១]

**លោក ឆេរីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំគិតថាការបកប្រែឃ្លា ដែលថាចាត់ទុកថាអាចធ្វើឲ្យខ្ញុំច្រឡំបន្តិច ដែលថាគេបានដឹងថាសមាជិកបក្សកុម្មុយនីស្តកម្ពុជានោះ។ សម្តេច សីហនុ មិនបានដឹងថា អ្នកណាជាអ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទេ។ គាត់មិនដឹងថា អង្គការហ្នឹងមានមិនមាន? ប៉ុន្តែគេដឹងថាមានមនុស្សមួយចំនួន ដែលគេហៅថា ខ្មែរក្រហម ប៉ុន្តែព្រះអង្គមិនបានដឹងអំពីអ្នកណាម្នាក់នោះទេ។ ប៉ុន្តែនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ មានសុន្ទរកថាវែងមួយ អ្ហ៎!អត់ទេ វាមានការជំទាស់ទៅនឹងការកាន់អំណាចរបស់គាត់ ហើយ លន់ នល់

ជាយោធា គឺបានផ្តល់បញ្ជីមួយ គឺថាមនុស្សឆ្វេងនិយម ៣៤នាក់នៅក្នុងភ្នំពេញ ដែលគាត់ថា បញ្ជាក់ឈ្មោះ ឬក៏ហៅមកសួរដេញដោល។ ហើយធ្វើឲ្យសម្តេច សីហនុ ហ្នឹងគឺថាអាចអញ្ជើញអ្នកទាំង ៣៤នាក់នេះ មកចូលរួមក្នុងរដ្ឋាភិបាល ឲ្យមានតំណែង។ ប៉ុន្តែមនុស្សពីរនាក់ដែលដាក់ក្នុងបញ្ជីនេះ ក្នុងចំណោម៣៤ហ្នឹង គឺមានឈ្មោះបុរស ឬក៏ថាមនុស្សដែលថាជា គេហៅខ្មោចទាំងបីនោះ។ អៀង សារី ហើយនិង ប៉ុល ពត ជាអ្នកបានបង្រៀននៅក្នុងសាលាឯកជននៅក្នុងភ្នំពេញទេ។ ហើយគាត់មានទំនាក់ទំនងដោយសម្ងាត់ជាមួយបក្សកុម្មុយនីស្តកម្ពុជា។

[១១:៣៦:៣១]

គេគិតថា នេះគឺជាកត្តាបង្ហាញនោះគឺមានន័យថា គាត់នឹង -- ពួកគេអាចគិតថាសម្តេច សីហនុ បានដឹងថាពួកគេមានតំណែងនៅក្នុងបក្ស។ ប៉ុន្តែតាមពិតសម្តេច សីហនុ មិនដឹងទេ។ ប៉ុន្តែ សុន សេន ជាមនុស្សម្នាក់ទៀតដែលបញ្ជាក់ផងដែរនៅក្នុងការសន្និដ្ឋានថា ប៉ុល ពត, អៀង សារី មិនបានដាក់ឈ្មោះនៅក្នុងបញ្ជីរបស់ខ្មែរក្រហមទេ។ ដូច្នេះមនុស្សបីនាក់នេះ បានរត់គៀសខ្លួនទៅភាគខាងលិចនៃកម្ពុជា ហើយក្រោយមកគេបានទៅលាក់ខ្លួនជាមួយមូលដ្ឋានទ័ពវៀតណាមកុម្មុយនីស្ត។ ហើយខ្ញុំបានដាក់លេខយោងជាឧបសម្ព័ន្ធនៅក្នុងសៀវភៅ "បងទីមួយ"នោះ។

ចំណុចដែលឲ្យមានសារៈសំខាន់ដល់តុលាការនៅថ្ងៃនេះ គឺថាអ្នកដែលមិនបានរត់ចូលព្រៃនោះ គឺ ខៀវ សំផន ហើយនិង នួន ជា។ ខៀវ សំផន ពីព្រោះគាត់ថា គាត់ៗមានតំណែង គឺថាគាត់មានសុវត្ថិភាពអំពីអនាគតរបស់គាត់នៅក្នុងភ្នំពេញនៅឡើយ។ ហើយ នួន ជា គឺថានៅក្នុងចំណោម៣៤ មិនមានបញ្ជាក់ពី នួន ជា ទេ។ វាមានលក្ខណៈសម្ងាត់ជាង ប៉ុល ពត ទៅទៀត។ គាត់មិនបានបង្រៀន មិនមានកំណត់ត្រាណា បញ្ជាក់ថាគាត់បានបង្រៀននៅក្នុងឯកសារទេ គឺថានៅក្នុងឯកសារហ្នឹងមិនមាន។ ហើយជាគាត់ជាបុគ្គលនេះ មិនមានឈ្មោះនៅក្នុងបញ្ជីអ្នក៣៤។ ដូច្នេះ គាត់នៅលាក់ខ្លួន។

[១១:៣៨:១៧]

គាត់ និង ប៉ុល ពត ប្រហែលជាមានការយល់ព្រមគ្នាថា ក្នុងពេលណាមួយត្រូវការរក្សាការសម្ងាត់។ គឺថាមិនត្រូវបញ្ជាក់ពីសមាជិកនៅក្នុងទីក្រុង ដើម្បីបន្តថាត្រូវធ្វើសកម្មភាពអ្វី ដើម្បីឲ្យគេដឹងនោះទេ។ មេដឹកនាំមួយចំនួនបានរត់គេចខ្លួន ហើយក្រោយមកសមាជិកផ្សេងទៀតទៅជាមួយ ប៉ុន្តែទាំងពីរ ដែលមិនបានរត់គេចខ្លួននោះ ខៀវ សំផន និង នួន ជា។ ប៉ុន្តែពេលក្រោយមក ខៀវ សំផន ក៏បានរត់ទៅក្នុងព្រៃ គឺថាក្រោយពីឆ្នាំ៦២។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ចំណុចមួយដែលខ្ញុំចង់លើកឡើងជាមួយសាស្ត្រាចារ្យ ឆេនដ៍ល័រ ជូនអង្គជំនុំជម្រះផងដែរ ថាគាត់ជាអ្នកសាក្សីជំនាញ ហើយខ្ញុំយល់ថាសហព្រះរាជអាជ្ញាបានលើកឡើងហើយ គាត់អាចប្រើទស្សនៈថាគិត ឬក៏គាត់សន្និដ្ឋាន។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ថា ប្រសិនបើគាត់និយាយអំពីជាឧទាហរណ៍ អំពីកូនក្តីរបស់ខ្ញុំ គាត់ត្រូវបែងចែកឲ្យច្បាស់ថានៅពេលណា ពេលណាដែលគាត់សន្និដ្ឋាន ឬគាត់សន្មត ឬក៏ពេលណាគាត់ច្បាស់តាមឯកសារ។ ក្នុងករណីនេះ ខ្ញុំឮសាស្ត្រាចារ្យនិយាយថា នួន ជា មិនបានទៅនៅព្រៃទេ ដោយសារគាត់ ពីព្រោះគាត់គិតថា នួន ជា គាត់មានសុវត្ថិភាពជាដើមអ្វីចឹង។

[១១:៣៩:៥៣]

ខ្ញុំយល់ថា សាស្ត្រាចារ្យ ឆេនដ៍ល័រ គាត់មានទស្សនៈបែបនេះ ប៉ុន្តែមានឯកសារ ព័ត៌មានអ្វីដែលគាំទ្រ? បើមិនមានឯកសារគាំទ្រទេ សូមលោកប្រុងប្រយ័ត្នកុំបញ្ជាក់ថា ជាការសន្និដ្ឋានរបស់គាត់ថាកូនក្តីរបស់ខ្ញុំបែបនេះបែបនោះ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤០:៤៧]

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញតទៀត មិនមានបញ្ហាអ្វីទេ។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមអរគុណលោក ដេវីដ ឆេនដ៍ល័រ ដែលលោកបានរៀបរាប់ទាក់ទងជាមួយនឹងដំណើរការវិវិត្តន៍របស់មន្ត្រី ឬសកម្មជននៃបក្សកុម្មុយនីស្តកម្ពុជាបាទ។ បន្តទៀតខ្ញុំសូមសួរលោកថា ដោយសារមានការគេចខ្លួន ឬក៏មានឈ្មោះនៅក្នុងបញ្ជីនៃរបបដឹកនាំដោយសម្តេច នរោត្តម សីហនុ ទើបមានការរត់ចូលព្រៃនៃមន្ត្រី ឬក៏សកម្មជននៃបក្សកុម្មុយនីស្តកម្ពុជានោះ។ ខ្ញុំចង់សួរលោកបន្ថែម ថាតើនៅក្នុង

អំឡុងទសវត្សរ៍៦០ មកទល់ទសវត្សរ៍៧០ ឬក៏និយាយឲ្យចំ១៩៦០ មកដល់១៩៧០ ដដែលហ្នឹង តើនៅក្នុងប្រទេសកម្ពុជាក្រោមការដឹកនាំរបស់សម្តេចព្រះនរោត្តម សីហនុ មានការធ្វើទុក្ខបុកម្នេញ ឬក៏ចាប់កាប់សម្លាប់ដោយសារតែការយកដី ឬក៏យកទ្រព្យសម្បត្តិ ឬក៏ចាប់ដោយគ្មានមូលហេតុ ឬយ៉ាងម៉េចដែរ? លោកអាចបំភ្លឺដល់អង្គសវនាការបន្តិចបានទេ ចន្លោះនេះបាទ?

[១១:៤២:១២]

**លោក ផេរីង ផេនដ៍ល័រ៖**

**ឆ៖** បាទ មាន។ តាមពិតយើងបានដឹងពីខាងដើមហើយ។ សំឡូតនៅឆ្នាំ១៩៦៧ គឺមានការបះបោរ គឺថាមានភស្តុតាងជាច្រើន ដោយថាមានកូនសិស្ស សមាជិក អ្នកគាំទ្រចិន នៅក្នុងទីក្រុងភ្នំពេញដែលប្រកាន់យកបដិវត្តន៍តាមលទ្ធិម៉ៅ ត្រូវរងការធ្វើទុក្ខបុកម្នេញ ធ្វើការបាប ឬក៏សមាជិករបស់គេរងការធ្វើបាប គេចាប់ដាក់គុក ហើយ ឌុច ក៏បានជាប់គុកដែលនៅសម័យនោះ។ ហើយគេបានចាប់ប្រមូលពួកអ្នកទាំងនោះ ហើយមានការបំភ្លឺនៅក្នុងសំណួររបស់លោក ខ្ញុំចង់ឲ្យច្បាស់ថា នៅក្នុង៣៤នាក់ នេះមិនទាន់បញ្ជាក់ថាជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ។ គេគ្រាន់ហៅពួកហ្នឹងថា ជនដែលបង្កគ្រោះដល់សង្គមកម្ពុជា ជាជនឆ្វេងនិយម។ គឺថាវាមានអ្នកកាសែតផងដែរ ហើយសមាជិករដ្ឋសភាខ្មែរ ដូចជាលោក ខៀវ សំផន ហ្នឹង។ គឺថាមនុស្សចំនួន ដែលដឹងថាអ្នកនោះមានទស្សនៈគាំទ្រខាងឆ្វេងនិយម។ គេ-- នៅពេលនោះគឺគេពិបាក មិនពិបាកនឹងរកទេ គឺថាគេស្តាប់ទស្សនៈរបស់គេថ្នាក់ជាតិ គឺថាគេគាំទ្រឆ្វេងនិយម គេប្រឆាំងអាមេរិក ហើយគេគាំទ្រចិន ជាដើមអ៊ីចឹង។ ហើយទស្សនៈទាំងអស់នោះគឺបញ្ញវន្តផ្សេងទៀតក៏បានធ្វើតាម ដែលថាអ្នកឆ្វេងនិយមនៅកម្ពុជាច្រើន ច្រើនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំនិយាយថា អ្នកដែលបានរត់គេចខ្លួន គឺអ្នកដែលគេហៅថាជាអ្នកឆ្វេងនិយម។ តាមពិតគឺមានសមាជិកសម្ងាត់របស់បក្ស -- មជ្ឈិមបក្សដែរមាន សុន សេន, អៀង សារី, ប៉ុល ពត ហើយមានអ្នកផ្សេងទៅជាមួយគាត់ ទៅតាមគាត់នៅពេលក្រោយ។ ប៉ុន្តែ នួន ជា នៅក្នុងភ្នំពេញនៅឡើយ ខ្ញុំអាចផ្តល់ឯកសារ។ ឯកសារហ្នឹងគឺថា ហើយជាប្រវត្តិរូបរបស់គាត់ អាចថាហ្នឹងគាត់ថាគាត់នៅភ្នំពេញ ហើយគឺគាត់ជាអ្នកនៅក្នុងភ្នំពេញមែន មិនមែនជាសន្ទតរបស់ខ្ញុំទេ។ នេះជា -- ហើយគាត់មានមូលហេតុក្នុងការនៅក្នុងភ្នំពេញ មិនរត់ មិនគេចខ្លួន។ អ៊ីចឹងខ្ញុំមើលឃើញថា ខ្ញុំគិតថា គាត់មានយល់ថា អាចមានសុវត្ថិភាព តាមការដែលគាត់រក្សាការសម្ងាត់បាទ។

[១១:៤៤:៥៤]

**ស៖** ខ្ញុំសូមសួរលោកបន្តិច ដោយសារវាទាក់ទងគ្នាសំណួរនេះ។ អ៊ីចឹងឈ្មោះ ឬក៏សកម្មជនខ្លះដែលលោកបានជម្រាបអង្គសវនាការអំមិញហ្នឹង វាមិនសុទ្ធសឹងតែជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជាទាំងអស់នោះទេក្នុងចំណោម ៣៤នាក់។ ក៏ប៉ុន្តែមានន័យថាមានដែរនៅក្នុងហ្នឹង។ សំណួរខ្ញុំចង់សួរថា នៅក្នុងពេលតស៊ូហិង្សាប្រដាប់អាវុធចន្លោះឆ្នាំ១៩៦៧ មកទល់នឹងឆ្នាំ៦៩ កៀកមកឆ្នាំ១៩៧០ ហើយ គឺមានចលនាបះបោរតស៊ូដោយអាវុធដូចលើកឡើងថានៅសំឡូតជាដើមនោះ។ តើនេះជាការផុសគំនិតដោយខ្លួនឯង ប្រជាពលរដ្ឋ ឬក៏មានអ្នកទៅដឹកនាំឲ្យប្រជាពលរដ្ឋធ្វើអ៊ីចឹងបាទ?

**ឆ៖** ខ្ញុំបានបញ្ជាក់ពីខាងដើមមកហើយ គឺថាភស្តុតាងដូចវាផ្ទុយគ្នា។ ហើយបើនិយាយពីភស្តុតាងដែលមានហ្នឹង គឺនេះជាចលនាដែលមានមនុស្សចូលរួម ប៉ុន្តែយើងមិនបានដឹងច្រើនថា វាមានការណែនាំពីណា ដូចថាមេដឹកនាំកុម្មុយនីស្តបានណែនាំឬក៏អត់ទេ។ នេះជាចលនាដែលបរាជ័យ គឺថាសម្តេច សីហនុ បានបង្ក្រាប។ ហើយមិនទំនងថាបក្សកុម្មុយនីស្តកម្ពុជាបាននិយាយថា ជាអ្នកគាំទ្រនោះទេ។ ជាការបរាជ័យគឺថា ពីព្រោះថាបក្សកុម្មុយនីស្តកម្ពុជាគឺគេមិននិយាយអំពីរឿងបរាជ័យទេ គេនិយាយតែពីរឿងជោគជ័យ។ ប៉ុន្តែយើងមិនមានភស្តុតាងគ្រប់គ្រាន់ដែលថា បក្សកុម្មុយនីស្តជាអ្នកទទួលខុសត្រូវទាំងស្រុងនោះទេ។ នេះហើយវាផុសចេញពីប្រវត្តិសាស្ត្រដែលលោកបាននិយាយពីខាងដើម។

[១១:៤៦:៤៩]

ក្នុងសៀវភៅរបស់ខ្ញុំគឺថា ភាពមិនងាយស្រួលក្នុងការដែលគេចាកចេញពីភ្នំពេញនោះ គឺថាភាពងាយស្រួលនោះគឺថាគេមិនពេញចិត្តនឹងការគ្រប់គ្រងស្តេច សីហនុ ហើយគេគិតថាវាអាចនឹងមានសង្គ្រាមវៀតណាម។ ហើយក៏ ឬក៏អាចមានការអំពាវនាវមកពីកន្លែងផ្សេង ឬក៏អាចគេមានគំនិតថាវាត្រូវមានដំណោះស្រាយនៅកម្ពុជា ដែលថាប្រជាជនក្មេងៗមិនមានការងារធ្វើ មានការលំបាកអីជាដើមហ្នឹង។ ក្នុងបរិបទនេះហើយដែលយើងអាចយល់បានថា ការបះបោររបស់ប្រជាជនអាចកើតឡើងពេលខ្លះមិនអាចមានការជំរុញពីបក្សកុម្មុយនីស្តកម្ពុជាក៏មានដែរ។

[១១:៤៧:៣៧]

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរសំណួរហ្នឹងទាក់ទងគ្នាបន្តិច ការដែលមើលឃើញរបស់លោក ឬក៏ការសិក្សារបស់លោក។ នៅក្នុងចន្លោះពេលឆ្នាំ១៩៦៧ ដល់ ឆ្នាំ១៩៧០ ហ្នឹង មុនពេលរដ្ឋប្រហារទម្លាក់សម្តេចន រោត្តម សីហនុ ហ្នឹង តើប្រជាជនពលរដ្ឋខ្មែរហ្នឹងវេទនាអត់បាយហូប អត់ស្លៀកពាក់ អត់ដីធ្លី ដូចការដែលខាងពួកកុម្មុយនីស្តដែលតែងតែលើកឡើងអ៊ីចឹងដែរទេបាទ?

**ឆ៖** ខ្ញុំមិនអាចនិយាយបានទេ ខ្ញុំមិនបានអង្កេតផ្ទាល់ទេ ប៉ុន្តែខ្ញុំបានអាន គឺថាវាមានការអត់ឃ្លានខ្លះដែរនៅសម័យកាលនោះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរទៅដល់នៅក្នុងកំណើតទ័ពបដិវត្តន៍ -- កងទ័ពបដិវត្តន៍ សូមទោស នៅថ្ងៃ១៨ ខែមករា ឆ្នាំ១៩៦៩។ តើហ្នឹងគឺជាចលនាបង្កទ័ពរបស់ពួកក្រុមកុម្មុយនីស្តដែរឬទេបាទ? សូមកែតម្រូវ ថ្ងៃ១៨ ខែមករា ឆ្នាំ១៩៦៨ បាទ។

[១១:៤៩:០៥]

**ឆ៖** ទាក់ទងនឹងសំណួរនេះ គឺថាយើងបានឆ្លើយរួចហើយ អ៊ីចឹងគឺថាគឺវាមានទំនាក់ទំនងជិតស្និទ្ធនេះគឺជាសេចក្តីសម្រេចធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ហើយមានឯកសារបញ្ជាក់ជាចំណុចចាប់ផ្តើមដែលយកគំរូតាមសកម្មភាពប្រដាប់អាវុធដំបូងដែលប្រឆាំងនឹងរដ្ឋាភិបាល។ ខ្ញុំបាននិយាយពីរឿងនេះរួចហើយពីខាងដើម ខ្ញុំមិនបាច់និយាយឡើងវិញទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅដល់បរិបទក្នុងឆ្នាំ១៩៧០ គឺមានន័យថាចាប់ផ្តើមពីពេលដែលមានរដ្ឋប្រហាររបស់របបលោក លន់ នល់ បានទម្លាក់សម្តេចនរោត្តម សីហនុ នៅថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០។ ដល់ពេលនោះមានចលនាប្រឆាំងជាច្រើនពីប្រជាពលរដ្ឋដែលនៅគាំទ្រសម្តេច នរោត្តម សីហនុ។ ក្នុងនេះ ខ្ញុំគ្រាន់តែចង់ជម្រាបសួរលោកថា តើពេលនោះការបង្កើតរដ្ឋាភិបាល មានន័យថារដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលមានអក្សរកាត់ជាភាសាបារាំងថា “ហ្គ្រុង ឬ គ្រុង” ហើយនិងក្រុមចលនាតស៊ូរណសិរ្សរំដោះជាតិ។ តើចលនាទាំងពីរហ្នឹងត្រូវរ៉ូវគ្នាបានដូចម្តេចដែរ សូមលោកបង្ហាញបន្តិចសិនបាទ?

[១១:៥០:៣៩]

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំអាចផ្តល់សេចក្តីលម្អិតបានទេ។ ខ្ញុំបញ្ជាក់ខាងដើម យើងបានពិភាក្សាពីមុនហើយ។ ការកត់ត្រាខ្សែអាត់សម្តេច សីហនុ ដែលបានប្រកាសឲ្យចូលចលនាតស៊ូប្រឆាំងនឹងវៀតណាមនោះគឺថា ផ្សាយជាទូទៅ ជារបាយការណ៍ច្របូកច្របល់អំពីបញ្ហានេះ។ អ្នកខ្លះថាមានការគាំទ្រ អ្នកខ្លះថាមិនមានការគាំទ្រច្រើន។ ដូច្នេះហើយទាក់ទងទៅនឹងចលនាតស៊ូពីដំបូងនោះគឺថាមានការស្មុគស្មាញ។ ជាបឋមគឺថា ដើម្បីស្តារនូវអំណាចរបស់សម្តេច សីហនុ ទេ ដើម្បីធ្វើយ៉ាងណាដើម្បីប្រឆាំងអារម្មណ៍ការយល់ឃើញពីរដ្ឋប្រហារ ជាពិសេសគេថា ព្រះមហាក្សត្រជាទីគោរព ហើយត្រូវកាន់អំណាច ហើយក្រោយមកមានការធ្វើរដ្ឋប្រហារ។ នេះជាព័ត៌មានដែលធ្វើឲ្យភ័ន្តច្រឡំដែរនៅពេលនោះ ហើយបក្ស

កុម្មុយនីស្តកម្ពុជានោះ ដោយហេតុថាគាត់បានចងសម្ព័ន្ធ ឬក៏ថាអាចបន្តការងារថ្មីបន្ទាប់ពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមមកនោះគឺថា គេអាចនឹង -- ក៏គេចូលនៅក្នុងចលនាតស៊ូ ហើយក៏គេអាចនិយាយឃ្លាដូចគ្នានឹងសម្តេច សីហនុ ដែលយើងបានឃើញនៅក្នុងនោះគឺថា គេព្យាយាមដើម្បីកាន់អំណាចតាមគំនិតរបស់គេនោះ។

**ស៖** បាទ សូមអរគុណ។ សំណួរទាក់ទងគ្នានេះដែរ។ ខ្ញុំចង់សួរលោកថា តើពេលដែលមានរដ្ឋប្រហារក្រោយថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ដែលទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ហើយនោះជាឱកាស -- តាមការយល់ឃើញរបស់លោក តើលោកអាចបញ្ជាក់បានទេថា ជាឱកាសដែលក្រុមរណសិរ្សរំដោះជាតិកម្ពុជា ឆក់យកឱកាស យកប្រជាប្រិយភាពលើចលនា ឬក៏រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជារបស់សម្តេច សីហនុ ដែរឬទេបាទ?

[១១:៥៣:០៣]

**ឆ៖** ខ្ញុំគិតថា ខ្ញុំបានពន្យល់នៅក្នុងចម្លើយមុនហើយ។ ក្នុងពេលដែលគេកាន់អំណាចដែលអ្នកគាំទ្រសម្តេច សីហនុ គឺថាមានភស្តុតាងជាច្រើន ដែលធ្វើឲ្យគេមានការគាំទ្រនៅក្នុងតំបន់ជនបទ។ នេះជាអត្ថប្រយោជន៍ ចំណុចសំខាន់ដែលគេបានគុណប្រយោជន៍នោះគឺ លន់ នល់ ហើយនិងបុគ្គលិកលក្ខណៈរបស់ លន់ នល់ នោះគឺថាជាអ្នកប្រកាសសង្គ្រាម ប៉ុន្តែមិនផ្លូវការទេ ប្រឆាំងនឹងវៀតណាម គឺក្នុងរយៈ -- មានបម្រាមគោចរ ៤៨ម៉ោងជាដើមហ្នឹង។ ហើយខ្មែរក្រហម ចលនារបស់គេនោះគឺអាចចូលរួមជាមួយអ្នកទាំងនោះ ហើយគេប្រើប្រព័ន្ធឃោសនា ការឃោសនា ដូចគាំទ្រ សីហនុ ដែរ ដោយសម្ងាត់ ប៉ុន្តែគេបានរួមជាមួយសម្តេច សីហនុ ដោយសម្ងាត់ ប៉ុន្តែគឺថា មិនត្រូវបាញ់សម្លាប់កងទ័ពណាមួយ។ អ៊ីចឹងហើយរដ្ឋប្រហារហ្នឹងគឺ អាចធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជា ទទួលបាននូវអត្ថប្រយោជន៍ដូចដែលលោកសួរហ្នឹងមែន។

[១១:៥៤:២១]

**ស៖** បាទ សូមអរគុណ។ នៅពេលនោះដែរ ខ្ញុំសូមសួរលោកថា តើលោកអាចពន្យល់បានទេ ឬក៏លោកអាចដឹងបានទេថា ប្រជាពលរដ្ឋដែលប្រើពាក្យថា រត់ចូលព្រៃម៉ាគី ដែលទៅគាំទ្រចលនាតស៊ូប្រឆាំងនឹងរបប លន់ នល់ តើភាគច្រើន ភាគច្រើននោះប្រជាពលរដ្ឋយល់ឃើញថា ខាងរណសិរ្សរំដោះជាតិកម្ពុជា ដែលឈ្មោះនេះគ្រាន់តែជាការ អ៎! គឺជាចលនារបស់បក្សកុម្មុយនីស្តកម្ពុជាដែរនោះ គេយល់ទេ យល់ថា អត្តន័យ ឬក៏ការកៀងគរចូលព្រៃហ្នឹង ថាការចលនាតស៊ូរបស់គេហ្នឹង ជួយខាង

សម្តេច សីហនុ ឬជួយខាងខ្មែរក្រហមបាទ?

[១១:៥៥:២២]

**ឆៈ** ខ្ញុំក្រែងថាមិនអាចឆ្លើយបាន ដោយសារមិនមានឯកសារ ប៉ុន្តែជាបឋមហ្នឹង គឺថាអ្នកដែលបានគេចខ្លួនហ្នឹងគឺ ដោយថាស្ថានភាពនៅក្នុងសង្គមហ្នឹងកែប្រែលឿនពេក គេមិនអាចយល់គឺថា ភាគច្រើនបានស្តាប់ ហើយបានគាំទ្រសុន្ទរកថារបស់សម្តេច សីហនុ។ យើងមិនដឹងថាមានប៉ុន្មាននាក់ទេអ្នកទាំងអស់នេះនោះ ហើយយើងមិនដឹងថាតើអ្នកប៉ុន្មាននាក់ដែលនៅក្នុងចលនាតស៊ូ ហើយក៏បានវិវត្តន៍ទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែមានខ្លះចូលអ៊ីចឹងមែន ប៉ុន្តែមានអ្នកខ្លះក៏បានដកខ្លួនចេញពីចលនាតស៊ូនៅពេលដែលគេដឹងច្បាស់ថា អាហ្នឹងមិនមែនជាបម្រើគំនិតរបស់រណៈ -- របស់សម្តេច សីហនុ នោះទេ។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ឲ្យបានច្បាស់ទេ ទៅលើចំនួនពីឯកសារនោះទេ ព្រោះខ្ញុំមិនមានឯកសារបញ្ជាក់បែបនោះ។

[១១:៥៦:១៥]

**សៈ** បាទ សូមអរគុណ។ បន្តទៅទៀត ខ្ញុំសូមជម្រាបសួរលោកថា នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា “បងធំទី១” ជាឯកសារ E3/17 ក្នុងទំព័រ១៨៦, ERN ជាភាសាខ្មែរ 00821758, និង ERN ជាភាសាអង់គ្លេស 00393007 ដែលនិយាយអំពីកងទ័ពកុម្មុយនីស្តមានវិន័យខ្លាំងជាងកងទ័ពរបស់សាធារណរដ្ឋខ្មែរ។ មានន័យថាសាធារណរដ្ឋខ្មែរ គឺរបបលោក លន់ នល់។ ប៉ុន្តែក្រុមទាំងពីរនេះ បានប្រព្រឹត្តអំពើលួចប្លន់ ជ្រើសរើសទ័ព និងធ្វើបាបប្រជាជនស៊ីវិលដូចគ្នា។ តើនៅក្នុងនេះ លោកអាចជម្រាបជូនបានទេថា បើនិយាយពីវិន័យកងទ័ពកុម្មុយនីស្ត វិន័យខ្លាំងជាង ហេតុអីលោកសរសេរអំពី មានប្រព្រឹត្តអំពើលួចប្លន់ ឬក៏ជ្រើសរើសទ័ព ឬក៏ធ្វើបាបប្រជាជនស៊ីវិលដូច្នេះបាទ? លោកអាចពន្យល់បានទេបាទ? ខ្ញុំអាចជូនឯកសារទៅលោក បើសិនជាលោកត្រូវការបាទ។

[១១:៥៧:៥៤]

**ឆៈ** ខ្ញុំ -- នេះជាភស្តុតាង ដ៏ល្អដែលថាជាកងទ័ព ដែលមិនបានបណ្តុះបណ្តាល មិនបានហ្វឹកហ្វឺន ហើយៗក៏ជាពិសេសគឺថា គេអនុវត្តសកម្មភាពប្រឆាំងនឹងជនជាតិភាគតិចវៀតណាម។ គេមិនមិនបានហ្វឹកហ្វឺនត្រឹមត្រូវ ហើយមិនមានវិន័យត្រឹមត្រូវ ហើយមិនមានអាវុធគ្រប់គ្រាន់ដើម្បីការពារប្រទេស។ នេះគឺជា -- នេះជាសេចក្តីសម្រេចគ្រោះថ្នាក់មួយសម្រាប់ពួកគាត់ ដែលគាត់ថាមិនមានកងទ័ពការពារប្រទេស ជ្រើសរើសដោយបន្ទាន់បែបនេះ ហើយគេប្រឈមមុខនឹងការខ្វះកងទ័ព ហើយ

គេជ្រើសរើសបន្ទាន់ ហើយបូករួមជាមួយទ័ពដែលមាននោះ។ ជាមួយ -- ហើយមិនមានរឿងរ៉ាវអំពីអ្នកជនភៀសខ្លួន ហើយនិងឯកសារផ្សេងៗទៀតនោះទេ។ មានស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ ហើយមានរបាយការណ៍ដែលរាយការណ៍មកពីវៀតណាម ដែលនិយាយថា ភាគីទាំងពីរហ្នឹង គឺភាគីម្ខាងទៀត គឺថាមានវិន័យល្អជាង មិនសូវប្រព្រឹត្តប្រឆាំងនឹងជនស៊ីវិល ហើយគេបានគោរពតាមវិន័យពុទ្ធសាសនាជាដើមហ្នឹង។ ហើយក៏ជាកត្តាដែលធ្វើឲ្យពួកគេមានប្រជាប្រិយភាពដែរ។

[១១:៥៩:៣១]

**ស៖** បាទ សូមអរគុណ។ សូមលោកសម្រួលបន្តិចសិន។ ខ្ញុំអាចបន្តបានទេលោក? បាទ ខ្ញុំបាទសូមអរគុណ និងសូមបន្តសំណួរទៅទៀត។ ខ្ញុំបាទសូមលោតសំណួរបន្តិចទៅចុះ ព្រោះទាក់ទងជាមួយនឹងម្សិលមិញនេះ គឺជាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ លោកបានជម្រាបអង្គសវនការស្ដីពីការប្រជុំរបស់មជ្ឈិម ឬក៏គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដែលធ្វើនៅខេត្តកំពង់ធំ ជិតភ្នំសន្ទុកនោះ។ ហើយខ្ញុំបានឮថា ពេលនោះមានការសម្រេចចាត់តាំង ឬក៏ជ្រើសតាំងលោក ខៀវ សំផន, សុនសេន និងលោកម្នាក់ទៀត ខ្ញុំចាំឈ្មោះមិនអស់។ ហើយពេលនោះ ពីម្សិលមិញនោះ លោកបានជម្រាបថា ពេលហ្នឹងមានការសម្រេចឲ្យលោក អៀង សារី ហ្នឹងទៅនៅជិតជាមួយនឹងសម្ដេចព្រះ នរោត្តមសីហនុ នៅប៉េកាំង។ តើក្នុងនេះ ការមានប្រសាសន៍របស់លោកហ្នឹង ការបញ្ជូនលោក អៀង សារី ទៅនៅជាមួយសម្ដេចព្រះនរោត្តម សីហនុ ហ្នឹងតើដើម្បីអី? ឬក៏មានហេតុការណ៍អីទើបធ្វើយ៉ាងនេះបាទ?

[១២:០១:០៨]

**ឆ៖** មូលហេតុសំខាន់នោះ គឺដើម្បីឲ្យសម្ដេច សីហនុ នៅក្នុងបន្ទប់មួយ ហើយនៅក្នុងក្រុមរបស់ខ្លួន។ នេះគឺជាបុគ្គលដែលជា -- ដោយគេយល់ថា ព្រះអង្គនិយាយអ្វីគឺធ្វើបែបនោះ គឺអ៊ីចឹងហើយគេឲ្យ ហើយមេដឹកនាំចង់ឲ្យមានការត្រួតត្រាលើសម្ដេច សីហនុ គឺលោក អៀង សារី ជាអ្នកត្រួតត្រា ហើយយើងឃើញច្បាស់ថា វត្តមានរបស់ អៀង សារី នៅប៉េកាំងហ្នឹង គឺផ្ដល់ជាអត្ថប្រយោជន៍ពីទំនាក់ទំនងរវាងចិន ហើយនិងបក្សកុម្មុយនីស្តកម្ពុជា។ ហើយឯកសារជាច្រើនបញ្ជាក់ពីរឿងនេះ។ មានហេតុផលពីរដែលឲ្យគាត់ទៅ ទីមួយគឺ គឺថាធ្វើយ៉ាងម៉េចកុំឲ្យសម្ដេច សីហនុ គឺថាដើរហួសពីព្រំដែនកំណត់នោះ។ គឺថាត្រូវតែប្រកាន់យកមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា គឺថាដោយសម្ងាត់ គឺថាត្រូវរៀបចំឲ្យព្រះអង្គធ្វើអ្វី បំពេញកិច្ចអីនោះ។ ហើយកុំឲ្យព្រះអង្គមានព្រះឱង្ការអ្វីដែលថា ព្រះអង្គថាយល់ថាសមស្របចំពោះជនរួមជាតិនោះ គឺថា ប៉ុន្តែឱកាសខ្លះក៏ព្រះអង្គក៏បាននិយាយជាមួយអ្នកកាសែត គឺថា គាត់និយាយថា

ខ្មែរក្រហមទុកគាត់ជា ដូចជាផ្លែរុក្ខជាតិមួយ កាលណាគេហូបសាច់អស់ គេខ្ទាក់គាត់ចោលគាត់ចោលហើយ។ អាហ្នឹងគឺគាត់បានប្រាប់ទៅអ្នកកាសែតអ៊ីចឹង។ ហើយ អៀង សារី គេចាត់ទុកថាលោក អៀង សារី ជាអ្នកមានសមត្ថភាពដើម្បីតាមដានពិនិត្យសកម្មភាពកម្រិតឲ្យព្រះអង្គរស់នៅ គង់នៅរបៀបម៉េចនោះ។

[១២:០២:៥៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេល -- សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ សូមអធ្យាស្រ័យដែលរំខានពេលវេលាសម្រាកបន្តិច។ ហើយខ្ញុំមុននឹងចប់ ខ្ញុំសូមមានចំណុចកត់សម្គាល់ចំនួនពីរបី ហើយខ្លីៗទេ ហើយនឹងភ្ជាប់នឹងសំណូមពរផងដែរ។

ទីមួយ ខ្ញុំក្នុងខណៈដែលលោកសាស្ត្រាចារ្យ អ្នកជំនាញបានធ្វើសក្ខីកម្មឆ្លើយតបទៅសំណួររបស់សហភាគា ដើមបណ្ដឹងរដ្ឋប្បវេណីអំមិញ ខ្ញុំកត់សម្គាល់ បើសិនជាការកត់សម្គាល់ខ្ញុំខុស សូមអធ្យា-ស្រ័យ។ ហើយបើសិនជាមិនខុសទេ ខ្ញុំសូមមេត្តាកត់សម្គាល់ដូចតទៅ៖

ខ្ញុំកត់សម្គាល់ឃើញថា លោកសាស្ត្រាចារ្យបានអានកំណត់ដៃ ឬកំណត់ត្រារបស់លោកនៅលើនៅចំពោះមុខនៅក្នុងខណៈដែលឆ្លើយនឹងសំណួររបស់ខ្លះសហភាគា។

ខ្ញុំសូមស្នើដល់សាលាដំបូង ស្នើសុំឲ្យលោកសាស្ត្រាចារ្យប្រគល់ជូនដល់សាលាដំបូង ដើម្បីទុកចូលក្នុងសំណុំរឿងនូវកត់ត្រា ឬក៏កំណត់សរសេរដៃរបស់លោកទៅក្នុងសំណុំរឿង ដើម្បីឲ្យភាគីបានដឹងនិងបានត្រៀម។ សំណើខ្ញុំបែបនេះ ក៏វាមិនខុសទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំទៅភាគីលោក នួន ជា ក្នុងខណៈដែលលោក នួន ជា បានអានកត់ហេតុ កំណត់ត្រាដៃរបស់គាត់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ ដែរ។ នេះជាកំណត់ហេតុទីមួយ និងសំណួរ -- អាហ្នឹងសំណូមពររបស់ខ្ញុំ ទីមួយ។

ទីពីរ សាលាដំបូងបានអនុញ្ញាតឲ្យមានតែករណីអ្នកជំនាញទេ ដែលអាចឆ្លើយសំណួរឧបមានវិធីក្នុងករណីចម្លើយស្មានអីអ៊ីចឹងបាន។ ខ្ញុំបាទមិនយល់ទាស់ទេ-- ក៏--

[១២:០៥:២៦]

**ប្រធានអង្គជំនុំ៖**

លោកៗច្រឡំហើយ លោកអាចកែវិញបានណា! សាលាដំបូងដូចមិនបាននិយាយថា អ្នកជំនាញអាចប្រើសម្ដីឧបមានវិធីទេ។ លោកអាចមើលប្រតិចារឹកឡើងវិញ អ្នកជំនាញចូលរួមនៅក្នុងនីតិវិធីដំណើរការនីតិវិធីរបស់តុលាការមានឋានៈខុសពីសាក្សី។ អ្នកជំនាញអាចបង្ហាញនូវការយល់ឃើញរបស់ខ្លួន សេចក្ដីសន្និដ្ឋាន មិនមែនជាការស្មានទេ។ បង្ហាញពីការយល់ដឹងរបស់ខ្ញុំ។ ផ្ទុយទៅវិញទេ ប្រសិនបើជាអ្នកជំនាញថា ខ្លួនបានឃើញ បានដឹងដោយផ្ទាល់នោះ គឺវាខុសតួនាទីជាអ្នកជំនាញហើយ។ កាលណាបានឃើញ បានដឹង ដោយផ្ទាល់ គឺជាសាក្សី ទោះបីជាគាត់មានសមត្ថភាពជាអ្នកជំនាញ ក៏ដោយ ប្រសិនបើគាត់បានដឹងរឿងអីដែលផ្ទាល់ គាត់មិនអាចទៅធ្វើអ្នកជំនាញនៅក្នុងរឿងក្ដីនោះបានទេ។ គាត់អាចចូលរួមនៅក្នុងនាមជាអ្នក -- ជាសាក្សីប៉ុណ្ណោះ។

អ៊ីចឹង សូមលោកប្រើពាក្យឲ្យត្រឹមត្រូវ ហើយលោកអាចមើលពិនិត្យមើលប្រតិចារឹកឡើងវិញ ចៀសវាងមានការភ័ន្តច្រឡំ ក្រែងលោប្រធានសវនាការហ្នឹងមានការភ័ន្តច្រឡំ។ ប៉ុន្តែយើងគិតថា ការប្រើពាក្យពេចន៍នេះ គឺជាក់ច្បាស់ណាស់។

[១២:០៦:៤៩]

**លោក អាង ឧត្តម៖**

សូមអរគុណ អធ្យាស្រ័យ បើសិនជាខ្ញុំបានប្រើពាក្យនេះ ពីព្រោះពាក្យនេះ ខ្ញុំបកស្រាយទៅលើពាក្យដែលគាត់ចាប់ផ្ដើម។ ពាក្យខ្លះថា "គាត់បានគិត" ដូច្នេះ ការគិតហ្នឹង វាចូលការស្មាន។ អ៊ីចឹង បើខ្ញុំបើបកស្រាយខុស សូមអធ្យាស្រ័យ។ ហើយទីពីរ និងជាចុងក្រោយ ហើយតើវិធាននៃការសួរនុំង ផ្លាស់ប្ដូរទៅតាមហ្នឹងដែរអត់? ពីព្រោះខ្ញុំកត់សម្គាល់ឃើញកន្លងមក មានសំណួរនាំមុខច្រើន។ តើករណីសម្រាប់សួរអ្នកជំនាញអ៊ីចឹង យើងសួរសំណួរនាំមុខបានដែរ ឬក៏មិនបាន? លោកប្រធាន អាចស្ដីបន្ទោសខ្ញុំវិញថា ម៉េចក៏ដឹងតាំងពីដើម ម៉េចក៏មិនជំទាស់ ថាមានសំណួរនាំមុខ។ ប៉ុន្តែខ្ញុំចង់ឲ្យមាសំណួរហ្នឹងទៅពីព្រោះសម្រាប់ភាគីផ្សេងទៀត ក៏មានផលប្រយោជន៍ក្នុងការសំណួរនាំមុខហ្នឹង ខ្ញុំបាទមិនយល់ទាស់ទេ។ តែសូមគោលការណ៍ណែនាំសម្រាប់ការសួរអ្នកជំនាញផង។ សូមអរគុណ។

[១២:០៧:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំហាក់ដូចជាងើបលឿនពេក ដោយសារតែសហព្រះរាជអាជ្ញាគាត់ចង់ឆ្លើយតប ដើម្បីជាប្រតិចារឹកគឺ នួន ជា ស្នើសុំតាមដានសវនាការដែលនៅសល់ នៅបន្ទប់ឃុំខ្លួនខាងក្រោម។ ដោយសារតែលោកមានការឈឺចង្កេះ និងការផ្តោតអារម្មណ៍នោះ មិនបានផ្តោតអារម្មណ៍ដូចពេលព្រឹក។ ដូច្នេះហើយ គឺស្នើសុំទៅតាមដានបន្តនីតិវិធីពីចម្ងាយនៅបន្ទប់ឃុំខ្លួនខាងក្រោម។ សូមអរគុណលោកប្រធាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

តើលោកប្រធានចង់ឮស្តាប់ការឆ្លើយតបរបស់ខ្ញុំទៅនឹងអ្វីដែលមេធាវីការពារក្តី អៀង សារី ឡើងដែរឬទេ? ខ្ញុំនឹងលើកឡើងដោយខ្លីទេ ពាក់ព័ន្ធទៅនឹងបញ្ហាសំណួរនាំមុខ។ សហភាគាខាងនោះ គឺគាត់គួរតែដឹងអំពីនីតិវិធី ដែលថាពេលណាគួរតែធ្វើការជំទាស់ទៅនឹងសំណួរដែលបានចោទសួរនោះ។

[១២:០៩:០៥]

បញ្ហាចំពោះកំណត់ត្រារបស់អ្នកជំនាញ អ្វីដែលយើកំណត់សម្គាល់នោះ គឺថាលោក ឆេនដ័ល័រគ្រាន់តែព្យាយាមរំឭកព័ត៌មានដែលសួរទៅកាន់គាត់តែប៉ុណ្ណោះ។ សំណួរស្មុគស្មាញជាច្រើនត្រូវបានចោទសួរទៅកាន់លោក។ ដូច្នេះហើយ វាសមរម្យសម្រាប់គាត់ ក្នុងការកត់ត្រាព័ត៌មាននៅក្នុងសៀវភៅនៅពេលដែលគាត់ឆ្លើយតប។ ដូច្នេះខ្ញុំមិនដឹង ថាតើការផ្តល់កំណត់ត្រានោះ នឹងជួយដល់អង្គជំនុំជម្រះនិងភាគីដោយរបៀបណានោះទេ? ក៏ប៉ុន្តែអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចទៅលើបញ្ហានេះ។ ក៏ប៉ុន្តែព័ត៌មានដែលសំខាន់នោះ គឺថា គឺសៀវភៅ និងអត្ថបទរបស់លោកសាស្ត្រាចារ្យដែលបានមកផ្តល់សក្ខីកម្មយកមកធ្វើជាមូលដ្ឋាននោះ។ ខ្ញុំមិនគិតថា -- ខ្ញុំគិតថា ឯកសារកំណត់ត្រានោះ វាគ្មានប្រយោជន៍អ្វីសម្រាប់យើងនោះឡើយ។ សូមអរគុណ។

[១២:០៩:៥៩]

**លោក អាង ឧត្តម៖**

លោកប្រធានខ្ញុំបាទសូមឆ្លើយតបពីរបីម៉ាត់ទាន។

បាទ សូមអរគុណ ហើយសហព្រះរាជអាជ្ញាអំមិញគិតឆ្លើយថា កំណត់ហេតុហ្នឹងមិនអាចមានផលប្រយោជន៍ទេ។ តែសម្រាប់យើងជាភាគីមេធាវីនេះ គឺមានផលប្រយោជន៍សម្រាប់យើង សម្រាប់ត្រៀមរឿងក្តីរបស់យើងឲ្យត្រឹមត្រូវតាមអ្វីដែលយើងត្រូវធ្វើ។ ហើយខ្ញុំស្នើសុំឲ្យបានកំណត់ត្រានេះនៅ

ឆាប់ជាទីបំផុត បើសិនជាអាចធ្វើល្ងាចរសៀលនេះបាន ជាការប្រសើរ ពីព្រោះយើងត្រូវការយកមកដើម្បីត្រៀមការសួររបស់យើងដល់លោកជំនាញនេះដែរ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១២:១១:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ ទីមួយ អង្គជំនុំជម្រះសូមសម្រេចលើសំណើសុំរបស់មេធាវីជាតិការពារក្តីឲ្យលោក អៀង សារី ថាសំណើសុំនេះអង្គជំនុំជម្រះបដិសេធ ដោយសំណើសុំមិនមានមូលហេតុអីសមស្របទេ។ មូលហេតុទាំងឡាយដែលអង្គជំនុំជម្រះបានជម្រាបរួចហើយក្នុងកិច្ចពិភាក្សាដេញដោល គឺមានចែងច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរ ក៏ដូចជានៅក្នុងវិធានផ្ទៃក្នុង។ ប្រសិនបើខ្លួនយល់ឃើញថាសំណួរឯណាដែលច្បាប់ហាមឃាត់ គឺអាចលើកមតិជំទាស់តវ៉ាដោយបង្ហាញហេតុ។ អង្គជំនុំជម្រះសម្រេចករណីនីមួយៗជាក់ច្បាស់ ហើយបានណែនាំច្រើនលើកច្រើនសារួចហើយក្នុងការអនុវត្តតាំងពីដើមទីនៃការចាប់ផ្តើមសវនាការនៃរឿងនេះ រហូតមកដល់ពេលនេះ។

[១២:១២:៣៨]

បញ្ហាមួយទៀត គឺជាកំណត់ត្រាខ្លីៗដើម្បីឲ្យមានការចងចាំ ហើយនិងងាយក្នុងការឆ្លើយតបពីព្រោះបញ្ហានេះវាស្មុគស្មាញ ហើយសំណួរវែងពាក់ព័ន្ធជាមួយនឹងការរៀបចំនូវការឆ្លើយតបឲ្យបានពេញលេញទៅតាមសំណួរដែលសួរ។ ដូច្នេះការសុំនូវកំណត់ត្រាដៃខ្លីៗ ដោយលោកអ្នកជំនាញ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ ហើយចម្លើយដែលលោកឆ្លើយជាក់ច្បាស់នុ៎ង គឺជាសំឡេងមាននៅក្នុងប្រតិចារឹកគ្រប់គ្រាន់ហើយ។

ហើយចុងក្រោយ គឺអង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់លោក នួន ជា។ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលរសៀលនេះ ដោយមូលហេតុមានអាការៈឈឺចង្កេះ ហើយមានស្ថានភាពថមថយនូវលទ្ធភាពផ្តង់អារម្មណ៍ក្នុងការតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់។

[១២:១៤:០៦]

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាម

រយៈមេធាវីការពារក្ដីរបស់គាត់ សូមទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនេះ។

អង្គជំនុំជម្រះតម្រូវឱ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឱ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

បង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ។

[១២:១៤:៥៦]

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការនេះ ហើយនិងនៅរសៀលនេះទុកឱ្យ នួន ជា តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ដែលមានឧបករណ៍សោតទស្សន៍រៀបចំជាស្រេចសម្រាប់គាត់ ហើយនិងលោក ខៀវ សំផន ឱ្យនាំគាត់ឡើងមកកាន់បន្ទប់សវនាការនេះវិញឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:១៥ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣២:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសូមធ្វើការតបទៅនឹងសំណើសុំរបស់មេធាវី

អន្តរជាតិការពារក្តីលោក នួន ជា កាលពីព្រឹកមិញ ពាក់ព័ន្ធទៅនឹងប្រតិចារឹកនៃកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ។ អង្គជំនុំជម្រះសូមជម្រាបលោកមេធាវីហើយនិងក៏ដូចជាភាគីដទៃទៀតដែរ ថាដំណើរការនៃការចាត់ចែងលើប្រតិចារឹក មិនមែនជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ វាស្ថិតនៅក្នុងការចាត់ចែងរបស់អង្គភាពគ្រប់គ្រងតុលាការ។ ហើយបញ្ហាទីពីរ គឺតាមបទពិសោធន៍ដែលយើងបានធ្វើកន្លងមកនេះ ទំនងជាការដែលធ្វើឆាប់ពេកនោះគឺមិនជាអាចធ្វើទៅបាននោះទេ គឺទាមទាររយៈពេលមួយដែលយើងបានធ្លាប់ទទួល។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏សូមសំណូមពរដល់ខាងអង្គភាពគ្រប់គ្រងតុលាការ សូមជំរុញនូវកិច្ចដំណើរការនៃការធ្វើប្រតិចារឹកនេះដើម្បីឲ្យបានកាន់តែឆាប់កាន់តែល្អ ដើម្បីបម្រើដល់សេចក្តីត្រូវការរបស់ភាគីដែលពាក់ព័ន្ធនឹងរឿងក្តីនេះ។

[១៣:៣៤:១៧]

ហើយទន្ទឹមនឹងនេះផងដែរ គឺអង្គជំនុំជម្រះក៏សូមជម្រាប រំឭកដល់ភាគីផងដែរថា សុទ្ធតែមានបុគ្គលជំនួយការរៀងៗខ្លួន។ ដូច្នេះគឺក្រៅពីប្រតិចារឹក ក៏យើងអាចមានលទ្ធភាពក្នុងការធ្វើការកត់ត្រាឲ្យបានត្រឹមត្រូវជាអតិបរមាតាមដែលអាចធ្វើទៅ ដើម្បីអាចមានលទ្ធភាពក្នុងការបម្រើនូវទិសដៅ និងគោលបំណងនៃកិច្ចពិភាក្សារបស់យើង ក្នុងការរៀបចំសំណួរអីជាដើម។

បាទជាបន្តសូមប្រគល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

[១៣:៣៥:០១]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមគោរពលោកប្រធាន និងលោកស្រីចៅក្រម ព្រមទាំងអង្គសវនាការជាទីគោរពលើកទីពីរ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមជម្រាបសួរលោក ដេវីដ ឆេនដ៍ល័រ។ បន្តទៅទៀតនេះ ខ្ញុំសូមបន្តសំណួររបស់ខ្ញុំពីពេលសម្រាកពិសាអាហារថ្ងៃត្រង់នេះ ជាមួយនឹងសំណួរទាក់ទិនជាមួយនឹងការបញ្ជូនលោក អៀង សារី ទៅនៅជាមួយព្រះបាទសម្តេចព្រះ នរោត្តម សីហនុ នៅប៉េកាំងពីឆ្នាំ១៩៧១។ សំណួរខ្ញុំសួរថា

គោលការណ៍ ឬក៏គោលនយោបាយដែលធ្វើឡើងពេលនោះ តើវាស៊ីសង្វាក់គ្នា ឬក៏ជាគំនិតផ្តួចផ្តើមគិតទុកជាមុនរបស់បក្សកុម្មុយនីស្តកម្ពុជា ក្រោយពេលដែលកាន់កាប់ប្រទេសកម្ពុជាទាំងមូលដែរឬទេ? ដោយសារ -- នៅក្នុងនេះខ្ញុំបាទសូមលើកឡើងអំពីឯកសារ IS6.2 ហើយដែលមាន ERN ជាភាសាខ្មែរលេខ 00072403, ERN ជាភាសាអង់គ្លេសលេខ 00244274 រហូតទៅដល់លេខ 00244278។ ដែលក្នុងឯកសារនេះ ស្តីអំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្សប្រជាជាតិប្រជាធិបតេយ្យរបស់បក្ស ចុះនៅថ្ងៃទី២២ ខែ៩ ឆ្នាំ១៩៧៥។

[១៣:៣៧:០៣]

តែក្នុងនេះទាក់ទងជាមួយនឹងព្រះនាមរបស់ព្រះបាទ នរោត្តម សីហនុ ត្រង់ទំព័រទី៤ ដែលខ្ញុំបាទជម្រាបថា ERN ជាភាសាខ្មែរលេខ 00072403 អម្បាញ់មិញនេះ។ គឺក្នុងនេះ-- ខ្ញុំបាទសូមអានជាភាសាខ្មែរ គឺទីពីរចាប់ពីចំណុច “សីហនុ ក៏បានក្តាប់បាន ដោយគាត់គ្មានអ្វីទាំងអស់ ទាំងសេដ្ឋកិច្ច ទាំងអំណាច។ ដូច្នេះត្រូវរណបយើងទាំងស្រុង ទាំងសម្ភារៈ ទាំងនយោបាយ។ បើប្រៀបធៀបគាត់ទៅនឹងឥទ្ធិពល -- គាត់នៅមានឥទ្ធិពលជាងអ្នកដទៃ។ ពីមុនយើងប៉ានថា បើចេញពីយើងគាត់ត្រូវស្លាប់ ដល់ឥឡូវយើងក្តាប់គាត់បានច្រើនជាងមុនដោយយើងឈ្នះខ្លាំង យើងមានអ្វីៗទាំងអស់ អ្វីក៏នៅលើយើងរហូតដល់វាំង ក៏ជាវាំងយើង ក៏ប៉ុន្តែយើងដំណើរការជាមួយគាត់បានស្រួល។ បច្ចុប្បន្នគាត់ឃើញថាគាត់នៅជាមួយយើងបាន បើប៉ុណ្ណឹងគាត់ពេញចិត្តហើយ ឲ្យតែបាននៅក្នុងប្រទេសខ្លះ ទៅក្រៅប្រទេសខ្លះ។ នេះជាសភាពការណ៍ដែលពន្យារពេលឲ្យយើងពង្រឹង និងពង្រីកកម្លាំងយើងបាន បើថ្ងៃក្រោយគាត់ប្រែប្រួលយើងប្រដូចគាត់បានទៅនឹងក្រមរ។ គឺជ្រុះឯងគ្មាននរណាធ្វើអីទេ ដោយគ្មានការឈឺចាប់”។

[១៣:៣៨:៥១]

ដូច្នេះសំណួរខ្ញុំចង់សួរលោកសាស្ត្រាចារ្យថា គោលនយោបាយដែលបក្សកុម្មុយនីស្តកម្ពុជា -- ទាក់ទងពីសំណួរអំពីថ្ងៃត្រង់មក ថាបញ្ជូនលោក អៀង សារី ទៅនៅជាមួយសម្តេច សីហនុ តើគំនិត ឬក៏បំណង ឬក៏ចេតនារបស់បក្សកុម្មុយនីស្តកម្ពុជា ពីពេលនោះមកទាល់នឹងរំដោះប្រទេសកម្ពុជាបាន ដូចខ្ញុំបាទលើកឯកសារនេះ គឺគេគ្រោងទុកជាមុនដើម្បីយកតែសម្តេច សីហនុ ជាខែល ឬក៏ជានុយអីចឹងដែរឬទេ ជាការយល់ឃើញរបស់លោកបាទ?

**ឆ៖** ខ្ញុំគិតថាយើងអាចសន្និដ្ឋានបែបនោះបាន គឺថាខ្ញុំចង់ឲ្យប្រាកដថា ពួកគេមិនមានការចាប់អារម្មណ៍ឲ្យសម្តេច សីហនុ កាន់អំណាចពិតប្រាកដវិញទេ ដូចដែលខ្ញុំបានបញ្ជាក់ខាងដើមអីចឹងនៅក្នុង

ឯកសារមួយ ហើយនិងនៅក្នុងជើងទំព័រ ដែលថាសៀវភៅដែលនិយាយពី “ផែនការអនាគត របស់ ប៉ុល ពត” គឺថា ពេលដែល ជូ អេនឡាយ បានស្លាប់ទៅនៅឆ្នាំ១៩៧៥ នោះគឺថា ធ្វើឲ្យបក្សកុម្មុយនីស្តកម្ពុជា គឺថាពន្លឿនសម្ពុះដើម្បីប្រឆាំងនឹងសម្តេច សីហនុ។ ដូច្នេះ ពាក្យផ្លូវការនៅឆ្នាំ៧១ គេហៅថា ជាអ្នកសម្របសម្រួល ដែលថា អៀង សារី រៀបរាប់ការងាររបស់គាត់នៅពេលដែលគាត់ទៅនៅប៉េកាំងជាមួយសម្តេច សីហនុ នោះគឺថា យើងមិនអាចឲ្យនិយាយច្បាស់ថា គំនិតរបស់គេគ្រោងមុន ឬមិនមុននោះ គឺខ្ញុំពិបាកនឹងប្រាប់លោក។

[១៣:៤០:៣៦]

**ស៖** បាទ សូមអរគុណ។ សំណួរ ខ្ញុំបាទ សូមបន្តទៅមុខទៀត ទាក់ទងជាមួយនឹងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាប្រធាន តាំងពីតស៊ូចាប់ពីឆ្នាំ ១៩៧០ ដល់ ៧៥ និងរណសិរ្សរំដោះជាតិកម្ពុជា ដែលយើងហៅថា ក្រុមខ្មែរក្រហមនោះ។ តើលោកអាចជម្រាបអង្គសវនាការបានទេថា ការចរចាក៏ដោយ ឬក៏ការព្រមព្រៀងគ្នា មុនពេលរំដោះយកប្រទេសកម្ពុជាបាននៅក្នុងឆ្នាំ១៩៧៥នោះ។ តើព្រះបាទសម្តេចនរោត្តម សីហនុ ឬក៏រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា លោកដឹងថា នយោបាយរបស់ក្រុមរណសិរ្សរំដោះជាតិកម្ពុជា ឬក៏ក្រុមខ្មែរក្រហមនេះ មានផែនការនឹងមិនទទួលយករបបរាជានិយមដែរឬទេ?

**ឆ៖** នៅពេលដែលបានយល់ស្របគ្នានៅជាសាធារណៈហ្នឹង គឺថា គេចង់ទុកសម្តេច សីហនុ នៅក្រោមការត្រួតត្រារបស់ពួកគេ នេះគឺជាចំណុចដែលគេបានបញ្ជាក់នៅ *អេតម៉េម័រ* គឺលិខិតជំនួយស្មារតីរបស់គេនោះ។

**ស៖** សូមអរគុណ។ សូមទោស ដោយសារក្នុងពេលសម្រាកនេះ ខ្ញុំបាទបានជួបនឹងប្រជាពលរដ្ឋដែលជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំបាទក៏សូមអនុញ្ញាតលោកប្រធាន សុំសួរជាសំណួរជាទូទៅមួយសំណួរ ទាក់ទងជាមួយនឹងការយល់ច្រឡំ ឬក៏ការយល់ឃើញរបស់ប្រជាពលរដ្ឋខ្មែរភាគច្រើនថា ការចូលព្រៃម៉ាគី គឺជានយោបាយរបស់សម្តេច សីហនុ ទាំងស្រុង ដែលនាំឲ្យឈានទៅរកការស្លាប់ប្រជាពលរដ្ឋខ្មែរជាងពីរលាននាក់នេះ។ ដូច្នេះ ខ្ញុំចង់បានឲ្យលោកសាស្ត្រាចារ្យពន្យល់បន្តិចថា នេះគឺជាការបោកប្រាស់របស់ខ្មែរក្រហម ឬក៏នយោបាយសម្តេច នរោត្តម សីហនុ មែន។ បាទ សូមអរគុណ។

[១៣:៤៣:២៥]

**ឆ៖** គឺថា គំនិតហ្នឹងទាំងពីរនៅពេលដែលព្រះអង្គធ្វើអំពាវនាវនោះគឺគ្រាន់តែថា អាចនឹងធ្វើសេចក្ដីអំពាវនាវ និងផ្ដល់អំណាចទាំងស្រួលដែលថា ឲ្យមានអត្ថបទអំពាវនាវបែបនោះមែន។ ប៉ុន្តែគឺថាមិនមែនខ្មែរក្រហមប្រាប់ថា ឲ្យព្រះអង្គនិយាយបែបនោះ បែបនេះនោះទេ គឺថាប៉ុន្តែជាសេចក្ដីនៅក្នុងខ្លឹមសារនោះវា អាចនឹងផ្ដល់ប្រជាប្រិយភាពទៅឲ្យខ្មែរក្រហម។ នេះជាឧបករណ៍មួយ ការអំពាវនាវនេះ គឺដើម្បីឲ្យខ្មែរក្រហមមានប្រជាប្រិយភាពនៅក្នុងតំបន់ជនបទ ដើម្បីឲ្យគេបានទទួលការគាំទ្រ គឺថាចូលរួមនៅក្នុងរណសិរ្ស ដោយសម្ងាត់នោះ ដែលទើបតែបានបង្កើតឡើងនៅប៉េកាំងនោះ។ នេះគឺជាករណីដែលយើងមិនដឹងច្បាស់ ដូចដែលខ្ញុំប្រាប់ព្រឹកមិញ គឺថាមិនដឹងថា មានមនុស្សប៉ុន្មាននាក់ ដែលបានឮការអំពាវ មិនដឹងថាមានប៉ុន្មាននាក់គោរពតាម។ ហើយនៅពេលខ្លះគឺថា អ្នកដែលចូលរួមនៅម៉ាគីហើយ ដែលមើលទៅស្ថានភាពមិនស្រួល ដែលមិនពេញចិត្តគេត្រឡប់មកវិញ។ មានអ្នកខ្លះក៏ត្រូវបានគេសម្លាប់។ ហើយមនុស្សខ្លះនៅក្នុងដំណាក់កាលមួយៗហ្នឹង អ្នកខ្លះបានឮ ហើយបានទទួលធ្វើតាមហើយយើងមិនអាចនិយាយទេថា តើមានប៉ុន្មាន ហើយមានប្រសិទ្ធភាពម៉េចទេការអំពាវនាវនេះនោះ។

[១៣:៤៤:៥៥]

ភស្តុតាងរហូតដល់មកដល់ឆ្នាំ៧៥ នោះគឺថា រដ្ឋប្រហារនោះក៏វាអាចនឹងធ្វើឲ្យសាធារណជនយល់បានគឺថា ដែលគេអាចនឹងចូលទៅខេត្តកំពង់ចាម ហើយទៅសម្លាប់បង ប្អូនប្រុសរបស់ លន់ នល់នៅទីនោះ។ អាហ្នឹងគឺជាការបង្កើតកំហឹងនៅទីនោះ។ រីឯកំហឹងយូរប៉ុនណា ហើយនឹងការកៀងគរមនុស្សដែលឲ្យខឹងមានចំនួនប៉ុន្មាននោះ គឺខ្ញុំមិនអាចឆ្លើយបានទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងចំណុចនេះដែរ ខ្ញុំបាទចង់ជម្រាបសួរលោកទាក់ទងជាមួយនឹងមុន -- ផែនការមុននឹងវាយរំដោះយកប្រទេសកម្ពុជា មុនឆ្នាំ១៩៧៥។ តើលោកបានស្វែងយល់ដែរឬទេទាក់ទងជាមួយនឹងសេចក្ដីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលសម្រេចប្រាំបីចំណុចក្រោយពេលដែលរំដោះប្រទេសកម្ពុជាបាន គឺទាក់ទងជាមួយនឹងសេចក្ដីសម្រេចចុះថ្ងៃទី២០ ខែឧសភាឆ្នាំ១៩៧៥។ ក្នុងនេះតើជាគោលនយោបាយខាងបក្សកុម្មុយនីស្តកម្ពុជាបំបាត់ចោលគោលនយោបាយរបស់រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ឬក៏យ៉ាងម៉េច? ដោយសារគោលការណ៍នោះវាមានប្រាំបីចំណុច ខ្ញុំបាទសូមអនុញ្ញាតអានជាភាសាខ្មែរបន្តិច នៅក្នុងឯកសារ IS លេខ 4.26។ ខ្ញុំបាទមានភាសាខ្មែរ មិនមានភាសាអង់គ្លេស។

[១៣:៤៦:៣៨]

**លោក ហុង គីមសួន៖**

សូមអនុញ្ញាតលោកប្រធានអានគោលការណ៍ប្រាំបីចំណុច ដែលសម្រេចដោយគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក ហុង គីមសួន៖**

បាទ សូមអរគុណ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** ខ្ញុំសូមជម្រាបសួរទៅលោកសាស្ត្រាចារ្យថា គោលការណ៍ប្រាំបីចំណុចនេះ គឺ១)ជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់។ ទី២) លុបបំបាត់ផ្សារទាំងអស់។ ទី៣) លុបបំបាត់រូបិយវត្ថុក្នុងរបប លន់ លន់ និងដកទុកនូវរូបិយវត្ថុបដិវត្តន៍ដែលទើបតែបោះពុម្ពហើយ។ ទី៤) ផ្សឹកព្រះសង្ឃទាំងអស់ ហើយឲ្យព្រះសង្ឃទាំងនោះទៅធ្វើស្រែ។ ទី៥) សម្លាប់អ្នកដឹកនាំក្នុងរបប លន់ នល់ ទាំងអស់ ដោយចាប់ផ្តើមពីថ្នាក់ដឹកកំពូលមុនគេ។ ទី៦) បង្កើតសហករណ៍ក្នុងកម្រិតខ្ពស់ទូទាំងប្រទេស ដោយឲ្យហូបបាយរួម។ ទី៧) បណ្តេញជនជាតិភាគតិចវៀតណាមឲ្យអស់។ ទី៨) ពង្រាយកងទ័ពតាមព្រំដែន ជាពិសេសព្រំដែនវៀតណាម។ សូមលោកសាស្ត្រាចារ្យបកស្រាយចំណុចនេះជូនអង្គសវនាការបន្តិចបាទ។

[១៣:៤៨:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំបាទមិនឡើងមកជំទាស់ទេ ក៏ប៉ុន្តែសូមធ្វើសំណូមពរថា ឲ្យសហភាគីដែលអានឯកសារហ្នឹង សូមប្រាប់ -- បើអាចសូមដាក់ឯកសារហ្នឹងបញ្ចាំងនៅកញ្ចក់ទូរទស្សន៍ផង ហើយសូមប្រាប់លេខទំព័រលើ ឬលេខ ERN ផង ព្រោះបើសិនគ្រាន់តែថាអានអ៊ីចឹង ខ្ញុំតាមមើលមិនដឹងឯកសារណាទេ។ សូមលោកប្រធានអរគុណ។

**លោក ហុង គឹមសួន៖**

បាទ សូមជម្រាបជូនផងដែរ ខ្ញុំបាទអម្បាញ់មិញថាមានតែភាសាខ្មែរ ហើយខ្ញុំបាទសូមជម្រាបជូន ERN តែម្តង គឺទំព័រដែលខ្ញុំបាទអាននេះគឺលេខ 0031505 និងលេខ 1, ហើយ IS លេខ 4,26។ ខ្ញុំបាទមានតែភាសាខ្មែរនេះទេ។ បញ្ចាំងបានទេ?

**ប្រធានអង្គជំនុំ៖**

បាទ ជំនួយការមេធាវីអាចបញ្ចាំងឯកសារនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ផង ខាងផ្នែកសោតទស្សន៍!

ហើយគួរតែរៀបចំសំណួរឲ្យបានល្អដែរ ដល់ពេលយើងសំណួរសួរដល់អ្នកជំនាញឲ្យគាត់បកស្រាយ វាអត្ថន័យវាអាចខុសគ្នារវាងការសំណួរផ្សេងទៀតដែលរៀបចំដោយភាគីពីមុនៗ គេតាំងសំណួររបៀបគ្នា ប៉ុន្តែគេប្រើពាក្យពេចន៍ខុសពីនេះ ដើម្បីឲ្យទំនងជាក្នុងការសួរទៅដល់អ្នកជំនាញ។

[១៣:៤៩:៥៥]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** អ៊ីចឹងខ្ញុំបាទ សូមសួរថា តើពាក្យពេចន៍ដែលខ្ញុំបាទអានអម្បាញ់មិញនេះ ដោយសារការរង់ចាំការបញ្ចាំង ខ្ញុំបាទសូមជម្រាបសួរសាស្ត្រាចារ្យថាតើគេអនុវត្តយ៉ាងម៉េចដែរក្នុងប្រាំបីចំណុចហ្នឹង? សូមអរគុណ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំមិនមានមតិជាក់លាក់នោះទេ ខ្ញុំបានអានភាសាខ្មែរលើអេក្រង់។ នេះជាសេចក្តីថ្លែងការណ៍យ៉ាងច្បាស់នៅក្នុងគោលនយោបាយគ្រប់តែករណីទាំងអស់។ នយោបាយនេះ ត្រូវបានគេគោរពតាមទៅគ្រប់កម្រិត គឺថាមន្ត្រី លន់ នល់ ពីថ្នាក់ខ្ពស់មកថ្នាក់ទាប ត្រូវបានគេសម្លាប់ គឺថាដូចឃើញច្បាស់ហើយនៅក្នុងការបោសសម្អាត ដែលក្រោយមកគឺបានបន្ថយ ឬក៏ចុងឆ្នាំ៧៥ គឺថាបានបង្អង់។

[១៣:៥០:៥៤]

ប៉ុន្តែនៅក្នុងរបបទាំងស្រុងនោះ ដូចដែលលោកបញ្ជាក់នេះ គឺថាមិនទាន់បានលើកឡើងពីថាដើមទេ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺថាឯកសារនេះ គឺថាបានធ្វើឡើងដោយរបបនេះ។ ពេលខ្លះ គឺធ្វើខុស

ពីគំរូរបស់ប្រទេសចិន ដែលថាដូចជាសេចក្ដីសម្រេចក្នុងការលុបបំបាត់រូបិយប័ណ្ណហ្នឹង គឺថាធ្វើឡើងនៅពេលក្រោយ។ ប៉ុន្តែយើងឃើញថា ប៉ុន្តែគេយល់ថាមានរូបិយវត្ថុ ប៉ុន្តែគេមិនប្រើនៅក្នុងទីផ្សារ ទេក្រោយមកនោះ។

**លោក ហុង គឹមសួន៖**

បាទ ដោយសារពេលវេលារបស់ខ្ញុំបាទ ត្រូវបែងចែកឲ្យសហភាតាខ្ញុំបាទ។ សូមសួរសំណួរចុងក្រោយមួយទៅលោកសាស្ត្រាចារ្យ។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សំណួរបាទសួរថា គោលនយោបាយរបស់មេដឹកនាំខ្មែរក្រហមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និយាយ អ្ហ៎!សូមអភ័យទោស។ សូមអភ័យទោស ខ្ញុំបាទសូមលើកយកឯកសារមួយទៀត គឺ E3/17 ទំព័រ២៣១ ERN ជាភាសាខ្មែរ លេខ 0082 -- សូមអភ័យទោសអានច្រឡំ។

**លោក ហុង គឹមសួន៖**

បាទ លោកប្រធានសូមអភ័យទោស។

សូមអភ័យទោស! ខ្ញុំសូមកែតម្រូវឡើងវិញ។ ឯកសារដែលនៅក្នុងសៀវភៅ “សំឡេងពីមន្ទីរ ស-២១” ដែលមាន ERN ជាភាសាខ្មែរ 00191846, ERN ជាភាសាអង់គ្លេស 00192694។ សូមអនុញ្ញាតលោកប្រធាន ឲ្យខាងសហការីបញ្ចាំងតាមទូរទស្សន៍ផង។

[១៣:៥៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

បើក១ ក្បាលមីក្រូសិន!

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** នៅក្នុងឯកសាររបស់លោកបានសរសេរនេះទាក់ទងជាមួយនឹងពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមអានតែម្ដង៖ “បានផ្ដល់អាទិភាពខ្ពស់បំផុតដល់ការងាររបស់ ស-២១ ក្នុងការការពារក្បាលម៉ាស៊ីនមជ្ឈិមបក្សរបស់ខ្លួន។ អនុលេខបក្សកុម្មុយនីស្តកម្ពុជា នួន ជា បងធំទី២ បានពន្យល់

គណៈប្រតិភូដាណាម៉ាកមួយក្រុម ដែលមានសមានចិត្តនឹងកម្ពុជាប្រជាធិបតេយ្យ ហើយដែលបានមកបំពេញទស្សនកិច្ចនៅខែកក្កដា ឆ្នាំ១៩៧៨ ថាយើងត្រូវតែការពារក្បាលម៉ាស៊ីនដឹកនាំឲ្យបាន ទោះជាត្រូវលះបង់អ្វីក៏ដោយ។ ប្រសិនបើយើងបាត់បង់សមាជិក តែនៅសល់អ្នកដឹកនាំ យើងអាចបន្តយកជ័យជម្នះបាន។ ការបាត់បង់សមាជិក២០០ ឬ៣០០នាក់ មិនអាចប្រៀបនឹងការបាត់បង់មេដឹកនាំពីរ ឬបីនាក់បានទេ។ យើងសុខចិត្តបាត់បង់សមាជិក២០០ ឬ៣០០នាក់ តែយើងមិនឲ្យបាត់បង់មេដឹកនាំពីរបីនាក់ឡើង។ បើពុំមានដូច្នេះទេ បក្សនឹងគ្មានអ្នកដឹកនាំ និងពុំអាចដឹកនាំការប្រយុទ្ធបានឡើង"។

ត្រង់ចំណុចនេះ ខ្ញុំបាទចង់សួរលោកសាស្ត្រាចារ្យថា ការស្វែងយល់របស់លោកសាស្ត្រាចារ្យ តើគំនិតនេះ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ និងគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា គេយល់ឃើញថា មានតែក្រុមរបស់គេទេ ទើបដឹកនាំប្រទេស ឬយ៉ាងម៉េច ក្រៅពីខ្លួនគេ ឬក៏ក្រុមរបស់គេ បាទ?

[១៣:៥៥:៤៣]

**លោក ហុង គីមសួន៖**

លោកប្រធាន សូមអនុញ្ញាតជូនជាភាសាអង់គ្លេសទៅលោកសាស្ត្រាចារ្យតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីមេធាវីជូនទៅអ្នកជំនាញ។

**លោក ឆេវីង ឆេនដ័ល័រ៖**

**ឆ៖** ចម្លើយខ្ញុំបានស្តាប់លោក ទាក់ទងទៅនឹងភាសាខ្មែរនេះ គឺជាសេចក្តីដកស្រង់ដ៏ទូលំទូលាយដែលគេដឹងគ្រប់គ្នា គឺថាប្រតិបត្តិការ ការអនុវត្តកម្ពុជាប្រជាធិបតេយ្យនោះ គឺថាដូចដែលគេថែងអីចឹងគឺថាគេ មិនឲ្យឯកសារទៅបរទេសភាគច្រើនទេ ប៉ុន្តែគេចង់ឲ្យមានការទុកចិត្តលើរបបរបស់គេ ទើបបានគេនិយាយបែបដូច្នេះ។ នៅក្នុងនេះ គឺថា នួន ជា បានបញ្ជាក់បែបនេះ គឺគាត់ធ្វើសេចក្តីថ្លែងការណ៍ហ្នឹង ដោយស្មោះត្រង់ ហើយគាត់ពិពណ៌នាអំពីគោលនយោបាយ ហើយភស្តុតាងដែលបង្ហាញនោះគឺថាការអនុវត្តនោះ គឺឃើញទូលំទូលាយទូទាំងប្រទេស។ គេចាត់ទុកថា មេដឹកនាំសំខាន់ណាស់។

[១៣:៥៦:៤៨]

ឌុច និយាយថា គោលបំណងសំខាន់នៃ ស-២១ គឺដើម្បីការពារអង្គការ។ អង្គការ មានន័យថា មេដឹកនាំបក្ស។ នេះហើយ គឺជាសេចក្តីថ្លែងការណ៍ដ៏ត្រង់ បាទ ហើយជាគោលនយោបាយមួយ ហើយវាក្នុងលក្ខណៈកម្រណាស់ ដែលថាមានតែមេដឹកនាំបញ្ជាក់ដោយមេដឹកនាំណាមួយ ហើយដោយកម្រ

ទេ។ ដូច្នេះ ហើយនេះជាសម្ដីចេញអនុលេខារបស់បក្សនោះ។

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកសាស្ត្រាចារ្យ ដោយសារពេលវេលាខាងខ្ញុំបាទ នឹងត្រូវចែកជូនទៅសហភាគាខ្ញុំបាទនោះ។ ខ្ញុំបាទសូមអរគុណយ៉ាងច្រើន ដែលលោកសាស្ត្រាចារ្យបានចូលរួមបំភ្លឺដល់អង្គសវនាការ និងសាធារណជន។ ហើយខ្ញុំបាទ សូមអរគុណលោក និងអរគុណលោកប្រធាន លោកលោកស្រីចៅក្រម។ និងបន្តទៀត សូមជូនវេទិកាទៅខាងសហភាគា បាទ។ សូមអរគុណ។

[១៣:៥៧:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមជម្រាបសួរលោកប្រធាន អស់លោក លោកស្រីក្រម ជាទីគោរព! ជម្រាបសួរអស់លោកទាំងអស់គ្នា និងជម្រាបសួរដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងលោកអ្នកជំនាញ។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** ខ្ញុំសូមចោទសំណួរលោកពីរបី ដោយខ្លី ដោយសង្ខេប ពីព្រោះថាពេលវេលាយើងមានពេលខ្លី ហើយបន្ទាប់មកទៀត សហភាគារបស់ខ្ញុំ អូលីវីយេ ហើយនិងនិយាយពីអង្គហេតុជាក់លាក់។ ហើយជាបឋម ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាមួយដែលបានលើកឡើងទាក់ទងទៅនឹងការរក្សាការអាថ៌កំបាំង។ គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ឬក៏របស់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហម គឺឲ្យតម្លៃខ្ពស់ទៅនឹងការ -- ទៅលើការសម្ងាត់។

[១៣:៥៨:៤៩]

សំណួរទីមួយរបស់ខ្ញុំ គឺថាបើយើងយល់អំពីការតស៊ូប្រដាប់អាវុធ ឬក៏ដោយលួចលាក់ គឺថាមុននៅឆ្នាំ១៩៧៥ មានកាតព្វកិច្ចដែលត្រូវធ្វើយ៉ាងណាលាក់ឈ្មោះ លាក់ខ្លួន កុំឲ្យគេដឹងពីអត្តសញ្ញាណរបស់ខ្លួន។ តើហេតុអ្វីក៏ការគោរពបូជាការសម្ងាត់នេះ នៅតែបន្តទៀត នៅពេលដែលទទួលបានជោគជ័យតែមួយគត់លោក ចំពោះអ្នកដែលឈ្នះសង្គ្រាមនោះ តើហេតុក៏នៅតែត្រូវបន្តវិធីរក្សាការសម្ងាត់នេះតទៅទៀត នៅក្រោយពេលថា ដែលទទួលបានជ័យជម្នះហើយនោះ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ចម្លើយនេះ ជាសំណួរល្អណាស់។ ដោយមានការអនុញ្ញាត ខ្ញុំសូមកែសម្រួល គឺមិនមែនចាំបាច់ហ្នឹងធ្វើបែបនេះទេ។ ប៉ុន្តែគេយល់ថា សំខាន់ចំពោះមេដឹកនាំ គេយល់ថា ជាការសម្ងាត់ ជានយោបាយរបស់គេ ដែលគេបន្តមកជាយូរហើយ ហើយគឺត្រូវរក្សាមេដឹកនាំនោះ ក្នុងការសម្ងាត់ ហើយមិនមានគុណធម៌អ្វីដើម្បីថា អ្នកខ្លះជាមេដឹកនាំ គេធ្វើអ្វី។

[១៤:00:00]

នេះគេយល់ថា ជានយោបាយដ៏ជោគជ័យរបស់គេ ទើបបានជាគេបន្តនោះ។ ខ្ញុំជឿថាវាជាការលាក់លៀមចំពោះអ្នកដទៃមែន ប៉ុន្តែក្នុងបក្សគេគិតបែបនោះ។

**ស៖** សូមអរគុណលោកអ្នកជំនាញ។ មានសំណួរមួយទៀតផងដែរ យើងបានលើកឡើងពីសំណួរ -- លោកបាននិយាយអំពីសំណួរនេះម្សិលមិញ ឬក៏កាលពីម្សិលមិញជាច្រើនដង លោកបានផ្តល់ឧទាហរណ៍មួយចំនួនទាក់ទងទៅនឹងការអនុវត្តការគោរពការសម្ងាត់នេះ ដែលអ្នកដឹកនាំព័ទ្ធជុំវិញទៅដោយការសម្ងាត់ទាំងអស់។ ក៏ប៉ុន្តែផ្ទុយទៅវិញ លោកក៏បាននិយាយអំពីស្ថានភាពរបស់ប្រជាជនកម្ពុជា ដែលចំពោះប្រជាជនកម្ពុជានេះ ត្រូវបានដាក់នៅក្រោមសតម្លាភាពទាំងស្រុង ហើយដោយថាមិនឲ្យប្រជាជននេះមានលាក់លៀមការសម្ងាត់អីទៅអង្គការនោះទេ។ តើលោកអាចផ្តល់យោបល់ផ្ទាល់ខ្លួនរបស់លោក ដែរឬទេ? តើនេះជាយុទ្ធសាស្ត្រអ្វី? ឬក៏ថាជាការអភិបាលកិច្ចពិសេសណាមួយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏យ៉ាងម៉េច ឲ្យគេមានតម្លាភាព ហើយខ្លួនឯងរក្សាការសម្ងាត់នេះ?

[១៤:០១:៣៥]

**ឆ៖** នេះក៏ជាសំណួរល្អ ដោយសារមានខ្លឹមសារមួយចំនួន ដែលធ្វើឲ្យខ្ញុំនឹកឃើញ។ ចំណុចដែលខ្ញុំចង់បញ្ជាក់ មេដឹកនាំរបស់បក្ស គឺគេប្រាប់គ្នាត្រង់ទៅវិញទៅមក វាមានតម្លាភាព គឺថានៅតាមមាគ៌ារបស់ថ្នាក់របស់គេដូចម្សិលមិញខ្ញុំបានប្រាប់គឺថា មេដឹកនាំទាំងអស់ គឺបានត្រៀមរៀបចំប្រវត្តិរូបដើម្បីពិនិត្យនៅក្នុងវគ្គសិក្សា។ ហើយពួកគាត់គឺមានតម្លាភាពក្នុងចំណោមគ្នាគាត់។ ប៉ុន្តែតម្លាភាពនេះ គឺថាមិនមានជម្រើសដើម្បីត្រូវរក្សាស្ងាត់ពីអ្នកដទៃរហូតអ៊ីចឹងទេ ពីព្រោះថា អ្នកនៅក្រៅពីបក្សកុម្មុយ-នីស្តកម្ពុជា ក៏គាត់ចង់ដឹងអំពីៗ គំនិតនេះដែរ គឺថា កាលណាគេមិនទុកចិត្ត គេត្រូវរក្សាការសម្ងាត់។ ដូច្នេះគេមិនទុកចិត្តអ្នកណាទាំងអស់។ ដូច្នេះហើយគេ -- បើសិនជាគេចង់បើកចំហទៅដល់របបទាំងមូលនោះ គេអាចនឹងត្រូវពិនិត្យមើល គេនឹងអាចចង់ដឹងថា អ្នកណាជាអ្នកណា។ ប៉ុន្តែតម្លាភាពនៅក្នុង

បក្សហ្នឹង គេចាត់ទុកជាកម្រិតខ្ពស់ណាស់ វាក្លាយទៅជាការសម្ងាត់ពីអ្នកខាងក្រៅ។ ដូចជារឿង ហ៊ូ នឹម ជាដើមហ្នឹង គឺថាគាត់ដឹងច្បាស់ថា អ្នកណាខ្លះជាមេដឹកនាំ ព្រោះគាត់ជាអ្នកផ្ទៃក្នុង។ បាទគឺថា ក្នុងសម័យនោះគឺថា ប្រជាជនធម្មតាពិបាកនឹងកំណត់ឈ្មោះមនុស្សប្រាំនាក់ នៅខាងលើក្នុងមជ្ឈិមបក្ស នឹងណាស់ មានតែអ្នកផ្ទៃក្នុងទេ ដែលគេដឹងថា អ្នកណាជាអ្នកណានោះបាទ។

[១៤:០៣:១៩]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ សំណួរតូចមួយទៀត ដែលខ្ញុំទើបតែនឹកឃើញ លោក -- អម្បាញ់មិញលោកបាននិយាយពាក្យថា “អង្គការ” ឬក៏ “អង្គការដឹកនាំបក្ស”។ ការប្រើពាក្យ “អង្គការ” នេះ ដែលបង្កើតឡើងតាំងពីថ្ងៃទី១៧ មេសា លោកទើបតែបាននិយាយពាក្យនេះអម្បាញ់មិញ ដែលគឺថា គឺជាអង្គភាពដឹកនាំ ដែលលាក់ខ្លួន -- ដែលថានៅក្នុងនេះមានអ្នកដឹកនាំជាន់ខ្ពស់ជាច្រើន។ តើក្រៅពីផាសុកភាព ឬក៏សុវត្ថិភាពរបស់អ្នកទាំងអស់នេះ ដែលតាមលោកដឹង តាមលោកអាន លោកបានឃើញ តើមានរូបភាពអ្វីមួយដែលគួរឲ្យភ័យខ្លាច នៃអំណាច -- ពីសំណាក់អ្នកកាន់អំណាចក្នុងការគ្រប់គ្រងប្រជាជន ទោះបីជាប្រជាជនថ្មី ឬក៏ប្រជាជនចាស់ក៏ដោយនោះ? តើមានការភ័យខ្លាចអីដែរឬទេពីសំណាក់អ្នកដឹកនាំ?

[១៤:០៤:៣២]

**ឆ៖** ខ្ញុំ -- គឺថា ប្រជាជនមិនបានដឹងថា គេមិនបានប្រាប់ថា អង្គការជាអ្នកណានោះទេ។ ខ្ញុំបានធ្វើការសម្ភាសពីអ្នកដែលរស់រានមានជីវិត គឺថា អ្នកខ្លះយល់ថា អង្គការគឺជាមនុស្ស។ អ្នកខ្លះថា គឺជាស្ថាប័ន អង្គការ ជាស្ថាប័ន ប៉ុន្តែអ្នកខ្លះអង្គការគឺជាឈ្មោះរបស់មនុស្ស។ ហើយអ្នកខ្លះថា មានមនុស្សនៅពីខាងក្រោយអង្គការ។ ដូច្នេះអ្នករស់រានមានជីវិតនេះ គឺគាត់ថាអង្គការគឺមានភ្នែកច្រើនណាស់ អង្គការភ្នែកម្នាស់។ អង្គការអាចមើលឃើញអ្វីៗទាំងអស់ មើលឃើញអ្វីៗដែលកំពុងតែដំណើរការទៅ មើលឃើញថាអ្នកណាគឺជាអ្នកណា។ នេះក៏ដូចជាពាក់ព័ន្ធទៅនឹងបញ្ហាថា បញ្ហាខ្លាំងនោះផងដែរ។ អ្នកខ្លះគឺនៅភូមិ ក៏ប៉ុន្តែតំណាងឲ្យអង្គការ ក៏ប៉ុន្តែគេអត់ដឹងថា អ្នកនោះគឺជាអ្នកណានោះទេ។ មានការតាមឃ្លាំមើល មានការតាមដានត្រួតពិនិត្យ។ ដូច្នេះបើសិនគេសួរថា អ្នកណាជាអ្នកណានោះ គឺថាវាមានការភ័យខ្លាចគេ -- អ្នក -- សួរថាអ្នកឯងជាអ្នក -- ដូច្នេះអ្នកណាៗប្រាប់អ្នកឯងនិយាយ។ ដូច្នេះគេមិនអាចប៊ានឆ្លើយបានទេ មានការភ័យខ្លាច។

[១៤:០៦:០៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមចោទសួរសំណួរមួយប្រភេទផ្សេងទៀត។ ខ្ញុំសូមត្រឡប់មកនិយាយអំពីប្រជាជនថ្មីវិញម្តង លោកបានលើកឡើងថា កាលពីម្សិលមិញ ឬក៏ម្សិលម៉្ងៃថា ប្រជាជនថ្មីនេះជាសត្រូវទីមួយ នៃរបបនុ៎ង ថាចាប់ពីថ្ងៃ១៧ មេសា មកម្ល៉េះ។ ពីព្រោះថា ប្រជាជននេះជាតំណាងឲ្យសក្តិភូមិ ចក្រពត្តិ។ តើនេះជាមូលហេតុដែលចោទប្រកាន់ទៅលើប្រជាជនថ្មីថាជាសត្រូវ ឬក៏យ៉ាងម៉េច ឬក៏មានមូលហេតុផ្សេងទៀតដែលលោកអាចផ្តល់ជូនមកអង្គជំនុំជម្រះបាន?

**ឆ៖** ការពន្យល់ដោយសាមញ្ញនោះគឺថា តាមនិយមន័យប្រជាជនថ្មីគឺរស់នៅទីក្រុង ដែលខ្មែរក្រហមមិនទាន់បាន គឺថាបញ្ចេញ ឬក៏ជម្លៀសពួកគាត់ចេញពីទីក្រុង ដូចជា ឧដុង្គ ស្ទឹងត្រែង ក្រចេះជាដើម។

[១៤:០៧:៣០]

ប្រជាជនទាំងអស់នេះ ដែលរស់នៅទីក្រុងនេះ តាមនិយមន័យគឺ អ្នកដែលមិនបានចូលរួមជាមួយបដិវត្តន៍ទេ។ ហើយដូច្នេះគេត្រូវតែមានឥរិយាបថ ក៏ដូចជាប្រជាជនដែលនៅខាងក្រៅពួកគាត់។ ដូច្នេះដើម្បីកំណត់ស្រួលជាមួយពួកគាត់ ដើម្បីងាយស្រួលកំណត់ថា អ្នកណាជាខ្មាំង អ្នកណាជាពួកក្បត់ ដើម្បីឲ្យខុសគ្នាពីក្រុមដែលស្ថិតនៅជាប់ជាមួយនឹងបដិវត្តន៍នោះ។ ហើយនៅក្នុង -- ជាពិសេសជួររបស់បក្សកុម្មុយនីស្តកម្ពុជានេះ គឺប្រជាជនដែលរស់នៅទីក្រុងត្រូវបានគេកំណត់ថា ជាខ្មាំងសត្រូវធំបំផុត ខុសពីកសិករដទៃទៀត។ ដូច្នេះការ -- គេបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុងភ្នំពេញ ក៏ដូចពីក្រុងបាត់ដំបង គឺៗថាពួកគាត់គឺមានការខឹងសម្បាណាស់ មិនមែនតែសម្រាប់ពួកលោកខាងលិច ឬក៏ពួកអាមេរិកាំងនេះទេ។ គឺៗទីក្រុង គឺតាមនិយមន័យ គឺប្រជាជនដែលមិនបានចូលរួមតស៊ូជាមួយបដិវត្តន៍ ដូច្នេះខ្មែរក្រហមចាត់ទុកថាអ្នកទាំងអស់នេះ គឺជាខ្មាំង។

[១៤:០៨:៥៧]

**ស៖** សូមអរគុណ។ លោកទើបតែនិយាយអំពី -- លើកឡើងអំពីក្រចេះ ហើយនិងឧដុង្គ។ ឥឡូវខ្ញុំសូមចោទសំណួរជាក់លាក់មួយ អង្កាល់នៅសម័យនោះការដែលមានការជម្លៀសប្រជាជន ហើយប្រជាជននោះមិនត្រូវបានគេចាត់ទុកថា ជាប្រជាជនថ្មីទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំអត់មានព័ត៌មានពីរឿងនេះទេ។ ខ្ញុំអត់ចាំថាតើប្រជាជនថ្មីនេះត្រូវធ្លាប់បានគេពាក់ព័ន្ធ ឬក៏ប្រើប្រាស់មុនឆ្នាំ៧៥ នោះឬយ៉ាងណានោះទេ ខ្ញុំអត់មានព័ត៌មាននេះទេ។

**ស៖** បើតាមការស្រាវជ្រាវរបស់លោក ឬក៏ចំណេះដឹងរបស់លោកតើលោកអាច --

លោកដឹងព័ត៌មានលម្អិតទាក់នឹងអ្វីដែលកើតឡើង ឬក៏លក្ខខណ្ឌនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ជាពិសេស តើលក្ខខណ្ឌអនាម័យ អាហារ តើយោធាខ្មែរក្រហមនោះទទួលប្រជាជនបែបណា អមប្រជាជនបែបណានៅតាមផ្លូវ? តើលោកដឹងព័ត៌មានលម្អិតទាក់ទងនឹងការជម្លៀស ព្រឹត្តិការណ៍នៃការជម្លៀសនេះដែរឬទេ?

[១៤:១០:៤៣]

**ឆ៖** គឺអ្នកនៅរស់រានមានជីវិត គឺថាស្ថានភាពនោះ គឺថាអាក្រក់មែនទែន។ នៅពេលនោះ គឺជាពេលចូលឆ្នាំថ្មី វាជាពេលវេលាមួយដ៏លំបាកសម្រាប់ប្រទេសកម្ពុជា ដោយសារថាខ្វះខាតទឹក ប្រជាជនត្រូវធ្វើដំណើរហូរចេញទាំងហ្វូងៗ ចេញពីទីក្រុង ហើយគាត់អត់មានទ្រព្យសម្បត្តិអីយកទៅជាមួយ ហើយគាត់មិនបានដឹងថា ពួកគាត់ត្រូវទៅទីណា មកទីណា។ ខ្ញុំគិតឃើញថា ពេលនោះគឺមានស្ថានភាពលំបាកលំបិនបំផុត។ ដូច្នេះចំណុចនេះ ជាចំណុចមួយទៅដុតបញ្ឆេះអ្នកថ្មីហ្នឹង គឺឱ្យមានការខឹងសម្បា។

ហើយក្រោយឆ្នាំ១៩៧៩ ប្រជាជនទាំងអស់នេះគាត់ចាំច្បាស់ថា មានរឿងរ៉ាវច្រើនណាស់ដែលៗ គឺថាមានរឿងចម្រូងចម្រាសច្រើនណាស់ដែលគាំទ្រទៅដល់ដំណើររឿងរបស់គាត់នោះ។ ហើយខ្ញុំអាចនិយាយថា នេះមិនមែនជារឿងមួយដែលផ្ទុយពីនេះ ជារឿងមួយដែលស៊ីសង្វាក់គ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាពេលមួយដែលត្រូវថាធ្វើម៉េច ធ្វើឱ្យរឿងនេះឱ្យវាបានស៊ីសង្វាក់ដូចគ្នាប្រជាជនមិនឱ្យរៀបចំខ្លួន -- ខ្ញុំគិតថានេះ គឺជាចម្លើយរបស់ខ្ញុំដែលឆ្លើយពីមុនមកហើយ ដែលប្រជាជនទាំងអស់នេះ គេមិនបានឱ្យតម្លៃអ្វីទៅលើពួកគាត់នោះទេ។ ប្រជារាស្ត្រត្រូវបានជាអ្នកដែលត្រូវបានគេសង្ស័យ មិនស្ថិតនៅក្នុងតួនាទីឋានៈអ្វីនោះទេ។

[១៤:១២:២២]

បើសិនណាជាយើងមើលទៅលើឯកសាររបស់តុលាការនេះ យើងឃើញថា អ្នកខ្លះគាត់មានសោកស្ដាយនៅពេលដែលគេ -- គេឆ្លើយថាគេសោកស្ដាយនូវអ្វីដែលបានគេប្រព្រឹត្តធ្វើនៅពេលនោះ អ្នកខ្លះឆ្លើយថាមិនដឹង។ ឧទាហរណ៍ រឿង -- និយាយឱ្យចំស្ថានភាពនៅពេលនោះ គឺថាលំបាកលំបិនមែនទែន។

**ស៖** សូមអរគុណ។ ក្នុងឋានៈជាអ្នកប្រវត្តិសាស្ត្រ តើលោកមានព័ត៌មានណា ដែលអាចធៀបប្រៀបធៀបទៅនឹងការជម្លៀសដ៏គួរឱ្យរន្ធត់នេះបានដែរឬទេ? តើនៅមានព្រឹត្តិការណ៍ណាដែលជាប្រវត្តិសាស្ត្រដែលអាចនឹងធៀបទៅនឹងការជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញនេះដែរឬទេ នៅក្នុងពិភពលោក?

**ស៖** ខ្ញុំហាក់បីដូចជាមិនច្បាស់បន្តិចត្រង់ចំណុចនេះ។ នេះគឺជាគេហៅថា ជាបញ្ហាយុត្តិសាស្ត្រមួយ គឺអង្កាល់ពីថ្ងៃពុធ យើងបាននិយាយគ្នាអំពីការជម្លៀសប្រជាជនម្តងទៀតនៅឆ្នាំ១៩៧៦។ ហើយបន្ទាប់ពីនោះមក គឺយើងនិយាយអំពីការជម្លៀសប្រជាជនដែលចេញពីទីក្រុងភ្នំពេញទាំងស្រុងតែម្តង។ មានធាតុមួយចំនួនដែលគេអនុវត្តទៅតាមបែបបទមកពីប្រទេសចិន ដែលខាងប្រជាជននៅស្រុកចិននោះគឺថាក៏មានជម្លៀសប្រជាជនចេញទីប្រជុំជន ទីក្រុងដែរ។ ដូច្នេះយើងដឹងថា ការជម្លៀសប្រជាជនចេញទីក្រុងនោះ គឺថាធ្វើតាមគំរូរបស់ចិនផងដែរ។ ប៉ុន្តែនៅចិននោះ គឺថាវាជាប្រទេសមួយធំ មានលក្ខណៈស្មុគស្មាញនៅក្នុងសម័យរបស់លោក ម៉ៅ នោះ។ ប៉ុន្តែគ្មានអ្វីដែលធ្ងន់ធ្ងរលំបាកលំបិនជាងចំណុចនេះទេ។ ខ្ញុំមិនដឹងថានៅៗ មុំងហ្កោលីនោះវាមានការជម្លៀសអ៊ីចឹងដែរ ឬក៏យ៉ាងណានោះទេ។

[១៤:១៥:០២]

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ លោកបានរំឭកនូវអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក អំពីអ្វីដែលតាមលក្ខណៈណាមួយ ដែលគេកំណត់ចំណាត់ថ្នាក់ឲ្យប្រជាជនថ្មី ឬក៏ការប្រព្រឹត្តទៅលើប្រជាជនថ្មីនេះ។ លោកបាននិយាយអំពីការជម្លៀសប្រជាជននៅឆ្នាំ១៩៧៦ ទៅខាងតំបន់ពាយ័ព្យ ហើយនិងការបង្ខំឲ្យធ្វើការជាទម្ងន់ដល់ប្រជាជនថ្មី ហើយលោកក៏បានចាត់ទុកស្ថានភាពរបស់គាត់ជាស្ថានភាពទាសករលោកក៏បានរំឭកផងដែរថា ប្រជាជនថ្មីនេះពុំមានសិទ្ធិបោះឆ្នោតទេនៅពេល -- នៅឱកាសបោះឆ្នោតនីតិបញ្ញត្តិដែលមានតែមួយគត់ នៅក្នុងសម័យខ្មែរក្រហមនោះ។ ហើយអម្បាញ់មិញនេះលោកក៏បានរំឭកផងដែរថា ប្រជាជនថ្មីនេះ ចំពោះអ្នកដឹកនាំជាមនុស្សដែលមិនអាចស្រោចស្រង់បានទេ។ ហើយលោកក៏បាននិយាយផងដែរ អំពី -- និយាយរឿងមួយដែលគួរឲ្យកត់សម្គាល់មែនទែនថា បន្ទាប់ពីបាន -- បន្ទាប់ពីៗសម្លាប់ប្រជាជនថ្មីហើយ គឺថាឈានទៅដល់ការសម្លាប់កម្មាភិបាលរបស់ខ្លួនឯងផ្ទាល់។ អ៊ីចឹងប្រជាជនថ្មីហ្នឹងមិនមែនជាជនរងគ្រោះតែមួយនោះទេ នៃឥរិយាបថរបស់អ្នកដឹកនាំខ្មែរក្រហម ដែលមានទំនោរចង់សម្លាប់ បំផ្លាញ កម្ទេចនោះ។

[១៤:១៦:៥៨]

សំណួរទីមួយរបស់ខ្ញុំគឺថា មានឆន្ទៈក្នុងការបំផ្លាញ ឬក៏កម្ទេចប្រជាជនថ្មី ជាបន្តទៅនឹងសំណួរនេះសួរថាការប្រព្រឹត្តដែល ប្រព្រឹត្តទៅលើប្រជាជនថ្មីនេះ ដូចជាការបង្ខំឲ្យធ្វើការជាទម្ងន់ ឬក៏ធ្វើឲ្យមនុស្សបាត់លក្ខណៈជាមនុស្ស ការបំបាត់សិទ្ធិមនុស្ស តើមានឆន្ទៈក្នុងការដាក់ឲ្យប្រជាជននេះឲ្យឯកាហើយនិងចាត់ទុកប្រជាជននេះតាមលក្ខណៈមួយថា ជាមនុស្សមិនមែនជាមនុស្សខ្មែរ។ ហើយបើតាម

ចំណេះដឹងរបស់លោក ឬក៏តាមការស្រាវជ្រាវរបស់លោក ដែលលោកបានខំធ្វើតាំងពីយូរណាស់មក ហើយនោះ តើលោកមានអារម្មណ៍ថាមានឆន្ទៈយ៉ាងដូច្នេះដែរឬទេ អំពីសំណាក់មេដឹកនាំខ្មែរក្រហម?

**ឆ៖** នេះជាបញ្ហាមួយចម្រូងចម្រាសណាស់។ ខ្ញុំអាចឆ្លើយទៅនឹងសំណួរបាន។ ព័ត៌មានដែលខ្ញុំមាននោះគឺថា មិនមានចេតនាណាជាប្រព័ន្ធនៅក្នុងជួរដឹកនាំរបស់ខ្មែរក្រហម ក្នុងការសម្លាប់ប្រជាជនថ្មីទាំងអស់ ក្រៅពីអ្នកដែលគេត្រូវតែកម្ចាត់ចោល ជាពិសេសគឺ សំដៅទៅលើប្រជាជនថ្មីនៅក្នុងទីក្រុងចំនួន ពីរទៅបីលាននាក់នេះ។

[១៤:១៩:០៥]

ខ្ញុំបានបង្រៀនប្រវត្តិសាស្ត្រកម្ពុជាជាច្រើនឆ្នាំ ប៉ុន្តែព័ត៌មានដែលខ្ញុំប្រើប្រាស់ គឺប្រហែលជាមិនអាចយកមកអនុវត្តនៅក្នុងប្រទេសកម្ពុជាបានទេយ៉ាង។ ដូចជានិយាយអំពីឧក្រិដ្ឋកម្មនៅក្នុងខ្សែភាពយន្តអាមេរិកាំង យើងឃើញបុរសម្នាក់មកចូលក្នុងហាងទំនិញ ហើយមានកាំភ្លើង។ ហើយគឺថា មក -- គឺអ្នកណាមិនធ្វើតាមខ្ញុំ មិនមានឥរិយាបថតាមដែលខ្ញុំចង់បាន ខ្ញុំនឹងត្រូវសម្លាប់ចោល ដូចជាទៅប្លន់ធនាគារ។ ហើយបន្តធ្វើបែបនេះតទៅទៀត ពីព្រោះថាគេត្រូវការប្លន់ដើម្បីយកប្រាក់កាស។ ហើយដូច្នេះការគំរាមកំហែងទៅដល់ប្រជាជននេះ គឺជាគំរូនៃការគំរាមកំហែងមួយ។ នេះជាការគិតគូរមួយដែលគេបានធ្វើឡើងនៅក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល ដែលថាចាត់ទុកអ្នកទាំងអស់នោះគឺថាមិនមែនជាខ្មែរ ដែលទោះបីជាខ្មែរក៏ដោយ ដែលចង់ឲ្យពួកគេមានឥរិយាបថមួយដែលតាមការចង់បាន។បញ្ហានេះគឺជាមិនមានអ្វីចងក្រងជាឯកសារ ប៉ុន្តែគឺជា ចេតនាមួយដែលធ្វើឲ្យប៉ះពាល់ទៅដល់ប្រជាជន ដែលគេចង់ធ្វើតាមការចង់បានរបៀបនេះឯង។

ចំណុចមួយទៀត ដែលខ្ញុំត្រូវធ្វើការបញ្ជាក់ផង គឺការងារបែបទាសករនេះ គឺគ្រប់ៗគ្នាទាំងអស់។ តាមការពិត គឺប្រជាជនមូលដ្ឋានមិនបានចេញទៅធ្វើការលំបាកលំបិន ដូចអ្នកថ្មីទេ។ អ្នកថ្មីគឺថាធ្វើការដូចជាទាសករនៅក្រោមកំដៅ គឺថាពេញមួយថ្ងៃតែម្តង។ ចំណុចដែលសំខាន់នោះគឺ វាជាការងារដែលលំបាកខ្លាំង មិន -- ផ្នែកខ្លះនៃប្រទេស គឺគេបានមានចេតនាផ្តល់ ទៅឲ្យប្រជាជននោះគឺ វាខុសគ្នាខ្លះ ប៉ុន្តែមិនជាខុសគ្នាទេ ខុសគ្នាត្រឹម១០ទៅ១៥ភាគរយហ្នឹង គឺប៉ុណ្ណោះឯងគឺ -- នៅតំបន់របស់ តាម៉ុក គឺថា យើងឃើញថា គឺគេមិនគិតបារម្ភពីរឿងការបាត់បង់ជីវិតមនុស្សពី១០ទៅ១៥ភាគរយអីទេ គឺថាបង្ខំឲ្យធ្វើការទាំងលំបាកលំបិនបំផុត។

[១៤:២១:៣៤]

ហើយនៅក្នុងប្រទេសទាំងមូលនេះគឺ ខ្ញុំលើកលែងតែកន្លែងមួយចំនួន ឬក្រុមមនុស្សមួយចំនួនដែលបង្ខំមនុស្សឱ្យធ្វើការខ្លាំងលំបាកមែនទែន។ ពាក្យខ្មែរគឺ "កម្ពុជាប្រជាធិបតេយ្យ" មិនដែលប្រើពាក្យនេះ ពាក្យនេះគេប្រើជាមួយនឹងរបប លន់ នល់ គេប្រើពាក្យ "កម្ពុជា" គឺប្រជាជនកម្ពុជាដើម្បីកំណត់អំពីចរិតលក្ខណៈឱ្យខុសពីរបប លន់ នល់។ ដូច្នេះគេនិយាយអំពីពាក្យ "កម្ពុជា" ជាមួយនឹងវៀតណាមក្ដី រហូតមកដល់មានពាក្យមកថា "ប្រជាជនកម្ពុជា ដែលមានក្បាលយួនខ្លួនខ្មែរ"។ ហើយគេមិនបានប្រើ "កម្ពុជា" ទៅលើអ្នកថ្មីនោះទេ។ ឯពួក លន់ នល់ វិញនោះគឺថា គាត់ប្រើពួកខ្មែរក្រហមថាពួក "ទមិឡ" ដោយយកពាក្យនេះពីខាងស្រីលង្កាមកគឺ មានន័យថា "អ្នកដែលស្ថិតនៅក្រៅសាសនាធម៌អាចិ៍" គឺយកមកពីខាងស្រីលង្កាវិញ ថាខ្មែរក្រហមនេះជា "ពួកទមិឡ"។

[១៤:២៣:០០]

នេះគឺជាបញ្ហាមួយដែលស្មុគស្មាញណាស់ ខ្ញុំយល់ថា ខ្ញុំមិនអាចរកភស្ដុតាងជាឯកសារណាមួយដើម្បីឱ្យកំណត់ឱ្យឃើញថា គោលនយោបាយពីថ្នាក់កំពូល ដើម្បីកម្ទេច ឬកម្ចាត់អ្នកថ្មីនេះទាំងស្រុងតែម្ដង -- ក្រុមប្រជាជនថ្មីនេះទាំងស្រុងតែម្ដង។ ប៉ុន្តែបើមិនមានគោលនយោបាយ ក៏អ្នកទាំងអស់នោះវាមិនអាចស្លាប់ទៅបានដែរ។ មានរឿង រាប់លាននាក់ រាប់លានរឿងដែលថា ប្រជាជនកម្ពុជាហ្នឹងច្រើនណាស់ ដែលត្រូវបានគេបំផ្លិចផ្លាញចោល ដូច្នេះពិបាកនឹងរៀបរាប់ណាស់។

**ស៖** លោកអ្នកជំនាញ អ្វីដែលលោកទើបតែនឹងរៀបរាប់នេះ ធ្វើឱ្យខ្ញុំមានសំណួរមួយទៀត។ មេដឹកនាំខ្មែរក្រហមធ្វើបដិវត្តន៍ ដើម្បីឱ្យប្រជាជនមូលដ្ឋានទទួលបានសេរីភាព ជាសមូហភាព នៅពេលដែលយើងបានឮអ្វីដែលលោកបាននិយាយ ឬក៏អ្វីដែលយើងបានអាននេះ។ តើមិនមានការក្បត់ចំពោះប្រជាជនមូលដ្ឋាន អំពីសំណាក់មេដឹកនាំខ្មែរក្រហមទេឬ?

[១៤:២៤:៤១]

**ឆ៖** នេះជាសំណួរមួយដែលល្អ គឺថាអ្នកខ្លះគេមានអារម្មណ៍បែបនេះឯង។ កាលណានិយាយពីថា រំដោះប្រជាជនមូលដ្ឋាន គេមិននិយាយពីរំដោះពួកគាត់ពីការរស់នៅដ៏លំបាកលំបិននោះទេ មិនមានអ្នកណាដឹងថា រឿងនេះគឺបែបវាដូច្នេះដែរ គឺប្រជាជនមូលដ្ឋានគាត់ផ្ដល់ធនធានកម្លាំងទៅឱ្យខ្មែរក្រហមការណ៍ដែលគាត់រំដោះនេះ គឺរំដោះឱ្យរួចផុតពីភាពអយុត្តិធម៌ កុំឱ្យៗមានៗក្រ។ ដូច្នេះអ្វី -- នៅពេលនេះគឺអ្វីដែលគេចង់បាន ចង់ផ្ដល់សេរីភាព ចង់ផ្ដល់សិទ្ធិៗ ដូចជាឱ្យពួកមូលដ្ឋានគាត់មានសិទ្ធិបោះឆ្នោតដូច្នេះជាដើម គឺខុសពីក្រុមអ្នកដទៃទៀតនេះ។ គឺក្រុមពួកមូលដ្ឋាននេះគឺគាត់មានការការ -- ទទួលការ

គាបសង្កត់នេះតិចជាងអ្នកថ្មី។ លោកបានលើកគឺថាការផ្គត់ផ្គង់ស្បៀងអាហារ គឺខាងមូលដ្ឋាននោះ គឺគាត់មានការអត់ឃ្លានហ្នឹងតិចជាង ហើយក៏មានចូលរួមការបង្កបង្កើនផលហ្នឹងក៏តិចជាង។ ប្រជាជនមូលដ្ឋាន គឺជាប្រជាជនមួយដែលនៅមិនមែនជាស្ថិតនៅជាប់ខ្សែរយៈរបស់ពួកមូលធននិយម ពួកសក្តិភូមិនិយមទេ ខុសពីពួកទីក្រុង។ ហើយអ្នកខ្លះមិនដឹងថា អ្នកទីក្រុងហ្នឹងរបៀបម៉េចផង រស់នៅរបៀបណានោះផង ពួកមូលដ្ឋាននោះ។ ដូច្នេះកាលណាយើងនិយាយអំពីកត្តាសម្ភារៈវិញនេះ គឺពួកគាត់យល់ណាស់ និយាយអំពីតាមផ្នែកទ្រឹស្តី តាមផ្នែកលទ្ធិនេះ លើកលែងតែៗអ្នកដែលគេត្រូវបានបំពាក់អាវុធឲ្យកាន់នោះ គឺថាគាត់មានរឿងមួយយល់ទៅផ្សេង។ ដូច្នេះតាមៗទស្សនៈដែលខ្ញុំយល់នោះ តើលោកស្រីយល់ទេ?

[១៤:២៦:៥៨]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ខ្ញុំបញ្ចប់ការចោទសំណួរហើយ។ ខ្ញុំសូមអរគុណដែលបានផ្តល់ការបំភ្លឺដ៏សំខាន់ទាក់ទងនូវចំណុចអ្វីដែលខ្ញុំបានលើកឡើងទាំងអស់នេះ។ ខ្ញុំសូមផ្តល់វេទិកាទៅសហភារបស់ខ្ញុំ។

លោកប្រធាន សហភាគារបស់ខ្ញុំនឹងបន្តចោទសំណួរតទៀត។ តើ -- ឥឡូវនេះ តើគួរតែសម្រាកឬក៏យ៉ាងម៉េចលោកប្រធាន ឬក៏គាត់អាចបន្តចោទសំណួរឥឡូវតែម្តង ថាសួរតែម្តងឲ្យចប់តែម្តង?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក អូលីវីយ៉េ បាហ្វូញ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា ជម្រាបសួរលោក ឆេនដ័ល័រ ជម្រាបសួរ សហភាតាទាំងអស់។ ខ្ញុំឈ្មោះ អូលីវីយ៉េ បាហ្វូញ។

**សួរដោយលោក អូលីវីយ៉េ បាហ្វូញ៖**

**ស៖** ខ្ញុំមានសេចក្តីរីករាយ ហើយនិងកិត្តិយសក្នុងការសួរសំណួរទៅកាន់លោក លោកសាក -- លោកអ្នកជំនាញ។ លោក ដេវីដ ឆេនដ័ល័រ ខ្ញុំសូមចាប់ផ្តើមសួរសំណួរទៅកាន់លោក គឺជាដំបូងឡើងខ្ញុំសូមរំឭកអំពីការលើកឡើងរបស់លោក នៅពេលដែលលោកត្រូវបានស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០១ គឺជាសំណុំរឿងរបស់ ឌុច។ លោកបានលើកឡើងអំពីសាស្ត្រាចារ្យ មីលក្រាម គេបន្តពីការសួរ

របស់លោក ហ្វ្រង់ ស្វ័ររូ។

[១៤:២៨:៤០]

ហើយនៅពេលដែលលោកលើកឡើងអំពីគាត់នោះ លោកបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការសិក្សារបស់សាស្ត្រាចារ្យ មីលក្រាម ហើយលោកបានរៀបរាប់ថាជាចុងក្រោយនៅក្រោយពីការសិក្សារបស់គាត់នោះ គេសង្កេតឃើញថា ៧០ភាគរយ នៃប្រជាជន ៧០ភាគរយ ត្រូវបានធ្វើការធ្វើតេស្ត។ ដូច្នេះខ្ញុំដឹងថាលោកបានដឹងពីការសិក្សារបស់លោកសាស្ត្រាចារ្យរូបនេះ ហើយឥឡូវនេះគឺថាវាមានសារៈសំខាន់ណាស់ក្នុងការគិតគូរទៅដល់បរិបទ ឬក៏លក្ខខណ្ឌដែលបង្កើតបានជាបដិការនៃការគោរព ការស្ដាប់បង្គាប់។ លោកសាស្ត្រាចារ្យ មីលក្រាម បានពន្យល់ថា មុននឹងស្វែងរកការពន្យល់ផ្ទាល់ខ្លួនពាក់ព័ន្ធទៅនឹងការស្ដាប់បញ្ជានោះ យើងត្រូវតែគិតទៅលើការបង្ខំ ឬក៏ការគំរាមកំហែងទៅលើបុគ្គលដែលនឹងត្រូវស្ដាប់បង្គាប់អ្នកណាម្នាក់នោះ។

ដូច្នេះ ខ្ញុំចង់សួរសំណួរលោកមួយចំនួន ដើម្បីឲ្យលោកបំភ្លឺពាក់ព័ន្ធទៅនឹងការសិក្សាទាំងមូលរបស់លោក ហើយនិងយោងទៅតាមបទពិសោធន៍របស់លោកយោងទៅតាមចំណេះដឹងរបស់លោក ដើម្បីឲ្យដឹងថាតើធាតុផ្សំទាំងអស់ហ្នឹង អាចត្រូវបានចាត់ទុកថាវាជាបរិបទនៃការស្ដាប់បញ្ជាបានដែរឬទេ?

[១៤:៣០:២៥]

**ប្រធានអង្គជំនុំ៖**

តំណាងដើម -- មេធាវីការពារក្ដីលោក អៀង សារី មុន។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយសូមអធ្យាស្រ័យក្នុងការឡើង។ ហើយសហភាតាបានលើកករណីដែលមានទាក់ទិននឹងនៅក្នុងសំណុំរឿង០០១ ទាក់ទងនឹងចម្លើយរបស់លោកសាស្ត្រាចារ្យម្នាក់ដែលមេធាវីរបស់លោក កាំង ហ្កេកអ៊ាវ បានសួរ។ ហើយខ្ញុំអត់បានដឹងថា ការឆ្លើយឆ្លងសួរហ្នឹង វានៅក្នុងក្របខ័ណ្ឌណា នៅក្នុងទំព័រណា ហើយប្រតិចារឹកណា? អ៊ីចឹងសូមឲ្យសហភាតាបង្ហាញផងថា នៅក្នុងប្រតិចារឹកមួយណា នៅក្នុងទំព័រណា? ដើម្បីខ្ញុំចង់ដឹង គេសួរ គេឆ្លើយយ៉ាងម៉េចកន្លងមក។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[១៤:៣១:២៨]

**លោក ហ្សាស្កើ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ស្របជាមួយមេធាវីការពារម្ខាងទៀត គឺថាលោកបានលើកឡើងពីការពិសោធន៍មួយដ៏គួរឲ្យចាប់អារម្មណ៍ ហើយបទជំនាញរបស់លោក ឆេនដ៍ល័រ គឺមិនទាន់ទៅនឹងវិស័យចិត្តសាស្ត្រ ការពិសោធន៍ចិត្តសាស្ត្រទេ។ ហើយខ្ញុំចង់ដឹងថា តើលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាត់ចាប់អារម្មណ៍ដឹង ចង់ដឹងរឿងនេះ ដើម្បីគោលបំណងអ្វី គឺថាអាច -- បើមិនដូច្នេះទេ សូមឲ្យអ្នកជំនាញធ្វើការសន្និដ្ឋានដែលគាត់មិនមែនជាអ្នកជំនាញខាងចិត្តសាស្ត្រ ឬក៏ដែលគាត់មិនអាចផ្តល់យោបល់ជំនាញគាត់ទាក់ទងទៅលើការពិសោធន៍ខាងចិត្តសាស្ត្រ ខាងផ្លូវវេជ្ជសាស្ត្របែបនោះទេ។ ដូច្នេះខ្ញុំសូមជំទាស់ចំពោះសំណួរបែបនេះដែលតម្រូវឲ្យអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ឆ្លើយនោះ គឺមិនសមស្រប។

[១៤:៣២:២៨]

**លោក អូលីវីយ៉េ បាហ្ញូញ៖**

លោកប្រធាន ខ្ញុំអាចឆ្លើយតបទៅនឹងចំណុចនេះបាន។ ខ្ញុំសូមឆ្លើយតបទៅនឹងក្រុមរបស់ អៀង សារី។ លោកសាស្ត្រាចារ្យ ម៉ីលក្រាម នេះគាត់មិនបានធ្វើសក្ខីកម្មទេ។ នេះគឺជា -- លោក ឆេនដ៍ល័រ គាត់ជាអ្នកយោងនិយាយទៅកាន់លោក ម៉ីលក្រាម នេះ។ ប៉ុន្តែខ្ញុំសូមឲ្យពិនិត្យមើលលើឯកសារមួយដែលមានលេខ ERN ខ្មែរ 00361545, ERN ជាភាសាអង់គ្លេស 00361454។ ចំពោះសំណួរទីពីរដែលបានចោទសួរនោះ គឺលោកមិនទាន់បានដឹងសំណួរខ្ញុំនៅឡើយទេ ប៉ុន្តែលោកនឹងដឹង។ ខ្ញុំសូមបញ្ជាក់ថា កម្មវត្ថុនៃការសួរនេះ គឺថាដើម្បីកំណត់អំពីអត្តិភាព និងតួនាទីនៃធាតុផ្សំដែលបង្កើតបានទៅជាបរិបទនៃការស្តាប់បញ្ជា។

លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ លោកតែងតែ--

**ប្រធានអង្គជំនុំ៖**

លោកៗ មេធាវីឆ្លើយតបទៅនឹងមតិជំទាស់របស់ក្រុមមេធាវីការពារក្តីលោក នួន ជា ហើយឬនៅ? ដូចជាមិនទាន់ឆ្លើយទេ។ អង្គជំនុំជម្រះមិនទាន់បានសម្រេចពីបញ្ហាហ្នឹងផង។

តើលោកមានមតិយោបល់អ្វីជំទាស់ទៅនឹងមតិជំទាស់តវ៉ារបស់ក្រុមមេធាវីការពារក្ដីលោក នួន ជា ដែរឬទេ? ពីព្រោះអំមិញហ្នឹងមានការជំទាស់តវ៉ាពីរភាគី គឺមេធាវីជាតិការពារក្ដីលោក អៀង សារី ផង ហើយនិងមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។ ដោយឡែកមេធាវីការពារក្ដីលោក អៀង សារី គ្រាន់តែកត់សម្គាល់សុំឱ្យមានការបង្ហាញអត្តសញ្ញាណឯកសារប៉ុណ្ណោះ។ ខ្លឹមសារដែលសំខាន់ គឺការជំទាស់របស់ក្រុមមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។

[១៤:៣៤:៤៣]

**លោក អូលីវីយេ បាហូញ៖**

ពាក់ព័ន្ធទៅនឹងការជំទាស់របស់មេធាវី អៀង សារី ខ្ញុំបានផ្ដល់លេខយោង ERN រួចទៅហើយលោកប្រធាន គឺប្រតិចារឹកដែលមានលេខអម្បាញ់មិញនេះ គឺប្រតិចារឹកនៃសវនាការដែលស្ដាប់ចម្លើយរបស់លោក ដេវីដ ឆេនដ៍ល័រ នៅក្នុងក្របខ័ណ្ឌសំណុំរឿង០០១ ដែលជាក្របខ័ណ្ឌប្រឆាំង -- សំណុំរឿងប្រឆាំងនឹង ឌុច។ នេះគឺជាទំព័រពាក់ព័ន្ធ ដែលលោក ដេវីដ ឆេនដ៍ល័រ បាននិយាយយោងពីបញ្ហានេះ។ ហើយ--

**ប្រធានអង្គជំនុំ៖**

តែលោកមានអ្វីឆ្លើយតបទៅនឹងចម្លើយ -- ការជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា ដែរឬទេ? ជំទាស់ទៅលើខ្លឹមសារ ទៅលើវិធីនៃការដែលលោកតាំងសំណួរ បែបចិត្តសាស្ត្រ បែបវេជ្ជសាស្ត្រនេះ ដែលអ្នកជំនាញរូបនេះគឺមិនមែនមានគុណភាពក្នុងនាមអ្នកជំនាញប្រភេទនោះទេ។

**លោក អូលីវីយេ បាហូញ៖**

ខ្ញុំសូមឆ្លើយតបថានៅក្នុងការជំទាស់របស់គាត់នោះ គឺគាត់បានលើកឡើងថា គាត់មិនទាន់បានឮសំណួរ ដូច្នេះខ្ញុំនឹងចោទសួរសំណួរ។ ហើយពេលនោះគាត់នឹងអាចវិនិច្ឆ័យបានហើយ ថាតើសំណួររបស់ខ្ញុំនោះពាក់ព័ន្ធទៅនឹងចំណេះដឹងខាងផ្នែកចិត្តសាស្ត្រ ឬក៏ចំណេះដឹងខាងផ្នែកជំនាញរបស់បុគ្គលណាម្នាក់ ដែលគាត់មានចំណេះដឹងខ្ពស់ គាត់មានបទពិសោធន៍ខ្ពស់។ ដូច្នេះ ខ្ញុំគិតថា ខ្ញុំបានឆ្លើយតបទៅនឹងខាងមេធាវី នួន ជា រួចទៅហើយ ព្រោះខ្ញុំមិនទាន់បានសួរសំណួរផង គាត់ឡើងជំទាស់។

[១៤:៣៦:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញតាំងសំណួរជាក់លាក់!

**លោក អូលីវីយេ បាហូញ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អូលីវីយេ បាហូញ៖**

**ស៖** លោក ដេវីដ ឆេនដ័ល័រ តើលោកអាចបញ្ជាក់ប្រាប់ខ្ញុំបានទេថា តើប្រជាជន កសិករខ្មែរនោះមានកម្រិតអប់រំបែបណានៅក្នុងឆ្នាំ៧៥? តើយើងអាចកំណត់ឱ្យបានច្បាស់ទេ បានថាល្អ មិនសូវល្អ មធ្យម ខ្សោយ ឬក៏ខ្សោយបំផុត? ថាតើលោកកំណត់យ៉ាងណាអំពីកម្រិតអប់រំរបស់ប្រជាជននៅ -- របស់អ្នកកសិករនោះនៅឆ្នាំ៧៥ នោះ?

[១៤:៣៧:២៧]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំអាចផ្តល់ជូនតែស្ថិតិ ដោយជាក់ច្បាស់នោះ គឺមិនអាចទេ គឺថាកម្រិតអនក្ខរភាពនោះគឺថាខ្ពស់បំផុតនោះស្ត្រី ហើយនិងមនុស្សចាស់ៗហ្នឹង ហើយនិងទាបបំផុតចំពោះក្មេងៗដែលទៅសាលា។ ចំនួនកុមារហ្នឹងគឺថា កុមារច្រើនក្នុងសម័យ សីហនុ ដែលទៅសាលា។ ហើយខ្ញុំពិនិត្យឃើញថា នៅពេលដែលខ្ញុំពិនិត្យឯកសារនៅទួលស្លែងនោះ ខ្ញុំឃើញថា កម្រិតអនក្ខរកម្ម អនក្ខរភាពនេះគឺថាអាចនឹងមានកម្រិតការសិក្សាថ្នាក់មួយដែលថា គាត់អាចសរសេរ និងអាចវាយអង្គុលីលេខបាន។ គឺថាចំពោះអ្នកស្រែវិញ ប៉ុន្តែកម្រិតសិក្សាអប់រំមិនខ្ពស់ទេ។ ប៉ុន្តែមិនគួរអ្វីគួរឱ្យខ្មាសអៀនទេ ដោយសារធនធានកម្ពុជា ដោយសារមិនមែន -- កម្ពុជាមិនមែនជាប្រទេសមានសាលាគ្រប់គ្រាន់សម្រាប់កំណើនប្រជាជនទេ។ ហើយនៅពេលដែលយើងពិនិត្យជនបទវិញ ផ្នែកខ្លះនោះ មិនមានសាលារៀន មិនមានការអប់រំនោះទេ។ ហើយនៅក្នុងដូចជាកំណត់ហេតុមួយរបស់ប្អូនរបស់ តាម៉ុក ហ្នឹងគឺថា នៅរហូតដល់ឆ្នាំ១៩៧០ ជាងហ្នឹងគឺថា មិនដែលបានឃើញជនជាតិអឺរ៉ុបណាមួយទេ រហូតដល់គាត់អាយុ១៥ឆ្នាំ មិនដែលឃើញជនជាតិបរទេសទេ។

[១៤:៣៩:០០]

អ៊ីចឹងហើយ គឺមិនមានបឋមសិក្សារដ្ឋ ឬក៏វិទ្យាល័យរដ្ឋទេ នៅក្នុងជនបទមួយចំនួននោះ។ អ៊ីចឹងហើយអនក្ខរភាពនោះគឺថាមានកម្រិតទាប ហើយនិងកម្រិតហ្នឹងគឺថា ផ្នែកខ្លះគឺថាវាមានកម្រិតខ្ពស់។ ហើយខ្ញុំសង្កេតឃើញថា អ្នកខ្លះមានជំនាញការសរសេរដៃ ហើយនិងវាយអង្គុលីលេខហ្នឹងបានល្អដូចជាបុគ្គលិកនៅ ស-២១ កាលនោះជាដើម។ គឺថា ខ្ញុំអាចនឹងសន្និដ្ឋានថា អ្នកទាំងនោះក៏ប្រាកដជាបាន

ទៅសាលាកម្រិតណាមួយអាចយល់ អាចមានការអប់រំគ្រាន់បើ ហើយក៏ខ្ញុំមិនអាចអះអាងថា គេទទួលការអប់រំក្នុងសម័យខ្មែរក្រហមដើម្បីសរសេរនោះដែរ។

**សះ** សូមអរគុណលោកសាស្ត្រាចារ្យ។ នៅក្នុងក្របខ័ណ្ឌនៃការឆ្លើយសំណួររបស់លោកនៅក្នុងសំណុំរឿង០០១ ខ្ញុំសូមបញ្ជាក់លេខ ERN ជាភាសាខ្មែរ 00361546, ERN ជាភាសាអង់គ្លេស 00361456, ERN ជាភាសាបារាំង 00361720។ លោក សាស្ត្រាចារ្យ នៅក្នុងប្រតិចារឹកនោះលោកបានឆ្លើយថា "អ្នកដែលចេញបញ្ជានោះ គឺថាគាត់ធ្លាប់ -- គាត់ទម្លាប់ទៅនឹងការចេញបញ្ជា ហើយអ្នកដែលស្តាប់នោះគឺទម្លាប់តែស្តាប់"។ ដូច្នេះនៅប្រទេសកម្ពុជាមិនមានវប្បធម៌នៅក្នុងការពិនិត្យមើលសើរើទៅលើការចេញបញ្ជារបស់បុគ្គលថ្នាក់លើទេ គឺគេចេញទៅអ្នកក្រោមត្រូវតែស្តាប់។ ម្យ៉ាងវិញទៀត គឺថាមិនមានការតវ៉ាអីចំពោះគ្រូបង្រៀនទេ តែគ្រូបង្រៀនថា ម៉េចគឺសិស្សត្រូវតែថាតាមហើយ។ ហើយនៅពេលដែលយើងជាបញ្ញាជន ជាបញ្ញវន្តនោះ លោក ខៀវ សំផន, លោក អៀង សារី ដែលគាត់ថា ជាបញ្ញវន្ត បញ្ញាជននោះគាត់មាន -- គាត់មានឋានៈដូចថា របៀបថា ពិសេសមួយដែលលើសពីគេ។ តើវាអ៊ីចឹងមែនទេ លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ?

[១៤:៤១:២៣]

**ឆះ** ខ្ញុំមិនច្បាស់ថា តើគាត់មានឋានៈពិសេសអ្វីទេ។ ខ្ញុំមានកំណត់ត្រាអំពីសាលារបស់គាត់ ឬក៏ឋានៈពីមុនរបស់គាត់នោះទេ។ ប៉ុន្តែដើម្បីឆ្លើយទៅនឹងសំណួររបស់លោកនោះ ប៉ុល ពត ជាគ្រូបង្រៀននៅសាលាជាមួយលោក អៀង សារី នោះ គឺមានគំនិតខ្ពស់ ហើយសិស្សសរសើរពួកគាត់ណាស់ គឺថាមិនឲ្យសួរគាត់ទេ គឺថាសិស្សត្រូវតែស្តាប់ពួកគាត់ ដោយហេតុថា គ្រូទាំងពីរនេះ គឺថាគឺជាមនុស្ស គឺថាអ្នកដែលបានជួបគាត់ដំបូងហ្នឹង គឺថាកាលពីគាត់អាយុ ១៤ឆ្នាំ បានជួបពួកគាត់នោះហើយ គឺគួរចង់ស្គាល់គាត់ជារៀងរហូត ហើយគាត់មិនមែនជាគ្រូធម្មតាទេ។

រីឯ ខៀវ សំផន ក្នុងឋានៈជាគ្រូបង្រៀន ការបង្រៀនរបស់គាត់ល្អ គាត់មានកិត្តិយសល្អតាំងពីមុនបដិវត្តន៍ ជាគ្រូ ហើយជាអ្នកកាសែត ហើយជាមនុស្សស្អាតស្អំ មិនមានពុករលួយទេ ជាសមាជិកសភា ហើយមានការយកចិត្តទុកដាក់ជាសមាជិកគណៈរដ្ឋមន្ត្រី។ ចំណុចនេះទាំងអស់នេះ ធ្វើឲ្យគេគោរពគាត់ មិនត្រឹមតែគោរពធម្មតាទេ គឺមេរបស់គាត់ក៏ត្រូវគោរពគាត់ដែរ។ ដោយសារអាកប្បកិរិយារបស់គាត់ គឺវាខុសពីមនុស្សធម្មតា។

[១៤:៤២:៥៣]

កម្ពុជា គឺថាទទួលស្គាល់ណាស់ កាលណាអ្នកប្រព្រឹត្តក្នុងចរិយាល្អ ដោយមានមនុស្សធម៌ ខ្ញុំនឹងប្រកាន់គំនិតរបស់ខ្ញុំដែលថា នេះមិនមែនថា អំណាច ឬក៏អំណាចផ្តាច់ការត្រូវតែមានគំរូបែបនេះនោះទេ។ ក៏ប៉ុន្តែនៅពេលដែលមានបញ្ហា ពេលខ្លះគឺភាគច្រើនគេមិនឲ្យជជែកដេញដោលមកវិញទេ។

ខ្ញុំសូមបន្ថែមពាក្យមួយ គឺថាពាក្យ “គោរព” ចំពោះកម្ពុជានេះ ដូចបញ្ហាហ្នឹង គឺថាមិនមានន័យថា គោរពនោះនៅក្នុងដូចជាភាសាអង់គ្លេស ឬបារាំងនោះ។ គឺថា ពាក្យ “គោរព” ហ្នឹង គឺថាត្រូវតែទទួលបញ្ជា។ បើសិនជាទទួលបញ្ជាហើយ យើងមិនមានជម្រើសថា ត្រូវធ្វើមិនធ្វើទេ គឺថាគេបញ្ជាឲ្យធ្វើអីគឺត្រូវធ្វើហ្នឹង ខុសក៏ដោយត្រូវក៏ដោយ អាហ្នឹងគឺអីចឹង។ នេះ គឺជាការបែងចែកដ៏ត្រឹមត្រូវសំខាន់កន្លែងនេះ។

[១៤:៤៤:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី ហើយអ្នកជំនាញ ឥឡូវដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញដល់អ្នកជំនាញក្នុងរយៈពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបានកំណត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុម

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលសិទ្ធិ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អូលីវីយ៉េ បាហ្វូញ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងនិយាយឲ្យបានយឺតៗ ដើម្បីឲ្យអ្នកបកប្រែធ្វើការបកប្រែបានល្អ។

**សួរដោយលោក អូលីវីយ៉េ បាហ្វូញ៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ បើតាមបទពិសោធន៍របស់លោក ហើយនិងចំណេះដែលលោកបានទទួលជាបន្តបន្ទាប់ តើលោកអាចបញ្ជាក់បានទេថា ការកម្ទេចបញ្ញាជន វិញ្ញូជនទាំងឡាយនោះ គឺវាជាការចូលរួមចំណែកបង្កើតនូវប្រព័ន្ធដែលលោកបានលើកឡើងតាំងពីមុនមកនោះ គឺថាតាំងពីនៅក្នុងសំណុំរឿង០០១ មកនោះ?

[១៥:០២:៣៦]

ខ្ញុំផ្តល់ជូននូវលេខ ERN ជាភាសាខ្មែរគឺលេខ 00361543, ERN ជាភាសាអង់គ្លេស 00361450, ភាសាបារាំង 00361704។

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** សូមលោកអានការដកស្រង់នេះឲ្យខ្ញុំស្តាប់បន្តិចបានទេ ព្រោះលោកដកស្រង់នេះមកពីក្នុងសំណុំរឿង០០១? ឬក៏ខាងភាសាបារាំងក៏ដូច្នេះដែរ គឺថាអាចអានជាភាសាបារាំងជាអ៊ីចឹងមក។

**ស៖** លោកសាស្ត្រាចារ្យ ខ្ញុំមានតែជាភាសាបារាំងទេ។ "ប្រទេសទាំងមូលបានក្លាយទៅជាមានភាពឯកោពីពិភពខាងក្រៅ"។ នេះគឺលោកនិយាយអំពីស្ថាប័នស្វយ័ត គឺមានន័យថាជាស្ថាប័នស្វយ័តដែលកាត់ផ្តាច់ពីគេ គឺជាពាក្យរបស់ទស្សនវិទូអាមេរិកាំង គឺ អ៊ាក់វីន ដុហ្វម៉ាន់ គឺគាត់ជាអ្នកប្រើពាក្យថា ស្ថាប័នស្វយ័តនេះ។ ថាជាកន្លែងដូចជា គឺថាមានកាត់ផ្តាច់ពីពិភពខាងក្រៅ អត់មានទំនាក់ទំនងជាមួយអ្វីខាងក្រៅ គឺបិទជិតតែម្តង។

[១៥:០៤:៣៦]

**ឆ៖** សូមអរគុណ។ នៅក្នុងបរិបទនេះ សៀវភៅស្តីអំពី "សំឡេងពីស-២១" គឺស-២១ គឺជាស្ថាប័នមួយដាច់ដោយឡែក ដែលអាចចង្អុលបង្ហាញថា ប្រទេសកម្ពុជាចន្លោះពី១៧ មេសា ៧៥ ទៅដល់ ០៦ មករា ៧៩ បានប្រែក្លាយទៅជាស្ថាប័នមួយដាច់ដោយឡែក ដាច់ដោយការ -- ដោយគោល

នយោបាយគ្រប់គ្រងដោយរបបនោះ។ នៅពីមុននោះគឺ ថាតើការ -- សំណួររបស់លោកសួរថា តើការកម្ទេចបញ្ញវន្តហ្នឹង ខ្ញុំដូចជាបាត់សំណួររបស់លោកមួយផ្នែក។ ខ្ញុំមិនចង់ចូលទៅពាក្យថា "កម្ចាត់" ទាំងស្រុង ដោយសារអ្នកខ្លះគឺថា បានរស់រានមានជីវិត អ្នកខ្លះក៏ត្រូវបានសម្លាប់ ដូច្នេះខ្ញុំមិនចង់ប្រើពាក្យថា *អ៊ីលីមីណេត* គឺថា "កម្ចាត់ចោល" នេះទេ។

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យសូមផ្អាកតិចសិន មានការតវ៉ាពីមេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដូចដែលសហការីបានឆ្លើយហើយ ហើយសាស្ត្រាចារ្យ ឆេនដ័ល័រ ក៏បានប្រើដែរ បរិបទនេះគឺប្រើតែនៅស-២១ មិនមែនប្រើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះទេ។ ដូច្នេះ--

[១៥:០៦:៣៨]

**លោក អូលីវីយ៉េ បាហ្សូញ៖**

ខ្ញុំអាចឆ្លើយតបទៅនឹងសំណួរបាន ខ្ញុំនឹងចាប់ផ្ដើមឆ្លើយចំពោះមេធាវីការពារក្ដី ហើយខ្ញុំគិតថា ចម្លើយនោះក៏អាចបញ្ជាក់បានចំពោះសាស្ត្រាចារ្យ ឆេនដ័ល័រ ផងដែរ។ ការលើកឡើងរបស់គាត់នេះគឺថា ប្រទេសទាំងមូលបានក្លាយទៅជាបរិយាកាសមួយដ៏ស្ងប់ស្ងាត់ដាច់ឆ្ងាយពីពិភពខាងក្រៅ គឺបិទជិតតែម្ដង។ ហើយនៅទំព័រ -- នៅជួរទី២៤ លោកបាននិយាយអំពីស្ថាប័នស្វយ័តមួយ។

**សួរដោយលោក អូលីវីយ៉េ បាហ្សូញ៖**

**ស៖** ដូច្នេះគឺខ្ញុំសួរទៅកាន់សាស្ត្រាចារ្យ ឆេនដ័ល័រ។ ពិតណាស់គឺថាពាក្យដែលខ្ញុំប្រើពាក្យថា "លុបបំបាត់" ឬក៏ "កម្ទេច" គឺថាជាពាក្យទូទៅ។ គឺថាការដាក់ បើថាប្រើពាក្យថា "ដាក់ឱ្យនៅក្រៅសង្គម" នោះ វាដូចជាហួសហេតុពេក គឺថាមានវិញ្ញូជន ហើយនិងបញ្ញាជនជាច្រើនត្រូវបានសម្លាប់ចោល។ ដូច្នេះខ្ញុំអាចនិយាយបានថា គឺថាដើម្បីគឺថាបំបិទមាត់។ គឺថាធ្វើយ៉ាងណាបំបិទមាត់ ឬក៏សម្លាប់ចោលបញ្ញាជន ឬក៏វិញ្ញូជន បញ្ញវន្តផ្សេងៗ គឺធ្វើយ៉ាងណាឱ្យបង្កើតបានជាស្ថាប័នស្វយ័តមួយដែលលោកខ្លួនឯងផ្ទាល់នេះលោកជាអ្នកផ្ដល់និយមន័យចំពោះពាក្យនេះ។

[១៥:០៨:០៩]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** សូមអរគុណចំពោះការបញ្ជាក់ឡើងវិញនេះ ដូចដែលលោកដឹងហើយ គឺថាសហព្រះរាជអាជ្ញាបានប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យមួយបានល្អជាងនេះ។ ការដែលលុបបំបាត់បញ្ញវន្តនេះគឺតាមពិតទៅគឺថាវាដូច្នេះហើយ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថាការចាត់ថ្នាក់បញ្ញវន្តនៅក្នុងប្រទេសកម្ពុជានៅក្នុងពេលនោះ គឺហៅថា អ្នកចេះដឹង អ្នកដែលមានចំណេះដឹងជ្រៅជ្រះ មិនមែនអ្នកណាម្នាក់ដែលទើបតែបញ្ចប់ការសិក្សារៀនសូត្រនៅក្នុងបញ្ហាណាមួយនោះ វាអាចជាសាស្ត្រាចារ្យ វាអាចជាសិស្សវិទ្យាល័យ។

គេអាចដឹងហើយនៅក្នុងមនុស្សប្រភេទនេះ គេអាចដឹងខ្លួនគេ។ ប៉ុន្តែរបបនោះគឺថាពិតជាមានការចេតនាបំបាត់នូវបញ្ញវន្តនេះ។ ខ្ញុំមិនចង់ប្រើពាក្យថា “បំបិទមាត់ឲ្យនៅស្ងៀមស្ងាត់” អី។ គឺការដែលកម្ចាត់នោះ គឺគេបំបិទមាត់ចង់ឲ្យបញ្ញវន្តទាំងអស់នោះធ្វើអ្វីទៅតាមរបបនោះចង់ឲ្យធ្វើ ហើយការនិយាយរបស់ពួកបញ្ញវន្តនេះ គឺត្រូវតែនិយាយនៅក្នុងកម្រិតមួយនៅក្នុងទីកន្លែងមួយបរិបទមួយទៅតាមរបបនេះ។ ដូច្នេះគឺមិនចង់ពួកគេជំទាស់ ឬប្រឆាំងជាមួយនឹងរបបនោះទេ។

[១៥:០៩:៤០]

ប្រជាជនជាច្រើនដែលគាត់មានការចងចាំ នឹកឃើញឡើងវិញនូវការ -- ថ្ងៃរំដោះថ្ងៃ១៧ មេសា ៧៥ របស់ទីក្រុងភ្នំពេញ គេចាំថា គឺមនុស្សយ៉ាងហោចណាស់រៀនចប់វិទ្យាល័យគឺគេប្រាប់ថា មិនស្គាល់អាម៉េចដែលហៅថា “បក្សកុម្មុយនីស្តកម្ពុជា” គ្រាន់តែដឹងថាសង្គ្រាមចប់ហើយ ខ្ញុំរៀនចប់វិទ្យាល័យ ខ្ញុំអាចជួយប្រទេសជាតិបានហើយ។ លើកលែងតែអ្នកដែលមានឈ្មោះនៅក្នុងបក្សរួចហើយទើបបានគាត់បានដឹង គឺថាបក្សកុម្មុយនីស្តកម្ពុជា គាត់បាន -- នៅក្នុងឆ្នាំ៧៦ បង្កើតនូវគណៈរដ្ឋមន្ត្រីដោយផ្តល់តួនាទីឋានៈទៅដល់កម្មាភិបាលរបស់គាត់មួយចំនួន ដូចជានៅក្នុងក្រសួងការបរទេស ក្រសួងពាណិជ្ជកម្មជាដើម។ ប៉ុន្តែចំពោះបញ្ញវន្តទាំងមូលនោះតែម្តង គឺថាត្រូវបានគេប្រព្រឹត្តមកលើពួកគាត់យ៉ាងអាក្រក់បំផុត មិនត្រូវបានគេគោរពចំពោះខ្លួនពីពេលមួយទៅពេលមួយ ហើយមិនត្រឹមតែបញ្ញវន្តទេ វាក៏ការប្រព្រឹត្តនេះក៏ធ្វើទៅលើប្រជាជនកម្ពុជាជាទូទៅផងដែរ។

[១៥:១០:៥៩]

នៅក្នុងទសវត្សរ៍៦០ គឺថាគេគោរពអ្នកដែលមានការចេះដឹងណាស់ គឺវាជា ថាកាលណាអ្នកនោះជាបញ្ញវន្ត គឺអ្នកនោះមានការចេះដឹង ប៉ុន្តែក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យល់ថា ការចំណេះដឹងបែបនេះគឺមិនមានប្រយោជន៍អ្វីទេ គឺថាធ្វើឲ្យប្រជាជននៅពេលនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង មិន

ត្រឹមតែបញ្ញវន្តទេ គឺទាំងនៅក្នុងជួរប្រជាជនទូទៅផងដែរ។ មានន័យថា អ៊ីចឹងប្រជាជនគាត់ថា កូនចៅរបស់ខ្ញុំមិនបាច់ត្រូវទៅសាលារៀនទេ ហើយឆ្លើយថា មិនបាច់ទៅសាលារៀនទេ។ នេះគឺជារបបមួយថ្មី ប្រទេសមួយថ្មី។ សាលារៀនគឺថា -- គេពីសង្គមកម្ពុជាគោរពទៅដល់អ្នកចេះដឹង ប៉ុន្តែពេលនោះគឺថា មិនមែនដូច្នេះទេ។

[១៥:១១:៥៦]

**សៈ** សូមអរគុណលោកសាស្ត្រាចារ្យ។ ដោយសារតែលោកនិយាយថា ពួកគេមិនត្រូវបានកម្ទេចទេគឺ គេគ្រាន់តែឲ្យពួកគាត់សរសេរ ឬក៏បង្ហាញពីបំណងដែលអង្គការចង់បាន តើយើងអាចបាននិយាយថាការត្រួតត្រាទៅលើបញ្ញាស្មារតី ឬក៏ការគិតរបស់ពួកគេបានទេ? តើខ្ញុំអាចប្រើពាក្យនេះបានទេ?

**ផៈ** ខ្ញុំគិតថា ឃ្លានេះ គឺរបបនេះមិនបានប្រើឃ្លានេះទេ ប៉ុន្តែគេព្យាយាមធ្វើបែបនេះ ដូចដែលខ្ញុំបាននិយាយរួចមកហើយគឺថា មានកងឈ្លបក្មេងៗលបស្តាប់ប្រជាជននិយាយគ្នា។ ឧទាហរណ៍ អ្នកខ្លះគឺនិយាយភាសាបរទេស គេអាចនឹងទាញអូសដៃចេញមក ឬក៏ចាប់ខ្លួន។ នេះឯងគឺការបំបិទមាត់ គឺថាកងឈ្លបទាំងនោះ ត្រូវបានគេដុសខាត់ខួរក្បាល ដើម្បីឲ្យតាមដានបែបនេះ។ ប៉ុន្តែជាការពិតហើយ អ្វីដែលខ្ញុំគិតទៅដល់ការយល់ឃើញនេះគឺថា--

[១៥:១៣:៣១]

**សៈ** យើងទើបតែបាននិយាយអំពីកម្រិតអប់រំ ហើយនិងការផ្តល់អំណាចទៅដល់ការបង្រៀន ហើយនិងសិទ្ធិសេរីភាពក្នុងការគិត ឥឡូវនេះ ខ្ញុំចង់បង្ហាញជូននូវបរិបទស្តាប់បង្គាប់មួយទៀតគឺថា ការដកតម្លៃជនរងគ្រោះ។ តើលោកមានធ្លាប់ឃើញអំពីសុន្ទរកថា ឬក៏ធាតុផ្សំអ្វីដែលបន្ថោក បន្ទាបតម្លៃទៅលើក្រុមមនុស្ស ឬក៏ជនរងគ្រោះអ្វីដែរឬទេ?

**ផៈ** ខ្ញុំមិនអាចឆ្លើយទៅនឹងសំណួរនេះទេ ប៉ុន្តែខ្ញុំដឹងថា ចម្លើយសារភាពពីស-២១ គឺមានចំណារដែលចារដោយ ឌុច ដែលបញ្ចុះ បន្ទាបបន្ថោកតម្លៃមនុស្ស ដោយការនិយាយថា "ចម្លើយរបស់ពួកគេគឺមិនមានតម្លៃអ្វីនោះទេ"។ ដូច្នេះ អ្នកទាំងអស់នេះ គឺថាត្រូវបានគេបញ្ចុះតម្លៃ បញ្ចុះអំណាច ហើយក៏មានការបើកវគ្គសិក្សានៅតាមជនបទ ដែលមានសុន្ទរកថាតឹងតែងមួយចំនួន។ ខ្ញុំមិនមានប្រតិចារឹក ឬក៏ចំណារពីចំណុចនេះទេ។ ប៉ុន្តែនៅក្នុងវគ្គសិក្សារៀនសូត្រ ខ្ញុំយល់ឃើញថា យើងបានឃើញឯកសារនេះកាលពីម្សិលមិញម្សិលម្ង៉ៃរួចមកហើយ គឺថាមានក្រុមមនុស្សម្នាក់គេដាក់ឲ្យនៅដោយឡែក ជាពិសេស

ជាមនុស្សដែលជាគោលដៅ ហើយមនុស្សណាដែលអាចសម្របសម្រួលនៅក្នុងវាយប្រហារទៅលើពួកវៀតណាម ឬក៏អាចសម្រួលក្នុងការវាយប្រហារទៅលើពួក លន់ នល់ សាសនាជាដើម។ល។ ដូច្នេះនៅពេលណាគេមានវត្តមាននៅចំពោះមុខមហាជន គឺថាគេលើកឡើងចំណុចទាំងនេះមកនិយាយ វាជាការពិតហើយ។

[១៥:១៥:៤៧]

**លោក អូលីវីយ៉េ បាហ្សូញ៖**

លោកប្រធាន ខ្ញុំចង់បង្ហាញនូវសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយដែលបង្ហាញអំពីការជេរប្រទេច។ តើខ្ញុំអាចផ្ដល់ឯកសារនេះ ផ្ដល់លេខឯកសារបានទេលោកប្រធាន? គឺឯកសារលេខ D22/622។ ERN ជាភាសាខ្មែរ 00499847 រហូតទៅដល់ 00499861។ ឯកសារនេះមិនមានជាភាសាអង់គ្លេស ឬបារាំងទេ។ ដោយសារតែខ្ញុំមិនចេះភាសាខ្មែរនោះ ខ្ញុំសូមឲ្យជំនួយការជាភាសាខ្មែរនោះអាចបកប្រែឲ្យខ្ញុំស្ដាប់បាន។ ខ្ញុំមិនបាន -- ខ្ញុំមិនផ្ដល់ឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ។ ខ្ញុំសូមបញ្ជាក់ផងដែរថា ខ្ញុំមានសក្ខីកម្មជាច្រើនពាក់ព័ន្ធទៅនឹងចំណុចនេះ ប៉ុន្តែខ្ញុំលើកឡើងតែមួយទេដើម្បីចំណេញពេលវេលា។

**សួរដោយលោក អូលីវីយ៉េ បាហ្សូញ៖**

**ស៖** "ពួកខ្មែរក្រហមតែងតែជេរខ្ញុំ គឺថា អាចាម ជេរថា អាចាម។ ខ្ញុំមិនយល់ពីន័យនៃពាក្យថា អាចាម នេះទេ។ លោកមិនមានប្រទេសអីទេ អាចាម អ្នែងអត់មានប្រទេសទេ អ៊ីចឹងត្រូវតែកម្ទេចចោល"។ តើលោកមានធ្លាប់ឮពាក្យគេហៅជេរថា ពាក្យ "អាចាម" នេះទេ?

[១៥:១៧:២៤]

**លោក ជេរីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំចង់ឃើញសំណេរហ្នឹងជាភាសាខ្មែរ។ ដោយថា ដូច ខ្ញុំដូចជាស្ដាប់មិនទាន់យល់។ ចង់ឃើញអត្ថបទនេះជាភាសាខ្មែរ។ ពីព្រោះខ្ញុំមិនដឹងស្ដាប់ឮថា "អាចាន់" ឬក៏ "អាចាម"។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! ឯកសារនេះមាននៅក្នុងបញ្ជីឯកសារស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរឬទេលោកមេធាវី?

**លោក អូលីវីយេ បាហួញ៖**

បាទ លោកប្រធាន គឺឯកសារនេះត្រូវបានផ្តល់ជូនរួចទៅហើយតាមតែអ្វីដែលបានអង្គជំនុំជម្រះបង្គាប់មកនោះ។

[១៥:១៨:២៥]

**លោក ដេវីដ ឆេនដ៏ល័រ៖**

**ឆ៖** ជាការពិតហើយ។ នេះគឺសំដៅទៅលើចាមហើយ អាចាម ហើយ ប៉ុនឮសូរស្ទានតែចាន់។ "អា" នេះគឺជាបុព្វបទមួយ ដែលជាពាក្យមើលងាយមនុស្សឲ្យមានកិត្តិយសឋានៈទាប។ ពាក្យនេះខ្លាំងធ្ងន់ធ្ងរ គេហៅសំដៅទៅលើពាក្យក្មេងៗ "អាចាម" គឺមានន័យថាជាពាក្យបន្ទាបបន្ថោក គឺដាក់ពួកចាមនេះមកឲ្យនៅមួយអន្លើ មួយឡែក។ ជាការពិតហើយ គឺមានន័យយ៉ាងដូច្នេះឯង។

**ប្រធានអង្គជំនុំ៖**

បើកក្បាលមីក្រូសិន លោកមេធាវីអត់ទាន់មាន -- បាទៗ។

**សួរដោយលោក អូលីវីយេ បាហួញ៖**

**ស៖** បើតាមបទពិសោធន៍របស់លោក និងតាមការដែលលោកបានអានឯកសារនានានោះ តើការបោះបង់ចោលសាកសពដែលគ្មានការពិធីបូជា ឬក៏បញ្ចុះអីនោះ តើដូចជាសត្វធាតុ សត្វតិរច្ឆានអីចឹង ចោលកណ្តាលភ្លៀង ខ្យល់ តើអ្វីទាំងអស់នេះគឺជាការបន្ទាបបន្ថោកទៅលើជនរងគ្រោះដែរឬទេចំពោះយោបល់របស់លោកនោះ?

[១៥:១៩:00]

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យកុំអាលទាន់ឆ្លើយតប មានការជំទាស់ពីមេធាវីជាតិ -- អន្តរជាតិការពារក្តីលោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សំណួរនេះមិនមែនជាសំណួរដែលត្រូវសួរទៅអ្នកជំនាញ របស់អ្នកជំនាញទៅទៀតទេ ដែលទាក់ទងទៅនឹងបញ្ហាសាកសពនេះ។ គឺថាត្រូវតែសួរ ថាតើពាក្យថាការវាយតម្លៃបន្ទាបបន្ថោកជនរងគ្រោះនោះមានន័យយ៉ាងម៉េច? ឬក៏យ៉ាងម៉េចនោះ? ត្រូវសួរទៅអ្នកជំនាញលើអ្នកជំនាញទៀត។

[១៥:២០:៤៣]

**លោក អូលីវីយ៉េ បាហូញ៖**

លោកប្រធាន ខ្ញុំគិតថា គាត់ដូចជាមានការឆ្ងេងយល់អីសោះ។ យើងត្រូវតែយល់អំពីសក្ខីកម្មជាច្រើនដែលសាក្សីបានឆ្លើយ ហើយមានដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ដែលគាត់បានផ្តល់ជាព័ត៌មានជាច្រើនពាក់ព័ន្ធទៅនឹងចំណុចនេះ ហើយលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ក៏គាត់បានធ្វើបានដែរ។ គឺធ្វើយ៉ាងណា ដើម្បីឲ្យដឹងថាអ្នកទាំងអស់នោះ មានការរង្កៀសចិត្តយ៉ាងខ្លាំងពាក់ព័ន្ធទៅនឹងការបោះបង់ចោលនូវសាកសពដោយមិនបូជា ឬក៏បញ្ចុះអីនោះ ហើយទុកចោលនៅក្នុងរណ្តៅសាកសពឲ្យអណ្តែតតាមទឹកទន្លេមេគ្គ។ ដូច្នេះ ខ្ញុំសួរទៅកាន់សាស្ត្រាចារ្យរូបនេះ ថាបើតាមបទពិសោធន៍ និងតាមការអានឯកសាររបស់គាត់នោះ តើគាត់មានដឹងប្រភេទនៃការធ្វើបាប និងការទុកចោលសាកសពបែបហ្នឹងឬទេ? ហើយតើមនុស្សមានអារម្មណ៍យ៉ាងណាដែរនៅពេលនុ៎ង។ នេះជាការងាររបស់ប្រវត្តិវិទូហើយ ដែលគាត់ត្រូវឆ្លើយថា ពិតមែនហើយ ខ្ញុំបានអាន ហើយខ្ញុំដឹង ខ្ញុំឃើញថាប្រជាជនច្បាស់ជាមានការប៉ះទង្គិចអារម្មណ៍យ៉ាងខ្លាំងនៅពេលដែលឃើញបែបនេះ។ នេះជាការងាររបស់ប្រវត្តិវិទូ គាត់ត្រូវតែឆ្លើយ។ ដូច្នេះមេធាវីការពារក្តីប្រហែលគាត់មិនបានអានអំពីសក្ខីកម្មរបស់សាក្សីមួយចំនួននោះទេ បានជាគាត់ជំទាស់បែបនេះនោះ។

[១៥:២១:៥៧]

**ប្រធានអង្គជំនុំ៖**

បានហើយលោកមេធាវី មិនអនុញ្ញាតឲ្យលោកធ្វើការជំទាស់ទៅនឹងសេចក្តីតបចុងក្រោយនោះទេន៎ែ។

[១៥:២២:១៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២២:៤៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់ក្រុមមេធាវីអន្តរជាតិការពារក្តីលោក នួន ជា មានប្រសិទ្ធភាព។ សំណួរនេះមិនសមស្របទៅនឹងការសួរដេញដោលចំពោះអ្នកជំនាញរូបនេះទេ។ ហើយក៏ជាសំណួរបែប ទម្រង់ជាសំណួរនាំមុខដែរ។ ដូច្នេះ លោកសាស្ត្រាចារ្យមិនបាច់ឆ្លើយតបទៅនឹងសំណួរអម្បាញ់មិញចុងក្រោយ

អម្បាញ់មិញនេះទេ។ ហើយមេធាវីអាចបន្តនូវសំណួរថ្មីផ្សេងទៀត ប្រសិនបើនៅមាន។

**លោក អូលីវីយេ បាហ្វូញ៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្តទៅទៀត។

[១៥:២៤:២៤]

**សួរដោយលោក អូលីវីយេ បាហ្វូញ៖**

**ស៖** ខ្ញុំសូមដកស្រង់ជាថ្មីម្តងទៀត។ សូមផ្តល់ជូននូវលេខ ERN ជាភាសាខ្មែរ។ នេះគឺជាសក្ខីកម្មរបស់លោកនៅក្នុងសំណុំរឿង០០១។ ERN ជាភាសាខ្មែរ 00361539 ទៅដល់ 00361540, ERN ជាភាសាអង់គ្លេស 00361446 ទៅដល់ 00361447, ERN ជាភាសាបារាំង 00361599 ទៅដល់ 00361700។ ខ្ញុំសូមដកស្រង់៖ "នៅពេលដែលយើងយោងទៅលើមាត្រា៤នៃលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមានន័យថា គោលជំហររឹងមាំ ក្នុងការដឹកនាំ ការដឹកនាំការងាររបស់បក្ស។ នៅក្នុងនោះមានបញ្ជាក់ថា គឺត្រូវតែមានសញ្ញាណនៅក្នុងការគ្រប់គ្រងការងារនៅជិតមហាជន នៅក្នុងសហជីព នៅក្នុងសហករណ៍ ហើយនិងកងទ័ពបដិវត្តន៍កម្ពុជា។ ត្រូវមានគំនិតផ្តួចផ្តើមច្នៃប្រឌិតដោយស្វ័យភាព ត្រូវមានភាពស្វាហាប់ ភាពខ្លាំងក្លា ពុះកញ្ជ្រោលជាបន្តបន្ទាប់ ជាប់ជាប្រចាំ"។ តើលោកអាចឆ្លើយបញ្ជាក់បានទេ ថាមានការបណ្តេញចេញ ឬក៏ការបោសសម្អាតនូវសមាសភាពដែលមិនស្អាតស្អំដែរឬទេ?

[១៥:២៥:៣៩]

**លោក ដេវីដ ឆេនឌ័ល័រ៖**

**ឆ៖** ខ្ញុំមិនប្រើពាក្យថា បោសម្អាតជាស្វ័យប្រវត្តិនេះទេ គឺភស្តុតាងពីអ្នកជនរងគ្រោះ ក៏ដូចជាអ្នករៀបរាប់ដំណើររឿង គឺគេមានការទិតៀនទៅដល់មនុស្សដែលធ្វើការមិនបាន ឱ្យបានខ្លាំងក្លាគ្រប់គ្រាន់ គឺកាលណាគេនិយាយអំពី -- កាលណាជាសមាជិកបក្ស គឺសំដៅទៅលើថាត្រូវតែមានការពិន័យ។ គឺយើងមានចម្លើយសារភាពពីគុកទួលស្លែង ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទៅលើអ្នកទាំងអស់នេះ ថាមិនបានតស៊ូមោះមុតនៅក្នុងបដិវត្តន៍។ ដូច្នេះ បើសិនណាជាយើងសមាជិកបក្ស ហើយមិនបានបំពេញនូវលក្ខខណ្ឌទាំងអស់នេះ នោះគឺជាការរំលោភបំពានទៅដល់មាគ៌ា ហើយនិងលក្ខន្តិកៈរបស់បក្សហើយ។ នៅតាមជនបទ ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន គឺមិនបានស៊ីសង្វាក់គ្នាទេ។ ប៉ុន្តែគេផ្តល់ឱកាសទៅដល់ប្រជាជនទាំងអស់នោះកសាងគាត់ថា មិនត្រូវធ្វើបែបនេះម្តងទៀតទេ។ សម្រាប់បញ្ហា

នេះ ខ្ញុំមិនអាចប្រើពាក្យ “បោសសម្អាត” នោះបានទេ។

[១៥:២៧:០០]

**ស៖** តើលោកអាចប្រាប់ខ្ញុំបានទេថា ប្រព័ន្ធដែលបានបង្កើតបែបនេះ ដែលសំដៅបង្កើតឲ្យមានភាពពុះកញ្ជ្រោលខាងផ្នែកបដិវត្តន៍ ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញ ដែលបង្ហាញអំពីមាត្រា៤ហ្នឹង តើមានការធាក់ថយក្រោយ មានការបន្ទុចបង្អាក់ទេ? ខ្ញុំសូមពន្យល់ គឺថា មានការជំរុញឲ្យមានការពុះកញ្ជ្រោលបែបនេះ គឺកម្មាភិបាល គឺគាត់ធ្វើការយ៉ាងសស្រាក់សស្រាំ ហើយគាត់ទទួលបញ្ជាពីគោលការណ៍ណែនាំពីថ្នាក់លើ។ ដូច្នេះ ក្នុងករណីបែបនេះ តើមេដឹកនាំគាត់គិតថាវាទៅហួសឆ្ងាយពេក ហើយគាត់មានដើរត្រឡប់ក្រោយ គាត់មានថយក្រោយមកវិញទេ ក្នុងករណីដែលគាត់គិតថាដើរលឿនពេកបែបនេះនោះ?

**ឆ៖** នេះជាសំណួរល្អមួយ។ មិនមានភស្តុតាងដែលបង្ហាញថា គាត់បង្អាក់នោះទេ គឺថាយើងបានអានពីម្សិលមិញហើយ ឯកសារនោះ គេថាពាក្យថា “ឆ្វេងនិយម” នៅខាង -- នៅក្នុងវង់ក្រចកហើយ ពាក្យខាងស្តាំ ខាងឆ្វេង គឺថា ថាតើ ឆ្វេងនោះអាក្រក់ ឬក៏ស្តាំ គឺថា កុំឲ្យស្តាំពេកៗ គឺថាបើស្តាំនិយម បើថាឆ្វេងនិយមនោះគឺថា ប៉ុន្តែគេមិនចាត់ទុកថាជាបទល្មើសទេ ប៉ុន្តែនៅពេលដែលគេបំផុសបំផុល គឺថាឲ្យសកម្ម ឬក៏ថាឲ្យ -- គឺវាមានករណីជាច្រើនដូចជាចម្លើយដែលខ្ញុំឆ្លើយ។ គេមិនឲ្យឱកាសទីពីរដល់មនុស្សទេ នៅពេលដែលគេយល់ថា ខុសហើយ គឺថាត្រូវតែកម្ទេចនោះ។ អានោះគឺវាជាគំនិតរបស់កម្មាភិបាលដែលស្រឡាញ់ការងារ ឬក៏ពេញចិត្តនឹងការងាររបស់គេនោះឯង ដែលគេធ្វើតាមមាគ៌ា។

[១៥:២៨:១៣]

នៅពេលដែលៗ គេឋិតនៅក្នុងឋានៈមួយ គឺគេត្រូវតែយល់ថា ក្រុមណាជាខ្លាំង រីឯសេរីភាពចំពោះការងាកចេញពីមាគ៌ានោះ គឺគេត្រូវប្រុងប្រយ័ត្នដោយខ្លួនគេ ថាតើត្រូវធ្វើដូចម្តេច ហើយកម្មាភិបាលដែលនៅក្នុងបក្សជាយូរហើយមានបទពិសោធន៍។ អ៊ីចឹងហើយ គឺគេត្រូវប្រុងប្រយ័ត្ន អ៊ីចឹងហើយដូចជាកម្មាភិបាលបាលមកពីនីរតី គេដឹងថាតើគេអាចបត់បែនប៉ុនណាដើម្បីផលិតនូវ ផលិតផល ឬក៏អ្វីដែលគេចង់បាន អ្វីដែលគេគត់សម្គាល់ ថាតើកម្មាភិបាលក្មេងនោះ ទៅខាងឆ្វេង ឬក៏ស្តាំពេកនោះ។ អ៊ីចឹងហើយគឺថា ឧទាហរណ៍មួយ ខ្ញុំមិនបានឃើញថាគេដាក់ទោស។ អ៊ីចឹងគឺថា បើសិនជាកម្មាភិបាលណាវាសកម្មពេកនោះ គឺពេលខ្លះ គឺថាអាចនឹងឈានទៅដល់កំណត់នូវកម្មាភិបាលគ្នាឯង

ថាមិនសកម្មជាខ្លាំង ដូចជានៅក្នុងប្រតិចារឹក គឺថាអាចនឹងឃើញថាជាឆន្ទៈ ឬក៏ការដែលប្រុងប្រយ័ត្ន សកម្មការងារហ្នឹងអាចឈានដល់បញ្ហាហ្នឹងក៏មានដែរ។

**ស៖** សូមអរគុណ។ យើងបានឃើញរួចមកហើយនូវធាតុផ្សំមួយចំនួន ពាក់ព័ន្ធទៅនឹងបរិបទនៃការស្តាប់បង្គាប់ ឬក៏ការស្តាប់បញ្ជា។ តើលោកអាចប្រាប់បានទេ ថាមានទំនាក់ទំនងដែរឬទេ រវាងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានវិនិច្ឆ័យទោសនៅថ្ងៃនេះនោះ?

[១៥:៣១:១២]

**ប្រធានអង្គជំនុំ៖**

សាស្ត្រាចារ្យកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរ សូមស្តាប់ -- ចាំរង់ចាំការស្តាប់សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ តាមពិតខ្ញុំក្រែងថា ដែលខ្ញុំនឹងសម្តែងមតិរបស់ខ្ញុំ គឺមិនគប្បីសួរលោកសាស្ត្រចារ្យឱ្យៗយោបល់ពាក្យថា "គោរពបញ្ជា" នោះទេ។ នេះជាពាក្យដែលបង្ហាញពីផ្លូវចិត្តចិត្តសាស្ត្រ គឺថា បើសិនជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរបែបនេះ គឺទាល់តែមានអ្នកជំនាញចិត្តសាស្ត្រ ទើបបានបញ្ជាក់បាន។ ហើយសាស្ត្រាចារ្យអាចឆ្លើយបានតែរឿងករណីប្រវត្តិសាស្ត្រ ហើយបើថាអាចសួរតែគំនិតផ្តោតយោបល់តែត្រឹមថា ឱ្យគាត់ផ្តល់យោបល់ពីការគោរពនេះ គឺហួសពីអ្វីដែលជំនាញរបស់គាត់ហើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក ខៀវ សំផន!

[១៥:៣២:២២]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមរយៈការបកប្រែអម្បាញ់មិញនេះ ខ្ញុំបានស្តាប់ថា លោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យសាក្សីជំនាញបង្ហាញអំពីព្រឹត្តិការណ៍នោះ ថាតើវាជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលកំពុងលើកយកមកជំនុំជម្រះនាពេលនេះដែរឬទេ? សំណួរនេះខ្ញុំយល់ថា មិនគួរឱ្យសាក្សីឆ្លើយបានទេ ពីព្រោះអ្នកសាក្សីមិនមែនជាអ្នកជំនាញវិភាគទៅលើធាតុផ្សំបទល្មើសដូចជាអ្នកច្បាប់ ហើយដែលជាសមត្ថកិច្ចនេះ ជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះដែលត្រូវធ្វើការវិនិច្ឆ័យ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីមានអីតបទៅនឹងសេចក្តីជំទាស់របស់មេធាវីទាំងក្រុមនេះដែរឬទេ?

[១៥:៣៣:១៦]

**លោក អូលីវីយេ បាហូញ៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាការច្បាស់ណាស់ដែលខ្ញុំមិនសុំមតិយោបល់ច្បាប់ទៅលោកអ្នកជំនាញនោះ។ ខ្ញុំកត់សម្គាល់ឃើញថា ទាក់ទងទៅនឹងសហភាតាក្រុម ខៀវ សំផន នោះ គាត់អត់មានបានចេញការជំទាស់ទៅលើសំណួរទាំងអស់ដែលខ្ញុំសួរនោះទេ ដែលទាក់ទងនឹងការបង្ហាញធាតុផ្សំនៃបរិបទនៃការស្តាប់បង្គាប់បញ្ជានេះ។

បន្ទាប់មកទៀត ខ្ញុំសូមឆ្លើយតបទៅនឹងក្រុម នួន ជា ផងដែរ វាមិនមែនជាការសុំយោបល់ផ្លូវចិត្តឬក៏ផ្លូវច្បាប់នោះទេ។ ក៏ប៉ុន្តែគ្រាន់តែសុំឱ្យលោកសាស្ត្រាចារ្យប្រាប់យើង ថាតើធាតុផ្សំដែលបានលើកឡើងអម្បាញ់មិញនេះមានដែរឬទេ មាននៅក្នុងពេលជាមួយគ្នា ផ្សំគ្នា។ នេះវាពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រគាត់អាចប្រាប់យើងថាតើថានៅសម័យនោះ សម័យនោះ នោះគឺថា ចំពោះយើងពីឆ្នាំ៧៥ ដល់៧៩។ គាត់គ្រាន់តែប្រាប់ថា តើធាតុផ្សំទាំងអស់នេះមានបូកបញ្ចូលគ្នានៅចន្លោះរយៈពេលហ្នឹងដែរឬទេ? តែប៉ុនន៎ុងទេ គឺបានន័យថា ខ្ញុំបាន -- ឧទាហរណ៍ដូចអំមិញខ្ញុំសួរលើកម្រិតវប្បធម៌ ហើយនិងការចំណេះដឹងរបស់សាស្ត្រាចារ្យ ហើយនិងការកម្ទេចបញ្ញាជន។ ហើយរាល់ដងហ្នឹងគាត់ឆ្លើយតបមកខ្ញុំ ហើយដែលមិនផ្តល់ជាហេតុផលត្រូវនោះទេ។ អ៊ីចឹងអ្វីដែលខ្ញុំចង់ដឹងនោះ គ្រាន់តែចង់ដឹងថាតើធាតុផ្សំទាំងអស់នេះមានដែរឬទេនៅសម័យនោះ? ដែល -- មាន ហើយមាននោះនៅក្នុងក្រោមការគ្រប់គ្រងរដ្ឋអំណាចមួយដែលសុំឱ្យមាន ឱ្យអ្នកដែលនៅក្រោមអំណាចរបស់ខ្លួនហ្នឹង មានភាពសស្រាក់សស្រាំ ហើយនិងខំប្រឹងដោយ--

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៦:២៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តីមានប្រសិទ្ធភាព។ លោកសាស្ត្រាចារ្យមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់ -- ដែលសួរឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ។

មេធាវីមានសំណួរអ្វីផ្សេងទៀតបន្តទៅសំណួរថ្មី។

**លោក អូលីវីយេ បាហ្សូញ៖**

បាទ លោកប្រធាន សូមអរគុណ។

**សួរដោយលោក អូលីវីយេ បាហ្សូញ៖**

**ស៖** លោកសាស្ត្រាចារ្យ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើការកម្ទេចអ្នកដឹកនាំសាសនានោះស្មើនឹងអ្នក -- វាដូចគ្នានឹងការកម្ទេចបញ្ញវន្ត ឬក៏ស្មើនឹងថាការគ្រប់គ្រង ការពិចារណារបស់ពួកគាត់ទាំងអស់គ្នាហ្នឹង?

[១៥:៣៧:២៧]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** តាមពិតនូវការដកចេញពីអំណាចនូវអំណាចពីមុន គឺមេដឹកនាំដូចជា កងទ័ព គឺព្រះសម្តេចសង្ឃ ហើយបញ្ញវន្ត ហើយនិងគ្រូបង្រៀន វាមិនមានលក្ខណៈជាប្រព័ន្ធទូទៅប៉ុន្មានទេ។ ប៉ុន្តែខ្ញុំដឹងចំពោះគ្រូបង្រៀននេះ គឺនៅមានគ្រូបង្រៀនខ្លះគឺថាអាចបង្ហាញភស្តុតាងសំខាន់ៗនោះដែរ។ ជាពិសេសគឺអ្នកដែលមានការអប់រំ ប៉ុន្តែព្រះសង្ឃពុទ្ធសាសនាមិនត្រូវបានអនុញ្ញាតឲ្យគោរពប្រតិបត្តិសាសនារបស់ខ្លួននោះទេ។

ខ្ញុំមិនប្រាកដថា វាខុសគ្នាពីការអនុវត្តការងារដ៏ពេញចិត្តពេញថ្លើមរបស់កម្មាភិបាលខ្មែរក្រហមនោះទេ។ អ្នកដែលការសិក្សាពីខ្មែរក្រហមគឺមានទិដ្ឋភាពមួយគឺៗ ទិដ្ឋភាពមួយគឺថា នយោបាយមួយគឺត្រូវបំបាត់សាសនា បាទហ្នឹងហើយ។

[១៥:៣៨:៣៩]

ដូច្នេះគឺយើងឃើញថា អ្នកទាំងអស់នេះគឺជួបវាសនាបែបនេះ។ ដូចដែលយើងបាននិយាយខាងដើម គឺធ្វើយ៉ាងម៉េចកុំឲ្យមានមតិតវ៉ា ឬក៏ដែលថាមតិជំទាស់ទាំងអស់ ឬក៏សំឡេងរបស់អតីតអ្នកកាន់អំណាចពីមុន គឺថាអាចធ្វើឲ្យរំខានដល់ការក្តោបក្តាប់អំណាចរបស់គេ។ បើគេចង់ស្តាប់គឺអាចឲ្យកម្មា-ភិបាលប្តូរចិត្ត ប្តូរមាគ៌ារបស់គេ។ អ៊ីចឹងហើយគេត្រូវតែធ្វើម៉េចកុំឲ្យបញ្ញវន្ត គឺអ្នកចេះដឹងហ្នឹងកុំឲ្យនិយាយស្តី ទោះបីជាការសម្តែងមតិហ្នឹងជួយបដិវត្តន៍ ឬក៏ប្រឆាំងក៏ដោយ គឺថាបញ្ជូនទៅជនបទដើម្បីឲ្យធ្វើការងារពលកម្ម។ អ៊ីចឹងហើយគឺជាសេចក្តីសម្រេចរបស់គេ គឺថាអាចនឹងមានបែបនេះ ដែលគេថាគេជោគជ័យដោយសារមាគ៌ារបស់គេ។ អ៊ីចឹងហើយគឺថា ធ្វើយ៉ាងណាឲ្យម្នាក់ៗធ្វើការងារ ធ្វើ

ដូចៗគ្នា។ គឺថាមិនឲ្យអ្នកណាម្នាក់មានមតិអ្វី ឬក៏សួរអ្វីអំពីមាគ៌ាបដិវត្តន៍ទេ ទោះបីជាគ្រូបង្រៀន សាស្ត្រាចារ្យ ព្រះសង្ឃ អ្វីក៏ដោយ។ គឺថាអាជ្ញាធរ អតីតអ្នកដែលក្នុងរបបមុនក៏ដូចគ្នាដែរ គេមិនឲ្យសិទ្ធិសេរីភាពនិយាយ ឬក៏សម្ដែងអ្វីទេ។ អ៊ីចឹងហើយគេគិតថា អាចនឹងធ្វើឲ្យមានមតិជំទាស់ គឺថាអាចនឹងមានការបះបោរ ក្នុងអតីតគ្រូបង្រៀន អតីតនិស្សិត ឬក៏ព្រះសង្ឃ ឬក៏អតីតទាហាន ដែលអាចគោរពនឹងមេរបស់គេ គឺថាអាចនឹងជំទាស់ទៅនឹងអំណាចរដ្ឋរបស់ខ្មែរក្រហមនោះ។ ហ្នឹងហើយ បាទសូមទោស។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដីលោក ខៀវ សំផន!

[១៥:៤០:៣៩]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ រឿងតូចតាចមួយទេ ខ្ញុំបាទកត់សម្គាល់ឃើញលោកសាក្សីជំនាញពេលដែលគាត់មានប្រសាសន៍ តែងតែនិយាយបែរទៅរកមេធាវី ព្រោះគាត់នៅកៀកគ្នា ហើយមិនបានមើលទៅក្រុមប្រឹក្សាជំនុំជម្រះ ហើយបញ្ហានេះ ខ្ញុំយល់ឃើញថា ដូចជាមិនសមគួរ។ បាទសូមអធ្យាស្រ័យ សូមជួយណែនាំ។

**ប្រធានអង្គជំនុំ៖**

បាទ មិនមានបញ្ហាអីទេ តូចតាចទេ នេះវាជារបៀប ឬក៏ទម្លាប់មួយនៃការពិភាក្សា បើពិភាក្សាមិនបានមើលមុខគ្នាហ្នឹង គឺវាអាចនិយាយទៅវាមិនៗចេញដែរនែ៎។ យើងបានជម្រាបជូនគាត់តាំងពីដើមទីគ្រប់បុគ្គលទាំងអស់ ប៉ុន្តែជាក់ស្ដែងគឺ ជាការលំបាកមួយក្នុងការកែប្រែទម្លាប់របស់មនុស្ស ដែលធ្លាប់ការជជែកពិភាក្សាគ្នា ទាំងគេទាំងយើងគឺទាមទារការមើលមុខគ្នា។ អ៊ីចឹងហើយបានជាមិនជាខុសឆ្គងអីទេ។ សូមអញ្ជើញទៀត!

**លោក អូលីវីយ៉េ បាហូញ៖**

បាទ សូមអរគុណលោកប្រធាន។ លើសពីនោះទៅទៀតនោះគឺថា គោលជំហររបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះមានការលំបាកលំបិនណាស់ ពីព្រោះថាយើងនៅក្រោយខ្នងលោក ដេវីដ ឆេនដ៍ល័រ។

**សួរដោយលោក អូលីវីយ៉េ បាហូញ៖**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ ឌុច បានបញ្ជាក់ថា ខ្ញុំសូមផ្ដល់លិខិតនេះ កំណត់សម្គាល់ជាភាសា

ខ្មែរគឺថា 00787936 ដល់ 00787977, 0079976 (ស៊ីក) ទៅដល់ 31 ចុងកន្ទុយ, 00792675, 00 ដល់ 41 លេខចុងក្រោយ។ នេះគឺជាលិខិតមួយដែលផ្ញើជូន ផ្ញើ -- មានចំណងជើងថា “មេរៀនដែលទាញចេញពីបុព្វបុរសរបស់យើង” មានការពន្យល់ថា ពាក្យថា អ្នកសាសនាប្រតិកិរិយា ដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សនោះ ទាក់ទងទៅនឹងសាសនាកាតុលិក។ តើលោកអាចពន្យល់បានទេថា ហេតុអ្វី -- ខ្ញុំចោទសំណួរមួយទៀតទន្ទឹមពេលហ្នឹងដែរ ថាហេតុអ្វីបានថា នៅចំពោះខ្មែរក្រហម ថាតើសាសនាគ្រិស្ត ហើយសាសនាឥស្លាមម៉ូស្លីមនោះខុសគ្នាយ៉ាងម៉េច?

[១៥:៤៣:៣៣]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំមិនគិតថា ខ្មែរក្រហមចាត់ទុក--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដី លោក អៀង សារី!

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន អំមិញសហភាតាមេធាវីគាត់បានប្រាប់តែលេខ ERN ប៉ុន្តែលេខឯកសារ ឈ្មោះឯកសារ អត់ដឹងថា ឯកសារណាមួយដែលគាត់លើកទេ។ ហើយមួយទៀត គាត់បានថ្លែងនិយាយពីរឿងទាក់ទងរឿងសាសនា។ ខ្ញុំដឹងថា លោកជំនាញគាត់មានជំនាញឯកទេសខាងកិច្ចការសាសនា ដែរឬអត់ដែលត្រូវមកឆ្លើយលើចំណុចទាក់ទងនេះ។ សូមអរគុណ។

**លោក អូលីវីយ៉េ បាហ្វូញ៖**

ឯកសារ E180។ បាទ ខ្ញុំសូមឆ្លើយស្របគ្នានេះ ទៅនឹងការកត់សម្គាល់នោះតែម្តង។

[១៥:៤៤:៣៥]

**សួរដោយលោក អូលីវីយ៉េ បាហ្វូញ៖**

**ស៖** បាទជាថ្មីម្តងទៀត មិនមែនជាការវាយតម្លៃផ្ទាល់ខ្លួន ទៅលើសាសនាណាមួយនោះទេ ក៏ប៉ុន្តែបន្ទាប់ពីការអានឯកសារទាំងអស់ ដែលលោក ដេវីដ ឆេនដ៍ល័រ គាត់បានអាននោះ ដែលខ្ញុំយល់ឃើញថា ជាចំនួនច្រើនណាស់ប្រហែលជាគាត់មានសមត្ថភាពក្នុងការផ្តល់ទស្សនទានពិសេសណាមួយរបស់ពួកខ្មែរក្រហមទាក់ទងទៅនឹងសាសនាទាំងពីរនេះ។ តើ ឬក៏ពួកខ្មែរក្រហមនេះចាត់ទុកថាសាសនាមួយនេះ ខុសពីមួយនោះ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

លោកសាស្ត្រាចារ្យមិនបាច់ឆ្លើយតបទេ ចម្លើយតបទៅនឹងសំណួរនេះ ទំនងមិនមានផលប្រយោជន៍អ្វីក្នុងការរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះទេ។

**លោក អូលីវីយេ បាហូញ៖**

មិនអ្វីទេលោកប្រធាន។

**សួរដោយលោក អូលីវីយេ បាហូញ៖**

**ស៖** ហេតុអ្វីបានជាហាមឃាត់មិនឲ្យគោរពសាសនាអ៊ីស្លាម បើសិនជាសាសនានោះគេមិនចាត់ទុកថាជាសាសនាប្រតិកិរិយានោះ?

[១៥:៤៦:១០]

**លោក ជេរីង ផេនដ៍ល័រ៖**

**ឆ៖** សំណួរទីមួយរបស់លោកតម្រូវឲ្យខ្ញុំផ្តល់គំនិតទាក់ទងការគិត គំនិតខាងសាសនារបស់ខ្មែរក្រហម ខ្ញុំមិនអាចឆ្លើយបានទេ។ គេបដិសេធគ្រិស្តសៀន ហើយនិងអ៊ីស្លាម ហើយគេប្រើទៅតាមលក្ខខណ្ឌនៅកម្ពុជា។ គ្រិស្តសៀន គឺទាក់ទងទៅនឹងគំនិតខ្មែរក្រហម គឺថាជាវៀតណាម។ លោកអាចឃើញនៅជាមួយឯកសារពីរបីថ្ងៃនេះគឺថាយើងតែងតែឃើញ គឺថា មិនមែនជាសត្រូវធំរបស់កម្ពុជាទេ។ ចំពោះចាម គឺថានៅក្នុងសង្គមខ្មែរមុនបដិវត្តន៍ជាសមាជិករបស់ សមាជិកកម្ពុជា ប៉ុន្តែពួកវៀតណាមមិនមែនជាសមាជិកក្នុងសង្គមខ្មែរនោះទេ។ ហើយអ្វីដែលខ្មែរក្រហមបានខឹងចំពោះចាមនោះ គឺមានការបះបោរនៅពេលដែលគេប្រកាន់យកសាសនារបស់គេ ហើយអ្វីដែលគេៗគិតពីអ៊ីស្លាមហ្នឹង ថាគេមើលឃើញថា ពួកគេមិនព្រមបះបោរ បោះបង់សាសនារបស់ពួកគេ ហើយទទួលយកសាសនា ឬក៏គំនិតរបស់បដិវត្តន៍ខ្មែរក្រហមគេនោះ។

[១៥:៤៧:៣៨]

**ស៖** បាទ សូមអរគុណលោកសាស្ត្រាចារ្យ។ សាសនា -- តើសាសនានោះជាមធ្យោបាយក្នុងការកំណត់អត្តសញ្ញាណចាមដែរឬទេ?

**ឆ៖** បាទ គឺថានេះគឺជាចំណុចមួយនៅក្នុង គឺថាភាសា សម្លៀកបំពាក់ ហើយគេមានភាសារបស់គេ ប៉ុន្តែគេឲ្យប្រើភាសាខ្មែរ គេប្រើឥណ្ឌូណេស៊ី ម៉ាឡេ ហើយគឺគេដឹងនូវក្នុងខេត្តកំពង់ចាម និងកំពត គឺថាការងាររបស់គេនោះគឺៗធ្វើឲ្យមើលឃើញខុសពីខ្មែរធម្មតា គឺអ្វីដែលគេប្រព្រឹត្តនោះ គឺថាអាចធ្វើ

ឲ្យខ្មែរក្រហមមានការខឹងសម្បាដូច ដូចពួកគាត់នោះប្រកាន់ទម្លាប់តានតឹង តឹងតែង។ ខ្ញុំមិនអាចនិយាយថា មិន -- ក្បាលរឹងទេ ប៉ុន្តែគេមិនសហការជាមួយខ្មែរក្រហមឲ្យបានដូចអ្នកផ្សេង ដូចជារដ្ឋធម្មនុញ្ញខ្មែរក្រហមនោះ គឺថាៗគឺចាត់ទុកថាសាសនាប្រតិកិរិយាទាំងអស់ហ្នឹង គឺត្រូវតែលុបបំបាត់អ៊ីចឹង។ អ៊ីចឹងហើយគឺគេប្រកាន់គោលការណ៍ហ្នឹង គេអាចធ្វើជា -- អ៊ីចឹងហើយគេអាចជាគំនិតមួយគឺថាមិនអាចអនុញ្ញាតឲ្យមានសាសនាទាំងអស់ គឺៗគេចាត់ទុកថាជាប្រតិកិរិយា។ អ៊ីចឹង រដ្ឋធម្មនុញ្ញហ្នឹងគឺថា ណែនាំកំណត់ជាឃ្លាមួយ គឺថាដើម្បីឲ្យបរទេសគេយល់ថាមិនសូវអាក្រក់ គឺថាគឺ -- ហើយគេគ្រាន់តែថែងថាមានសាសនាដើម្បីកុំឲ្យឃើញថា គេមិនអនុញ្ញាតឲ្យមានសាសនា។ ហើយចាម ជាក្រុមសាសនាមួយ ហើយឯកសារនោះបង្ហាញថា មូលហេតុនៃការវាយប្រហារទៅលើចាមនោះ គឺមិនចាប់ផ្ដើមភ្លាមៗបន្ទាប់ពី៧៥ ១៩៧៥ ទេ។ ហើយគេមិនចាត់ទុកថា ចាមជាខ្មាំង ដូចវៀតណាមនោះទេ។ ដូច្នេះហើយមានការបង្ក្រាបជនជាតិចាម គឺថាខុសពីប្រជាជនផ្សេងទៀតនៅក្នុងតំបន់មួយចំនួនគឺគេបង្ក្រាប នៅពេលដែលតែចាមហ្នឹងប្រឆាំងបះបោរនឹងខ្មែរក្រហមនៅឆ្នាំ១៩៧៦ តែប៉ុណ្ណោះទេ។ ដែលគេចាត់ទុកថាជាតំបន់ដែលគ្រោះថ្នាក់សម្រាប់បដិវត្តន៍។ ពេលនោះគឺថាគេធ្វើទុក្ខបុកម្នេញចំពោះក្រុមចាមដែលបានបះបោរនោះ គឺថាមិនមែនដោយសារតែជំនឿសាសនាអ៊ីស្លាមទេ ដោយសារថាក្រុមចាមនៅតំបន់មួយនោះ គាត់បានបះបោរ។

[១៥:៥០:២១]

**ស៖** បាទ សូមអរគុណលោកសាស្ត្រាចារ្យ ខ្ញុំសូមអានសម្រង់មួយ ឯកសារ E3/178, ERN ជាភាសាខ្មែរគឺ 00275587 រហូតដល់ 98, ជាអង់គ្លេស 00342708 រហូតដល់ 23, ជាភាសាបារាំង 00623304 រហូតដល់ 21។ នេះគឺជាកំណត់ហេតុនៃកិច្ចប្រជុំប្រចាំឆ្នាំ ប្រចាំថ្ងៃ -- និយាយអំពីអ្នក ១៧មេសា ដែលជាចាម ដែលបញ្ជូនទៅនៅសហករណ៍មួយទាក់ទងទៅនឹងជំនឿសាសនារបស់ពួកគាត់ ហើយនិងការចាំបាច់ក្នុងការហូបចំណីអាហារទៅតាមការគោរពសាសនារបស់ខ្លួន។ អ្នកណានោះបាននិយាយថា -- និយាយពីមាត្រា១០ នៃរដ្ឋធម្មនុញ្ញដើម្បីជាអំណះអំណាងនៃសុន្ទរកថារបស់ខ្លួន។ ចំពោះមុខនឹងស្ថានភាពនេះ គេបានចាត់វិធានការ ជាពិសេសគឺថាវិធានការស្វែងរកខ្សែហើយនិងមេចលនាហ្នឹង ដើម្បីបោសសម្អាត។

បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីការបរិហារ -- នូវការបរិភោគសាច់ជ្រូក។ តើការបង្ខំហូបឲ្យសាច់ជ្រូកនោះ ជាមធ្យោបាយនៃការកំណត់អត្តសញ្ញាណចាម ដើម្បីបោសសម្អាត ឬក៏កម្ទេច

រាល់បុគ្គលទាំងឡាយណាដែលមិនសុខចិត្ត មិនព្រមហូបសាច់ជ្រូកតើអ៊ីចឹងមែនទេ?

[១៥:៥២:៣៧]

**ឆ៖** ពាក្យថា“បោសសម្អាត”នោះ ជាឃ្លាសម្រាប់គេប្រើការកម្ទេចនោះ គេបានដឹងថាអ្នកណាជាចាមរួចហើយ គឺថាខ្ញុំបានអានច្រើនណាស់អំពីការងារនេះក្នុងការសរសេរសៀវភៅ ការបង្ខំឲ្យហូបសាច់ជ្រូកហ្នឹង គេអាចហៅថាជាការប្រកាន់ ហើយការបង្ខំ ហើយគឺថាបើមិនអាចហូបបាន គេនឹងរងការមើលងាយ។ គេមិនប្រើ បង្ខំឲ្យហូប នេះជាការធ្វើតេស្តដើម្បីបង្ហាញថាចាម មិនចាមទេ ដូចជានៅរបបហាយនភាពផ្សេង។ រីឯចាម គឺថាពួកគាត់មិនលាក់កំបាំងខ្លួនទេ គេដឹងថាពួកគាត់ជាសហគមន៍ចាម ហើយនៅកន្លែងណាក៏គេដឹងដែរ។ អ៊ីចឹងគឺថាការឲ្យហូបសាច់ជ្រូកនេះ គឺជាការម៉ាក់ងាយសាសនាសហគមន៍របស់គាត់ ព្រោះគាត់តមសាច់ជ្រូក។ នេះហើយ គឺជាគំនិតមួយ គឺជាការអនុវត្តម៉ាក់ងាយទៅលើសាសនាទេ។

[១៥:៥៣:៣៦]

**ស៖** បាទ ខ្ញុំសូមអរគុណលោកសាស្ត្រាចារ្យ។ ខ្ញុំសូមផ្តល់រឿងមួយឲ្យលោកដឹង លោកទើបបាននិយាយថា ចាមមិនបានបះបោរមុនឆ្នាំ៧៥ ទេ។ គឺឯកសារ 21.3, ERN ជាភាសាខ្មែរគឺ 00008494, ជាភាសាអង់គ្លេស 00185064 រហូតដល់ 65, ជាភាសាបារាំង 00386260។ នេះ គឺជាទូរលេខ លេខ១៥ ផ្ញើជូនដល់សមមិត្ត ប៉ុល ជាទីគោរពស្នេហា។ ជាគោលការណ៍ភូមិភាគ បញ្ជូនប្រជាជន៥0ភាគរយទៅភូមិភាគខាងជើង ហើយយើង--

**អ្នកបកប្រែ៖**

លោកៗប្រធាន គាត់អានលឿនពេក អ្នកបកប្រែបកអត់ទាន់។ សូមឲ្យគាត់បន្ថយល្បឿនលោកប្រធាន។

**ស៖** --ការជម្លៀសប្រជាជននេះ គឺជាការបំបែកដែលមនុស្សដែលយើងបានពិភាក្សាជាមួយបងនេះ ចុះនៅថ្ងៃទី៣០ ខែ១១ ឆ្នាំ១៩៧៥។ បាទ សំណួរខ្ញុំគឺ -- បើសិនជាមិនដែលមានការបះបោរពួកចាមនោះ តើហេតុអ្វីបានគេចាត់ ធ្វើការជម្លៀសគាត់ ហើយនិងការបំបែកពួកចាមទាំងអស់នេះ?

**ឆ៖** សូមអរគុណ។ ខ្ញុំទុកសិទ្ធិឲ្យលោកកែតម្រូវ ហើយទូរលេខនេះជាឯកសារនេះ គឺថាឯកសារត្រឹមត្រូវពិតប្រាកដគឺថា បង្ហាញថាការដាក់សម្ពាធទៅលើជនជាតិចាម។ ខ្ញុំគិតថា ភូមិភាគបូព៌ានៅក្រចេះ គឺដល់ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឯកសារខ្លួនឯងនោះ គឺជាភស្តុតាងដែលថាអាចនឹងមានការ

បះបោរ គឺថាមិនមែនមានការបះបោរ -- នៅក្នុង៧៥ គឺថា មូលហេតុនៃការបំបែកជនជាតិចាមនោះ គឺគេមិនបានបញ្ជាក់ច្បាស់ទេ ប៉ុន្តែគឺដែលបំបែកពួកគេនេះ គឺជាសហគមន៍មួយស្វ័យភាពដែលគេគោរពសាសនាតឹងរ៉ឹង ហើយគេមានប្រវត្តិសាស្ត្រនៅក្នុងតំបន់ គឺជាប្រភពនៃកម្លាំងមួយដែលខ្មែរក្រហមគេចង់បំបែកកុំឲ្យរស់នៅជាមួយក្រុមគ្រួសារ នៅជាមួយសហគមន៍របស់គេ។

[១៥:៥៦:៤៧]

គេតំណាងការគំរាមកំហែងទៅនឹងអង្គការសមូហភាពរបស់ខ្មែរក្រហម គេយល់អ៊ីចឹង។ ដូច្នេះហើយគេចង់រក្សាអំណាចបដិវត្តន៍ហ្នឹងឲ្យរឹងមាំ អ៊ីចឹងហើយមានតែបំបែកកម្លាំងណាដែលអាចគំរាមកំហែងពួកគេនោះ។ អ្វីដែលខ្ញុំចងចាំនោះ គឺចាប់ផ្តើមនៅពេលដែលគេ -- ក្រុមតូចទេ ដើម្បីបះបោរ ប៉ុន្តែក្រុមតូចហ្នឹងគឺថាអាចជាហេតុដែលធ្វើឲ្យគេគិតថា ជាការគំរាមកំហែងទើបបានជាគេបំបែកសហគមន៍ចាមនោះ ជម្លៀសចេញពីតំបន់។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ គឺថា ខ្ញុំគិតថាឥរិយាបថរបស់លោក ហើយនិងរបៀបឆ្លើយរបស់លោកហ្នឹង គឺថាធ្វើឲ្យខាងការពារក្តីនោះ គេពេញចិត្តហើយ ព្រោះថានៅពេលលោកមិនដឹង លោកឆ្លើយថា លោកមិនដឹង។ ខ្ញុំសូមត្រឡប់និយាយៗអំពីអ្វីដែលលោកលើកឡើងអម្បាញ់មិញទាក់ទងនឹងការបែងចែកមនុស្ស ហើយទាក់ទងនឹងការហូបសាច់ជ្រូក ហើយនិងការប្រត្តិបត្តិសាសនាជាដើម។ ខ្ញុំសូមអានសម្រង់មួយគឺឯកសារ D125/75.1។

[១៥:៥៨:១៣]

បាទ ឯកសារនេះ យើងបានបញ្ជូនទៅអង្គជំនុំជម្រះហើយ គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលពន្យល់ថា នៅឆ្នាំ១៩៧៨ មានមនុស្សមួយក្រុមមកក្នុងភូមិគាត់នៅតំបន់ ភូមិភាគបូព៌ា។

"គាត់និយាយថា ខ្ញុំនៅសល់រស់តែម្នាក់ឯងទេ ព្រោះថាខ្ញុំតែងខ្លួន ក្លែងខ្លួនទៅជាមនុស្សពូជប្រភេទផ្សេង ហើយខ្មែរក្រហមបានចាត់ឲ្យបុរសៗចាមចាប់ពីវ័យជំទង់ទៅ ត្រូវសង់ផ្ទះមួយនៅក្នុងមួយនៅឆ្ងាយ នៅ -- ចាមប្រហែលជាជាង ២០នាក់ បានចេញទៅតាមការចាត់តាំងហ្នឹង បន្ទាប់មកពួកគាត់បានត្រឡប់មកផ្ទះយើងវិញ ហើយគាត់បាននិយាយថា ផ្ទះថ្មីនោះត្រូវបានសង់ហើយ ហើយចាមត្រូវមកនៅក្នុងភូមិថ្មីនុ៎ង។ នៅក្រោមបញ្ជារបស់ខ្មែរក្រហម ម្តាយខ្ញុំ ជីដូនខ្ញុំ ប្អូនខ្ញុំៗ ហើយនិងខ្ញុំៗផងដែរ យើងបានធ្វើដំណើរទៅវត្តមួយ ខ្ញុំទៅដល់នោះប្រហែលជាម៉ោងប្រាំបីព្រឹក។ ខ្ញុំឃើញគ្រួសារចាមប្រហែលជា៣០គ្រួសារ ប្រមូលផ្តុំគ្នាឡើងជិះកាណូត ហើយសមាជិកគ្រួសារទាំងអស់នោះសុទ្ធជាស្រីៗ

ទេ លើកលែងតែមានក្មេងតូចៗតែប៉ុណ្ណោះ។ ខ្ញុំជិះឡើងកាណូតជាមួយម្ដាយ ស្រាប់តែពេលនោះ កម្មាភិបាលម្នាក់បានអូសខ្ញុំចេញ ហើយគេយកខ្ញុំទៅដាក់នៅក្នុងក្រុមមួយប្រហែលជា នារីៗនៅលីវ ប្រហែលជា៤០នាក់។ អ៊ីចឹងខ្ញុំបែកពីបងប្អូនរបស់ខ្ញុំ។ គេបានបញ្ជាខ្ញុំឲ្យសំដៅទៅភូមិមួយឈ្មោះទ្រាស អ៊ំ! ទ្រា"។ ខ្ញុំសូមបន្តទៅទៀត។

[១៦:០០:១២]

"កម្មាភិបាលទាំងអស់នោះបានសួរយើងថា តើពួជអ្នកឯងអស់គ្នាហ្នឹង ពូជអី? ឃើញថាកូនស្រីរបស់ខ្ញុំឆ្លើយថា នាងជាជនជាតិចាម។ អ្នកផ្សេងទៀតបន្ទាប់មកហ្នឹងក៏ឆ្លើយដូចគ្នាអ៊ីចឹងដែរ។ បន្ទាប់មកទៀតដល់វេនខ្ញុំ ខ្ញុំក៏ព្យាយាមឆ្លើយធ្វើម៉េចឲ្យវាបានប្រយោជន៍ ខ្ញុំឆ្លើយថា ខ្ញុំខ្មែរ។ អ៊ីចឹងកម្មាភិបាលហ្នឹងរុញខ្ញុំ កម្មាភិបាលឈ្មោះ ហូ ហ្នឹងរុញខ្ញុំទៅផ្ទាច់នៅជញ្ជាំង ហើយម្នាក់ទៀតហ្នឹងក៏ឆ្លើយថាខ្មែរដែរ ហើយគេរុញមកដាក់នៅខាងខ្ញុំនេះដែរ។ មួយស្របក់ក្រោយមក អ្នកដែលឆ្លើយថាខ្លួនជាចាមនោះត្រូវនាំចេញពីផ្ទះនុង។ ខ្ញុំមើលគាត់តាមប្រហោងជញ្ជាំង អង្កាល់ហ្នឹងវាយប់រាងជ្រៅបន្តិចហើយ ខ្ញុំមើលមិនឃើញសូវច្បាស់ទេ ឃើញក្រោមពន្លឺព្រះចន្ទ។ ខ្ញុំឃើញខ្មែរក្រហមនាំនារីម្នាក់ដែលគេចងមុខទៅមាត់ទន្លេនៅមុខផ្ទះនុ៎ង។ ហើយបន្ទាប់មកទៀត គេទាញក្បាលមកក្រោយ ហើយអារ-ក។ ហើយនាទីផ្សេងៗទៀតដែលប្រកាសថាខ្លួនជាចាមហ្នឹង សុទ្ធតែគេអារ-កចោលទាំងអស់"។

[១៦:០១:៤៥]

បាទ នេះដើម្បីឆ្លើយតបទៅនឹងការកត់សម្គាល់របស់លោក ទាក់ទងនឹងការកត់សម្គាល់ ឬការបែងចែកដែលចាមជាកម្មវត្ថុ។ លោកសាស្ត្រាចារ្យ តាមយោបល់របស់លោក តើចាមជាកម្មវត្ថុនៃគោលនយោបាយសម្លាប់រង្គាលដែរឬទេ?

**ឆ៖** សូមអរគុណណាស់ដែលបានអានអត្ថបទនេះឲ្យខ្ញុំស្ដាប់។ លោកអាចឲ្យការបរិច្ឆេទមកខ្ញុំម្ដងទៀតបានទេ? ថាតើព្រឹត្តិការណ៍នេះកើតឡើងនៅពេលណាដែរ? ដើម្បីធ្វើម៉េចឲ្យខ្ញុំឆ្លើយទៅបានត្រឹមត្រូវ។

**សៈ** ឆ្នាំ១៩៧៨ គឺថាចុងឆ្នាំ១៩៧៨។

**ឆ៖** ហ្នឹងអាចជួយឲ្យខ្ញុំឆ្លើយបាន គឺនៅចុងបញ្ចប់ឆ្នាំ១៩៧៨ គឺគាត់ធ្វើការ -- ធ្វើទុក្ខបុកម្នេញទៅដល់ចាមហើយ។ ហើយគោលនយោបាយហ្នឹងក៏ពាក់ព័ន្ធទៅដល់ការកម្ចាត់ជនជាតិវៀតណាម គឺនិយាយសំដៅទៅលើពូជ ពូជខ្មែរ ដែលពីដើមគឺមិនបានប្រើប្រាស់ជាប៉ុន្មាននោះទេ។ នេះជាពាក្យ

វាក្យស័ព្ទមួយដើម្បីជំរុញឲ្យប្រជាជនកម្ពុជា ចូលរួមពាក់ព័ន្ធទៅនឹងពេលដែលគេធ្វើសង្គ្រាមប្រឆាំងជាមួយពួជ -- សង្គ្រាមពូជសាសន៍ជាមួយនឹងវៀតណាម។ គឺចង់សំដៅវែកមុខរកអ្នកណាមិនមែនជាខ្មែរ។

[១៦:០៣:៤៧]

ដូច្នេះនៅចុងបញ្ចប់នៃឆ្នាំ៧៨ ខ្ញុំចងចាំរំឭកទៅដល់ដំណាក់កាលនៃការបោសសម្អាត។ វាជាដំណាក់កាលមួយដ៏ឆ្កួតលីលានៅក្នុងរបបនោះ។ នៅក្នុងមជ្ឈិមក៏ដូចជានៅផ្នែកផ្សេងទៀត គឺជានយោបាយប្រកាន់ពូជាសាសន៍មួយ ជាដំណាក់កាលមួយថយក្រោយ គឺចន្លោះត្រឡប់មក៧៥-៧៦។ កាល នៅពេលហ្នឹងដែលគេហៅថា “អាចាម”។ ដូច្នេះគឺមានន័យថា គឺមានន័យថាមិនគោរពទៅដល់ជនជាតិចាមទេ។ ដូច្នេះការប្រកាន់ពូជសាសន៍នេះ គឺជាអព្ភូតហេតុដ៏អាក្រក់មួយ ហើយការណ៍អាក្រក់មួយដែលកើតឡើងនៅឆ្នាំ៧៨ ដែលកងកម្លាំងខ្មែរក្រហមធ្វើឡើងដើម្បីប្រឆាំងជាមួយនឹងជនជាតិវៀតណាម ដែលគេត្រូវសម្លាប់ជនជាតិវៀតណាម ដោយសារតែអ្នកនោះជាជនជាតិវៀតណាម។ នៅពេលនោះគឺថា តាំងពីពេលមិនទាន់មានសង្គ្រាមជាមួយកម្ពុជា។ ដូច្នេះ បរិបទនេះក៏ត្រូវខ្មែរក្រហមបន្តយកមកប្រើប្រាស់--

[១៦:០៥:២១]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅមានប៉ុន្មានសំណួរទៀត ពេលវេលាដូចជាដល់ម៉ោងកំណត់ហើយ។ តើលោកត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការតាំងសំណួរនេះ?

**លោក អូលីវីយេ បាហ្វូញ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំព្យាយាមនឹងចោទសំណួរតែពីរទៀត ហើយនិងសូមបញ្ចប់។ ធ្វើយ៉ាងម៉េចបានចប់មុនម៉ោងបួនដប់ប្រាំនាទី លោកប្រធាន។ ខ្ញុំសូមទៅមុខឲ្យលឿន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមន្ត្រីរដ្ឋបាលតុលាការផ្តល់ព័ត៌មានទៅខាងប្រធានអង្គភាពគ្រប់គ្រងតុលាការផង ដើម្បីសម្របសម្រួលមធ្យោបាយធ្វើដំណើរត្រឡប់ទៅលំនៅដ្ឋាននៅរសៀលនេះ។

សូមអញ្ជើញបន្ត!

[១៦:០៦:២២]

**លោក អូលីវីយេ៉ បាហ្វូញ៖**

បាទ សូមអរគុណជាអនេកប្បការលោកប្រធាន។

**សួរដោយលោក អូលីវីយេ៉ បាហ្វូញ៖**

**ស៖** កាលបរិច្ឆេទឆ្នាំ១៩៧៨ គឺថាវាមានកម្រិតឆ្លួតលីលាខ្ពស់ជាងគេបំផុតនៅឆ្នាំនុំង។ ខ្ញុំសូមអានសក្ខីកម្មមួយ គឺថាឯកសារ D125/98។ ERN ជាភាសាខ្មែរ 00218553 រហូតដល់ 54, ជាភាសាអង់គ្លេស 00242087 ដល់ 88។ "យើងនៅឆ្នាំ១៩៧៧ ការកាប់សម្លាប់នោះមានខ្ពស់បំផុតនៅក្នុងឆ្នាំ១៩៧៧ ជនរងគ្រោះភាគច្រើនជាប្រជាជនថ្មី។ ហើយក៏ប៉ុន្តែនៅខែកញ្ញា និងខែសីហា ឆ្នាំ១៩៧៨ មានចាមជាច្រើនត្រូវគេប្រហារជីវិត។ នៅតាម -- នៅវត្តអូរត្រកួន ខ្ញុំចាំយ៉ាងច្បាស់អំពីកាលបរិច្ឆេទ -- មិនច្បាស់ទេពីការបរិច្ឆេទ ក៏ប៉ុន្តែនៅឆ្នាំ១៩៧៨ ប្រធានក្រុមខ្ញុំមកប្រាប់ខ្ញុំថា ឈ្លបនោះត្រូវការជំនួយ ឈ្លបដាវែងត្រូវការជំនួយ ត្រូវការជំនួយបួននាក់ ដើម្បីឲ្យទៅភូមិសំបូរមាស។ នៅក្នុងភូមិនុំងពួកគេចាប់អ្នកភូមិទាំងអស់។ គេបានឲ្យខ្ញុំ ហើយនិងបីនាក់ទៀតជូនដំណើរគេទៅវត្តអូរត្រកួន។ គេមិនចងជនរងគ្រោះនោះទេ អ្នកភូមិទាំងអស់នោះភ័យទាំងអស់។ អ្នកខ្លះនោះស្រែក ក៏ប៉ុន្តែពុំមានអ្នកណាហ៊ានរត់ទេ។

[១៦:០៨:២៩]

ខ្ញុំអាណិតពួកគាត់មែនទែន ពីព្រោះថាមនុស្សភាគច្រើន អ្នកភូមិភាគច្រើនសុទ្ធតែខ្ញុំស្គាល់ ព្រោះថាខ្ញុំធ្លាប់នេសាទត្រីជាមួយពួកគាត់។ នៅពេលដែលទៅដល់មន្ទីរនៅមន្ទីរអូរត្រកួន -- មន្ទីរសន្តិសុខអូរត្រកួនហ្នឹង គេបានបំបែកអ្នកភូមិទាំងអស់ ស្រីគេរុញចូលទៅវិហារ ហើយគេវាយប្រុសៗនឹងដំបងដែកដើម្បីបំបាក់ស្មារតីពួកគេ។ ហើយបន្ទាប់មកទៀត គេបានឃុំឃាំងពួកគេនៅក្នុងវិហារ។ ខ្ញុំមិនឃើញការកាប់សម្លាប់ទាំងអស់នេះផ្ទាល់ភ្នែកទេ។ ប៉ុន្តែមិត្តខ្ញុំឈ្មោះ មឿន ជាអ្នកឡើងត្នោតបានប្រាប់ខ្ញុំថា គេបានយកអ្នកភូមិទាំងនោះទៅសម្លាប់នៅពេលយប់ពីម៉ោងប្រាំពីរ ដល់ម៉ោង ដប់ពីរអធ្រាត្រ រួមបញ្ចូលទាំងកុមារៗផងដែរ។ កុមារទាំងអស់នេះត្រូវបានគេវាយបោកផ្ទប់ទៅនឹងគល់ឈើ ហើយបោះសាកសពកុមារនោះទម្លាក់ចូលទៅក្នុងរណ្ដៅជាមួយមនុស្សចាស់ ដែលស្ថិតនៅក្បែរគុម្ពឫស្សីខាងកើតវត្ត។

[១៦:០៩:៤៣]

នៅទីនោះ គឺមានស្ត្រីៗដែលជាអ្នកទោសផងដែរ ក៏ប៉ុន្តែគេមិនដាក់ខ្នោះគាត់ទេ។ ហើយ មឿន នោះបានប្រាប់ខ្ញុំថា គេបានឃុំខ្លួនអ្នកទាំងអស់នោះមិនមែនឃុំដល់មួយយប់នោះទេ បន្ទាប់ពេលក្រោយ

មក គេនាំទៅក្បែរគុម្ពឫស្សី ដែលជាកន្លែងសម្លាប់មនុស្ស។ ហើយមិនដែលមាននរណាប្រាប់មូលហេតុនោះទេ ក៏ប៉ុន្តែខ្ញុំសង្កេតឃើញថា ពួកគេបានចាប់ ការប្រឆាំងនឹងចាម អ្នកដែលមិនមែនជាខ្មែរ។ នេះដែលនៅមុនឆ្នាំ១៩៧៨ រឿងរ៉ាវដែលកើតទាំងអស់នេះ។ នៅចំណុចជាមុននឹងបញ្ចប់នេះ ខ្ញុំសូមសួរទៅលោកអ្នកជំនាញ អំពីទំនាក់ទំនងពិសេស ដែលមានរវាង ប៉ុល ពត និង ខៀវ សំផន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី -- មេធាវីជាតិការពារក្តីលោក អៀង សារី!

[១៦:១១:០០]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំមើលម៉ោងវាច្រើនដែរ ប៉ុន្តែខ្ញុំសូមអភ័យទោស ដោយសារ ខ្ញុំឡើងមកជំទាស់ចំពោះសំណួរនេះ ពីព្រោះថា ខ្ញុំបានស្តាប់ បើមិនច្រឡំទេ លោកសាស្ត្រាចារ្យអះអាងហើយថា គ្មានការធ្វើទុក្ខបុកម្នេញផ្នែកខាងសាសនា ជាពិសេសសាសនាចាមជាប្រព័ន្ធទេ ហើយលោកសហភាតា ក៏កំពុងតែជំរុញឲ្យលោកអ្នកជំនាញឆ្លើយនូវសំណួរបែបនេះ ហើយសំណួរបែបនេះ តាមពិតជាសំណួរទាក់ទងផ្នែកផ្លូវច្បាប់ទេ មិនមែនជាសំណួរទាក់ទងនឹងផ្នែកប្រវត្តិសាស្ត្រទេ។ យើងសួរថា យកច្បាប់ហើយអង្គហេតុឧក្រិដ្ឋកម្ម អាហ្នឹងខ្ញុំទទួល។ ប៉ុន្តែបើយកសំណួរបែបនេះ មកសួរសម្រាប់កិច្ចការប្រវត្តិសាស្ត្រ ខ្ញុំសូមជំទាស់។ សូមអរគុណ។

**លោក អូលីវីយេ បាហ្វូញ៖**

បាទ ខ្ញុំមិនយល់អំពីការជំទាស់នេះទេ ព្រោះថា ខ្ញុំមិនយល់ថា លក្ខណៈច្បាប់ហ្នឹង នៅក្នុងសំណួរហ្នឹងមានលក្ខណៈច្បាប់យ៉ាងម៉េចទេ? សូមឲ្យសហភាតាពន្យល់ខ្ញុំ ព្រោះថាឥឡូវនេះ យើងដល់ម៉ោងបួនដប់ប្រាំនាទីហើយ ខ្ញុំមិនអាចបញ្ចប់សំណួរខ្ញុំនោះទេ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សាស្ត្រាចារ្យឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៦:១២:៤០]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** អត្ថបទដែលលោកអាន គឺពាក់ព័ន្ធទៅនឹងចាម ខ្ញុំមានការព្រួយថា ខ្ញុំព្រួយបារម្ភថា ឆ្នាំ៧៧

នោះយើងអត់មានខែ ចាមទាំងអស់នេះដូចជានៅភូមិភាគបូព៌ា ដែលជាគឺថា អ្នកដែលរស់នៅទាំងនោះ គឺត្រូវថាដំបូងគេគឺថា ត្រូវថាមានការឃោគយល់ដំបូងឡើយ ហើយក្រោយមកត្រូវបានគេជ្រើសរើស និងសម្លាប់ចោល។ ខ្ញុំមិនច្បាស់ថាតើនៅពេលដែលមេធាវីការពារក្តីក្រោកឈរឡើង លោកយល់ថា អត្ថបទនេះវាពាក់ព័ន្ធទៅនឹង អៀង សារី, ខៀវ សំផន ឬ ប៉ុល ពត, អៀង សារី, ខៀវ សំផន ឬក៏យ៉ាងណា? ខ្ញុំអត់ច្បាស់ទេដែលថា មេធាវីការពារក្តីគាត់លើកឡើងមកជំទាស់អម្បាញ់មិញនេះ។

**ស៖** មានការច្រឡូកច្របល់មួយគឺថា ទាក់ទងទៅនឹងសក្ខីកម្មហ្នឹងគឺ សីហា -- និង កញ្ញា, សីហា ឆ្នាំ១៩៧៧។ ហើយទាក់ទងទៅនឹងឈ្មោះ ប៉ុល ពត, ខៀវ សំផន ដែលលោកបានលើកអម្បាញ់មិញនេះ គឺការនិយាយអំពីទំនាក់ទំនងពិសេសរវាងបុគ្គលទាំងពីររូបនេះ។

**លោក អូលីវីយេ បាហូញ៖**

ហើយខ្ញុំប្រហែលជា ខ្ញុំសូម -- ប្រហែលជាមិនអាចបញ្ចប់សំណួរនេះទេ។ លះបង់សំណួរនេះចោលហើយ ព្រោះថាឥឡូវនេះ ម៉ោងបួនដប់ប្រាំនាទីហើយ បើសិនជាលោកប្រធានអនុញ្ញាតអាចបន្តបញ្ចប់សំណួរនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ ហើយអង្គជំនុំជម្រះបញ្ចប់នូវការ ពេលវេលាតាំងសំណួរដេញដោលចំពោះក្រុមមេធាវីការពារក្តី -- សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រឹមនេះ។

សូមអញ្ជើញ!

[១៦:១៤:៤២]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ ខ្ញុំបាទស្នើសុំម្តងទៀត សូមអង្គជំនុំជម្រះសាលាដំបូងរក្សាទុកកំណត់ត្រារបស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ ទោះជាគាត់ធ្វើការកត់ត្រានូវបន្ទប់សវនាការក្តី ឬកំណត់ត្រាពីគេហដ្ឋាន ពីចម្ងាយក្តី។ សូមរក្សាទុក ព្រោះក្នុងករណីដែលយើងខ្ញុំនឹងប្តឹងសាទុក្ខ នោះតុលាការនឹងមានភស្តុតាងនេះយកទៅធ្វើការដេញដោល ប៉ុន្តែបើសិនជាតុលាការមិនធ្វើការរក្សាទុក តើថ្ងៃក្រោយយើងនឹងមានភស្តុតាងនេះមកដេញដោលនៅចំពោះមុខសាលា -- តុលាការកំពូលឬអត់? ខ្ញុំសូមស្នើម្តងទៀត សុំរក្សា -- ឲ្យ

E1/93.1

តុលាការរក្សាកំណត់ត្រាដូចខ្ញុំបានពោលអម្បាញ់មិញនេះ នៅក្នុងដែរបស់អង្គជំនុំជម្រះ សាលាដំបូងជាបណ្ដោះអាសន្ន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធនៅលើសំណើសុំនេះជាលើកទីពីរ។ សម្រេចរួចហើយ។ ដូច្នេះ អង្គជំនុំជម្រះមិនត្រួតពិនិត្យលើសេចក្ដីសម្រេចរបស់ខ្លួនទេ នៅអ្វីដែលធ្វើជាកំណត់ត្រាដែធម្មតា ដើម្បីជាការចងចាំក្នុងការឆ្លើយតបទៅនឹងសំណួរផ្សេងៗ ដែលអ្នកយល់ដឹង អ្នកដែលមានការត្រៀមខ្លួននៅក្នុងការចូលរួមកិច្ចពិភាក្សាផ្សេងៗ តែងតែធ្វើដូច្នេះ មិនអាចមិនមានការកត់ត្រា ហើយទៅចូលរួមប្រជុំនៅកិច្ចពិភាក្សាធំៗបានទេ។

[១៦:១៦:៣៦]

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីន្ទូហ្វ៊ី៖**

ខ្ញុំនឹងសង្ខេបខ្លីទេ លោកប្រធាន ហើយខ្ញុំបានស្នើសុំប្រតិចារឹកដើម្បី -- ខ្ញុំបានឃើញអ៊ីមែលទាក់ទងទៅនឹង -- ហើយយើងចង់បានប្រតិចារឹកខ្មែរ ចង់បាននូវចុងថ្ងៃនេះ គឺថាអង់គ្លេសដូចគ្នាដែរ ហើយនិងភាសាបារាំង ក៏និងចង់បញ្ជូននូវដើមថ្ងៃចន្ទ គឺថាអាចនឹងមានអត្ថប្រយោជន៍ ហើយយើងៗនឹងបានប្រតិចារឹកនៅចុងថ្ងៃនេះ ហើយសំណើយើងជូនឲ្យសហសេវិកពេលបន្ថែមទៀត ហើយយើងចង់ៗបានពេលមួយថ្ងៃ មួយក្រុម គឺថាពីរថ្ងៃកន្លះ។ ដូច្នេះគឺថាមួយថ្ងៃសម្រាប់ក្រុមនីមួយៗ គឺរយៈពេលសមល្មមសម្រាប់យើងសួរខ្លឹមសាររបស់គាត់។ ហើយយើងនឹងព្យាយាមបញ្ចប់ក្នុងពីរថ្ងៃកន្លះចំពោះក្រុមទាំងបី ប៉ុន្តែបើជាការល្អ យើងចង់បានមួយថ្ងៃមួយក្រុមបាទ។

[១៦:១៧:៥៤]

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យទេ។ ក្រៅពីពីរថ្ងៃកន្លះ លើកលែងតែពេលវេលានុំងវាមានការខាតបង់ដោយកិច្ចពិភាក្សាផ្សេងៗ ដូចកិច្ចដំណើរការការផ្ដល់សិទ្ធិទៅឲ្យក្រុមតំណាងសហព្រះរាជអាជ្ញាសួរ ហើយមានការជំទាស់តវ៉ាដែលត្រូវចំណាយពេលវេលាអស់ច្រើនម៉ោង ដោយក្រុមមេធាវីការពារក្ដីជាមួយនឹងភាគីពាក់ព័ន្ធ ហើយនិងកិច្ចដំណើរការរបស់អង្គជំនុំជម្រះ។ ដូចជាព្រឹកមិញ យើងបានបន្ថែមម៉ោងឲ្យ១៥នាទី ដោយសារមានការខាតបង់១៥នាទី នៅក្នុងការជំទាស់តវ៉ា កាលពីដើមដំបូងនៃពេល

វេលាចូលមកចាប់ផ្តើម។ ដូច្នេះសូមជម្រាបថា មិនអនុញ្ញាតឲ្យទេ លើកលែងតែស្ថានភាពចាំបាច់ដោយមូលហេតុផ្សេងដែលនាំឲ្យខាតបង់ពេលវេលាដែលបានកំណត់ឲ្យ។

[១៦:១៨:៤៣]

បញ្ហាទីពីរ សំណើសុំគឺយើងបានបញ្ជាក់រួចហើយ អំពីប្រតិចារឹក មិនមែនជាមុខងាររបស់អង្គជំនុំជម្រះទេ មិនមែនស្ថិតនៅការគ្រប់គ្រងការចាត់ចែងរបស់អង្គជំនុំជម្រះទេ នៅក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់តុលាការ ហើយយើងសូមផ្តល់ព័ត៌មានថា កិច្ចដំណើរការនៃការធ្វើប្រតិចារឹកនេះមិនអាចដំណើរការបានដូចបំណងដែលខ្លួនសុំនោះទេ។ គឺប្រតិចារឹកដែលប្រធានអង្គភាពគ្រប់គ្រងតុលាការបានផ្តល់ឲ្យយើងមុននេះ គឺបានបង្ហាញថា ប្រតិចារឹកជាភាសាអង់គ្លេស ឬភាសាបារាំងត្រូវការពេលវេលាមួយថ្ងៃ ឬពីរថ្ងៃបន្ទាប់ពីថ្ងៃធ្វើសវនាការទើបអាចធ្វើរួច។ ដោយឡែក សេចក្តីព្រៀងប្រតិចារឹកជាភាសាខ្មែរគឺអាចទទួលយកបានជារៀងរាល់ចុងថ្ងៃនីមួយៗ នៃថ្ងៃធ្វើសវនាការ។ ដូច្នេះ ប្រសិនបើភាពចាំបាច់ គឺសហការគ្នារវាងក្រុមមេធាវីជាតិដើម្បីយល់ដឹងអំពីបញ្ហាខ្លឹមសារនៃប្រតិចារឹកនោះអាចយកធ្វើមូលដ្ឋានពិភាក្សាក្នុងការតាំងសំណួរដេញដោលបានហើយ។

[១៦:២០:១១]

បាទ កិច្ចដំណើរការសវនាការថ្ងៃនេះ ដល់ពេលសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ សប្តាហ៍ក្រោយ គឺនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទសប្តាហ៍ក្រោយនេះ នឹងបន្តធ្វើដោយការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ដោយក្រុមមេធាវីការពារក្តីដោយចាប់ផ្តើមដំបូង គឺក្រុមមេធាវីការពារក្តី នួន ជា។ សូមភាគី និងសាធារណជនជ្រាប។

ហើយសូមលោកសាស្ត្រាចារ្យ កិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ ហើយសវនាការនឹងបន្តធ្វើនៅថ្ងៃ២៣ ខែកក្កដា ឆ្នាំ២០១២ ទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកសាស្ត្រាចារ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយទៀត។ ហើយសូមសាស្ត្រាចារ្យបានឈប់សម្រាកពីរថ្ងៃហ្នឹង រីករាយនៅទីក្រុងភ្នំពេញ។

[១៦:២១:២៥]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ក្នុងការជូន

អ្នកជំនាញវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក ហើយនិងឲ្យនាំខ្លួនពួកគាត់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី២៣ ខែកក្កដា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួន។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:២២ នាទី)*